ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# គោលការណ៍ណែនាំស្ដីពី ក្របខណ្ឌកិច្ចគាំពារសង្គម ឆ្លើយតបនឹងគ្រោះអាសន្ន

គាំពារ សង្គម កម្ពុជា
SOCIAL PROTECTION IN CAMBODIA

រៀបចំដោយក្រុមប្រឹក្សាជាតិគាំពារសង្គម
ខែកញ្ញា ឆ្នាំ២០២៣

# មាតិកា


**បញ្ជីតារាង** .......... I

**បញ្ជីរូបភាព** .......... II

**អារម្ភកថា** .......... III

**បុព្វកថា** .......... V

**ខ្លឹមសារសង្ខេបប្រតិបត្តិ** .......... VII

**១. សេចក្តីផ្តើម** .......... ១

១.១ ភាពងាយរងគ្រោះអាសន្ននៅកម្ពុជា .......... ១

១.២ តួនាទីកិច្ចគាំពារសង្គមក្នុងការឆ្លើយតបនឹងគ្រោះអាសន្ន .......... ២

១.៣ ភាពចាំបាច់នៃកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ននៅកម្ពុជា .......... ៣

**២. ទស្សនាទានរួម** .......... ៥

២.១ គោលបំណង .......... ៥

២.២ អភិក្រមនៃក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ននៅកម្ពុជា .......... ៥

**៣. ជម្រើសឧបករណ៍គោលនយោបាយគាំពារសង្គម សម្រាប់ឆ្លើយតបនឹងគ្រោះអាសន្ន** .......... ៨

៣.១ ការកែសម្រួលយន្តការអនុវត្តកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមដែលមានស្រាប់ .......... ១០

៣.២ ការពង្រីកវិសាលភាពគ្របដណ្តប់តាមខ្សែបញ្ឈរ .......... ១២

៣.៣ ការពង្រីកការគ្របដណ្តប់ដល់គ្រួសារថ្មីៗ ដែលទទួលរងផលប៉ះពាល់ដោយគ្រោះអាសន្ន .......... ១៣

៣.៤ ការបំពេញតម្រូវការថ្មីៗ តាមរយៈការផ្សាភ្ជាប់កម្មវិធីជំនួយសាច់ប្រាក់ពិសេសបន្ទាន់ក្នុងគ្រាអាសន្នរបស់ស្ថាប័នមនុស្សធម៌ នឹងប្រព័ន្ធគាំពារសង្គម .......... ១៨

៣.៥ ជម្រើសឧបករណ៍គោលនយោបាយសម្រាប់អនាគត .......... ២០

៣.៥.១.ការពង្រីកវិសាលភាពគ្របដណ្តប់នៃមូលនិធិសមធម៌សុខាភិបាល .......... ២០

៣.៥.២.ប្រព័ន្ធស្បៀងបម្រុង .......... ២០

៣.៥.៣.ជម្រើសផ្សេងទៀត .......... ២១

**៤. តួមិសាស្ត្រអាទិភាព និងសូចនាករប្រកាសអាសន្ន** .......... ២២

**៥. សកម្មភាពអាទិភាព** .......... ២៧

៥.១ ការរៀបចំក្របខណ្ឌគោលនយោបាយ និងស្ថាប័ន .......... ២៨

៥.២ ការរៀបចំយន្តការអនុវត្តកម្មវិធី .......... ២៩

៥.៣ ប្រព័ន្ធបើកផ្តល់ .......... ៣០

៥.៤ ប្រព័ន្ធទិន្នន័យ និងព័ត៌មាន .......... ៣២

៥.៥ យន្តការហិរញ្ញប្បទាន ........ ៣៤
**៦. តួនាទី និងយន្តការសម្របសម្រួលរវាងក្រសួង-ស្ថាប័ន** ........ ៣៥
៦.១ តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន ........ ៣៥
៦.២ យន្តការសម្របសម្រួលសម្រាប់កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ........ ៣៨
៦.២.១ យន្តការសម្របសម្រួលអន្តរក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ........ ៣៩
៦.២.២ យន្តការសម្របសម្រួលរវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ ........ ៤០
**យន្តការតាមដាន និងវាយតម្លៃ** ........ ៤១
**សេចក្តីសន្និដ្ឋាន** ........ ៤២
**សន្ទានុក្រម** ........ ៤៣

# បញ្ជីតារាង

តារាងទី១៖ សូចនាករកំណត់កម្រិតភាពធ្ងន់ធ្ងរនៃគ្រោះទឹកជំនន់នៅកម្ពុជា........................២២
តារាងទី២៖ ទីតាំងភូមិសាស្ត្រអាទិភាព និងតម្រូវការព័ត៌មានក្នុងការអនុវត្តវិធានការអន្តរាគមន៍ទៅតាមប្រភេទគ្រោះអាសន្ន ......................................................................២៣
តារាងទី៣៖ តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន ........................................៣៥

# បញ្ជីរូបភាព


រូបភាពទី១៖ វិធីសាស្ត្រដែលប្រព័ន្ធគាំពារសង្គមគាំទ្រដល់ការឆ្លើយតបនឹងគ្រោះអាសន្ន ......... ៣

រូបភាពទី២៖ កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ននៅកម្ពុជា៖ ការគ្របដណ្តប់ទៅដល់ពលរដ្ឋដែលងាយរងគ្រោះដោយសារគ្រោះអាសន្ន ...................................... ៩

រូបភាពទី៣៖ មូលដ្ឋានគ្រឹះនៃក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ............. ២៧

រូបភាពទី៤៖ ក្របខណ្ឌសម្របសម្រួលស្ថាប័នសម្រាប់ប្រព័ន្ធគាំពារសង្គមនៅកម្ពុជា ............ ៣៩

# អារម្ភកថា

ប៉ុន្មានទសវត្សន៍ចុងក្រោយនេះ ការប្រែប្រួលអាកាសធាតុបានជះឥទ្ធិពលអវិជ្ជមានលើគ្រប់បណ្តាប្រទេស ក្នុងនោះព្រះរាជាណាចក្រកម្ពុជា ក៏បានក្លាយជាប្រទេសមួយដែលងាយទទួលរងផលប៉ះពាល់ពីគ្រោះធម្មជាតិផ្សេងៗ ដូចជាគ្រោះទឹកជំនន់, គ្រោះរាំងស្ងួត និងខ្យល់ព្យុះ ជាដើម។ បន្ថែមលើនេះ ព្រះរាជាណាចក្រកម្ពុជាក៏ធ្លាប់រងផលប៉ះពាល់ពីវិបត្តិផ្សេងទៀតជារឿយៗផងដែរ។ ជាក់ស្តែង, ថ្មីៗកន្លងទៅនេះ កម្ពុជាក៏ដូចជាបណ្តាប្រទេសផ្សេងទៀតទូទាំងសកលលោកបានប្រឈមនឹងការរាតត្បាតនៃជំងឺកូវីដ-១៩ និងការកើនឡើងខ្ពស់នៃអត្រាអតិផរណា។ គ្រោះអាសន្ន និងវិបត្តិទាំងនេះ បានគំរាមកំហែងដោយផ្ទាល់ដល់អាយុជីវិត សន្តិសុខស្បៀង និងកម្រិតជីវភាពរបស់ពលរដ្ឋ ដែលជាទូទៅ ផលប៉ះពាល់ទាំងនេះមានទម្ងន់កាន់តែខ្លាំងលើគ្រួសារក្រីក្រ។ ក្នុងគ្រាមានគ្រោះអាសន្ន និងគ្រោះមហន្តរាយនានា, រាជរដ្ឋាភិបាលកម្ពុជាតែងផ្តោតការយកចិត្តទុកដាក់ខ្ពស់ក្នុងការដោះស្រាយ ជាពិសេសការដាក់ចេញអន្តរាគមន៍ភ្លាមៗ ដើម្បីសង្គ្រោះជីវិត ក៏ដូចជាផ្តល់ជម្រក និងស្បៀងអាហារបន្ទាន់។

បទពិសោធន៍នៃវិបត្តិជំងឺកូវីដ-១៩ និងគ្រោះអាសន្ននានាកន្លងទៅ បានបង្ហាញឱ្យឃើញថាផលប៉ះពាល់នៃគ្រោះអាសន្ន និងវិបត្តិទាំងនោះ អាចបង្កស្លាកស្នាមយូរអង្វែងលើកម្រិតជីវភាពរបស់ពលរដ្ឋ។ រាជរដ្ឋាភិបាលយល់ច្បាស់អំពីបញ្ហាប្រឈម និងភាពចាំបាច់ក្នុងការដាក់ចេញនូវអន្តរាគមន៍គាំពារសង្គម ដើម្បីបំពេញបន្ថែមលើអន្តរាគមន៍សង្គ្រោះបន្ទាន់ភ្លាមៗនានា ក្នុងគោលដៅជួយទ្រទ្រង់ជីវភាពពលរដ្ឋក្នុងអំឡុងពេលជួបការលំបាកទាំងនោះ។ ជាក់ស្តែង រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តកម្មវិធីជាតិជំនួយសង្គមមួយចំនួន រួមមានៈកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ក្រោយពេលបិទខ្ទប់ទ្រង់ទ្រាយធំ, និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យដោយគ្រោះទឹកជំនន់ និងក្នុងអំឡុងពេលមានសម្ពាធអតិផរណា ទោះបីជាប្រព័ន្ធគាំពារសង្គមកម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍក៏ដោយ។

ប្រព័ន្ធគាំពារសង្គមកម្ពុជាមានថាមវន្តខ្ពស់ និងមានការវិវឌ្ឍគួរឱ្យកត់សម្គាល់ ក្នុងរយៈពេលចុងក្រោយនេះ ជាពិសេសបន្ទាប់ពីការដាក់ឱ្យអនុវត្ត **"ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥"** ដែលផ្តល់មូលដ្ឋានគ្រឹះសម្រាប់ការរៀបចំក្របខណ្ឌ និងយន្តការស្ថាប័ន, ការដាក់ឱ្យអនុវត្តកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម, ការពង្រឹង និងពង្រីកយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដោយគ្របដណ្តប់លើគ្រួសារងាយរងហានិភ័យ និងការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងការចុះបញ្ជី និងការបើកផ្តល់អត្ថប្រយោជន៍ជាដើម។ កិច្ចការទាំងនេះ បាន និងកំពុងបង្កើតបរិយាកាសអំណោយផលសម្រាប់កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន។ ឈរលើមូលដ្ឋាននេះ, រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវ **"គោលការណ៍ណែនាំស្តីពីក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន"** ដោយផ្អែកលើការវិភាគយ៉ាងលម្អិតលើស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ ក៏ដូចជាមេរៀន និងបទពិសោធន៍ របស់កម្ពុជាក្នុងការគ្រប់គ្រងវិបត្តិ ព្រមទាំងគិតគូរផងដែរនូវកត្តាអំណោយផល និងកត្តារាំងស្ទះនានា។

**“ក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន”** នេះ ត្រូវបានរៀបចំឡើង ក្នុងគោលបំណងត្រៀមរួចជាស្រេច ក្នុងការដាក់ចេញអន្តរាគមន៍គាំពារសង្គម ជាមួយនឹងជម្រើសឧបករណ៍គោលនយោបាយជំនួយសង្គម និងសន្តិសុខសង្គម ដែលមានលក្ខណៈសមស្រប ឆ្លើយតបនឹងគ្រោះអាសន្ន បន្ថែមលើផែនការគ្រប់គ្រងគ្រោះមហន្តរាយ ដោយផ្អែកលើវិធីសាស្ត្រចំនួន៤ គឺ៖ (១) ការកែសម្រួលយន្តការអនុវត្តរបបសន្តិសុខសង្គម ឬកម្មវិធីជំនួយសង្គមដែលមានស្រាប់, (២) ការពង្រីកវិសាលភាពរបប ឬកម្មវិធីដែលមានស្រាប់ តាមខ្សែផ្ដេក និងខ្សែបញ្ឈរ, (៣) ការដាក់ចេញនូវរបប ឬកម្មវិធីអន្តរាគមន៍ពិសេសថ្មីៗ, និង (៤) ការបំពេញតម្រូវការថ្មីៗ តាមរយៈការផ្សារភ្ជាប់កម្មវិធីជំនួយសាច់ប្រាក់បន្ទាន់ក្នុងគ្រាអាសន្នរបស់ស្ថាប័ន និងអង្គការមនុស្សធម៌ ជាមួយនឹងប្រព័ន្ធគាំពារសង្គមរបស់រាជរដ្ឋាភិបាល។ រាល់អន្តរាគមន៍គាំពារសង្គមដែលនឹងត្រូវដាក់ចេញក្រោមក្របខណ្ឌនេះ សុទ្ធតែមានចរិតជាអន្តរាគមន៍មួយគ្រា សម្រាប់រយៈពេលកំណត់មួយជាក់លាក់ ដើម្បីដោះស្រាយបញ្ហាក្នុងតំបន់ភូមិសាស្ត្រដែលរងផលប៉ះពាល់ ដោយកំណត់ច្បាស់លាស់ជាមុននូវយុទ្ធសាស្ត្រចាកចេញសមស្រប។

ការបោះជំហានទៅមុខនៃកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន និងការដាក់ឱ្យអនុវត្តជម្រើសឧបករណ៍គោលនយោបាយឆ្លើយតបនឹងគ្រោះអាសន្ននានា ត្រូវការជាចាំបាច់នូវកិច្ចសហការអនុវត្តពីសំណាក់ក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ។ កិច្ចសហការនេះកសាងនូវបណ្ដុំជាមូលដ្ឋាន (Building Blocks) នៃក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ដែលមានសកម្មភាពអាទិភាពទៅតាមផ្នែកនីមួយៗ នៃបណ្ដុំជាមូលដ្ឋានទាំង ៥ ដែលត្រូវបានដាក់ចេញក្រោមក្របខណ្ឌនេះ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលសង្ឃឹមយ៉ាងមុតមាំថា **“ក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន”** នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការបំពេញបន្ថែមលើកិច្ចខិតខំរបស់រាជរដ្ឋាភិបាល ឱ្យបានកាន់តែទូលំទូលាយសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព, ការកាត់បន្ថយភាពក្រីក្រ និងភាពងាយរងគ្រោះ, អសន្តិសុខស្បៀង, និងការពង្រឹងភាពធន់រយៈពេលវែងសម្រាប់គ្រួសារនីមួយៗ តាមរយៈការផ្ដល់កិច្ចគាំទ្រដល់គ្រួសារទាំងនោះនូវមធ្យោបាយ និងលទ្ធភាពដើម្បីដោះស្រាយបញ្ហាជីវភាព និងការស្តារជីវភាពឡើងវិញ ប្រកបដោយប្រសិទ្ធភាព ទាំងក្នុងអំឡុងពេល និងក្រោយពេលគ្រោះអាសន្ន។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា **“គោលការណ៍ណែនាំស្ដីពីក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន”** នេះ នឹងក្លាយជាមគ្គុទ្ទេសក៍ដ៏សំខាន់ ក្នុងការកំណត់ជម្រើសឧបករណ៍គោលនយោបាយសមស្របដែលអាចជួយស្រោចស្រង់កម្រិតជីវភាពរបស់ពលរដ្ឋ នៅពេលប្រឈមនឹងគ្រោះអាសន្ន ឬវិបត្តិនានា ក្នុងពេលអនាគត។

ថ្ងៃ ពុធ ៦កើត ខែ ភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# បុព្វកថា

ក្រុមប្រឹក្សាជាតិគាំពារសង្គមរៀបចំ **"ក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន"** នេះឡើង ក្នុងគោលបំណងធ្វើស្ថាប័នូបនីយកម្មយន្តការឆ្លើយតបនឹងគ្រោះអាសន្ន ក្នុងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម សំដៅត្រៀមរួចជាស្រេចក្នុងការដាក់ចេញនូវអន្តរាគមន៍ចាំបាច់នានា ដើម្បីគាំទ្រ និងទ្រទ្រង់ជីវភាពពលរដ្ឋឱ្យបានទាន់ពេល និងចំគោលដៅ ក្នុងករណីមានគ្រោះអាសន្ន ឬវិបត្តិធ្ងន់ធ្ងរណាមួយកើតឡើង បំពេញបន្ថែមលើវិធានការឆ្លើយតបដើម្បីជួយសង្គ្រោះបន្ទាន់ភ្លាមៗ ដែលមានស្រាប់របស់រាជរដ្ឋាភិបាល។

**ក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន** ដែលដាក់ឱ្យអនុវត្តដោយគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលនេះ នឹងប្រើប្រាស់ប្រព័ន្ធគាំពារសង្គមក្នុងការផ្តល់នូវកិច្ចគាំពារដែលមានលក្ខណៈជាប្រព័ន្ធ, អាចទស្សទាយទុកជាមុន, ទាន់ពេល និងមានប្រសិទ្ធភាព ជូនពលរដ្ឋ ជាពិសេសពលរដ្ឋក្នុងគ្រួសារក្រីក្រ និងងាយរងហានិភ័យ ដើម្បីឆ្លើយតបនឹង **គ្រោះអាសន្នធម្មជាតិ, វិបត្តិម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងវិបត្តិសុខភាពសាធារណៈ** ទៅតាមតំបន់ភូមិសាស្ត្រជាក់លាក់ **ទាំងក្នុងអំឡុងពេលគ្រោះអាសន្ន** ដើម្បីរក្សាលំនឹងជីវភាព **និងក្រោយគ្រោះអាសន្ន** ដើម្បីស្តារជីវភាពឡើងវិញ ដោយកំណត់អំពីកម្រិតនៃគ្រោះអាសន្ន ដែលអាចឈានទៅសម្រេចដាក់ឱ្យអនុវត្តអន្តរាគមន៍ ស្របតាមជម្រើសឧបករណ៍គោលនយោបាយដែលបានត្រៀមទុកជាមុន ជាមួយនឹងយន្តការ និងប្រព័ន្ធប្រតិបត្តិការដែលមានស្រាប់។

ក្របខណ្ឌនេះ ក៏ដាក់ចេញនូវការងារអាទិភាពតាមបណ្តុំជាមូលដ្ឋានចំនួន៥ គឺ៖ (១) ការរៀបចំក្របខណ្ឌគោលនយោបាយ និងស្ថាប័ន, (២) ការរៀបចំយន្តការអនុវត្តឧបករណ៍គោលនយោបាយអន្តរាគមន៍, (៣) ប្រព័ន្ធបើកផ្តល់, (៤) ប្រព័ន្ធទិន្នន័យ និងព័ត៌មាន និង (៥) ហិរញ្ញប្បទាន ក្នុងគោលបំណងកសាងភាពធន់ក្នុងសង្គម, បង្កើនភាពត្រៀមលក្ខណៈនៃប្រព័ន្ធគាំពារសង្គម, ជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម និងការត្រៀមខ្លួនទុកជាមុន ដើម្បីឆ្លើយតបនឹងគ្រោះអាសន្ននានា។ លើសពីនេះ ក្របខណ្ឌនេះ ក៏កំណត់ផងដែរអំពីតួនាទី និងភារកិច្ចរបស់ក្រសួង-ស្ថាប័នដែលមានសមត្ថកិច្ចក្នុងការចូលរួមអនុវត្ត និងបើកផ្លូវឱ្យមានយន្តការសម្របសម្រួលអន្តរក្រសួង-ស្ថាប័ន ព្រមទាំងអនុញ្ញាតឱ្យរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ពង្រឹងកិច្ចសហការ និងការធ្វើសុខដុមនីយកម្មកិច្ចគាំពារសង្គមនៅកម្ពុជាឱ្យកាន់តែប្រសើរឡើង និងដើម្បីត្រៀមឆ្លើយតបនឹងគ្រោះអាសន្ន។

ការរៀបចំឯកសារក្របខណ្ឌនេះ ទទួលបានកិច្ចសហការយ៉ាងជិតស្និតពីសំណាក់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងភាពជាម្ចាស់។ ផ្អែកលើការខិតខំរបស់គ្រប់ភាគីពាក់ព័ន្ធ, **"ក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន"** ត្រូវបានរៀបចំបានគ្រប់ជ្រុងជ្រោយ និងទទួលការឯកភាពពីក្រុមប្រឹក្សាជាតិគាំពារសង្គម ក្នុងកិច្ចប្រជុំលើកទី៩ កាលពីថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣ និងទទួលបានការអនុញ្ញាតដាក់ឱ្យអនុវត្តពីរាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដែលដឹកនាំដ៏ខ្ពង់ខ្ពស់ដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

ក្រុមប្រឹក្សាជាតិគាំពារសង្គម សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងសុខាភិបាល, ក្រសួងផែនការ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ចំពោះការផ្តល់ធាតុចូល និងការគាំទ្រនាពេលកន្លងមក។

ក្រុមប្រឹក្សាជាតិគាំពារសង្គម ក៏សូមថ្លែងអំណរគុណផងដែរដល់កម្មវិធីស្បៀងអាហារពិភពលោក (WFP) ចំពោះជំនួយបច្ចេកទេស និងការគាំទ្រដំណើរនៃការរៀបចំក្របខណ្ឌនេះ។ បន្ថែមលើនេះ ក្រុមប្រឹក្សាជាតិគាំពារសង្គម ក៏សូមថ្លែងអំណរគុណចំពោះការជ្រោមជ្រែងយ៉ាងពេញទំហឹងពីសំណាក់ដៃគូអភិវឌ្ឍន៍ និងសហគមន៍មនុស្សធម៌ពាក់ព័ន្ធ ដូចជាមូលនិធិសហប្រជាជាតិដើម្បីកុមារ (UNICEF), អង្គការស្បៀង និងកសិកម្មសហប្រជាជាតិ (FAO), អង្គការសុខភាពពិភពលោក (WHO), អង្គការអន្តរជាតិខាងការងារ (ILO), កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP), ការិយាល័យអ្នកសម្របសម្រួលរបស់អង្គការសហប្រជាជាតិ ប្រចាំព្រះរាជាណាចក្រកម្ពុជា (UNRC), អង្គការទស្សនៈពិភពលោក (World Vision), អង្គការសង្គ្រោះកុមារ (Save the Children), អង្គការ Oxfam, អង្គការ People in Need, ធនាគារអភិវឌ្ឍន៍អាស៊ី (ADB), ទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់ការអភិវឌ្ឍអន្តរជាតិ (GIZ), ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID), ធនាគារពិភពលោក (World Bank) និងធនាគារ វីង (ខេមបូឌា) ម.ក, នាយកដ្ឋានកិច្ចគាំពារពលរដ្ឋ និងប្រតិបត្តិការជំនួយមនុស្សធម៌របស់សហភាពអឺរ៉ុប (ECHO), អង្គការ Dan Church Aid (DCA) ចំពោះការផ្តល់កិច្ចគាំទ្រ និងកិច្ចសហការក្នុងដំណើរការរៀបចំដែលធ្វើឱ្យក្របខណ្ឌនេះមានភាពគ្រប់ជ្រុងជ្រោយ និងលេចចេញជារូបរាងឡើង។

ថ្ងៃ ចន្ទ ១១រោច ខែ ស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# ខ្លឹមសារសង្ខេបប្រតិបត្តិ

"គោលការណ៍ណែនាំស្តីពីក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន" ត្រូវបានរៀបចំឡើងអនុលោមតាមក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ដោយសំដៅរួមចំណែកក្នុងការសម្រេចបាននូវគោលដៅក្នុងការធានាសន្តិសុខប្រាក់ចំណូល និងកាត់បន្ថយភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ពលរដ្ឋ ព្រមទាំងរួមចំណែកកាត់បន្ថយភាពក្រីក្រជាអតិបរមា។

បំពេញបន្ថែមលើវិធានការឆ្លើយតបនឹងការជួយសង្គ្រោះបន្ទាន់ភ្លាមៗ ដែលមានស្រាប់របស់រាជរដ្ឋាភិបាល, ក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ជាគំនិតផ្តួចផ្តើមក្នុងការប្រើប្រាស់ប្រព័ន្ធគាំពារសង្គម ដើម្បីផ្តល់កិច្ចគាំពារដែលមានលក្ខណៈជាប្រព័ន្ធ, អាចព្យាករទុកមុន, ទាន់ពេល និងមានប្រសិទ្ធភាព ជូនដល់ពលរដ្ឋ ពិសេសគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ដើម្បីឆ្លើយតបនឹង **គ្រោះអាសន្នធម្មជាតិ, វិបត្តិម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងវិបត្តិសុខភាពសាធារណៈ** ទាំងក្នុងអំឡុងពេលគ្រោះអាសន្នដើម្បីរក្សាលំនឹងជីវភាព និងក្រោយគ្រោះអាសន្នដើម្បីស្តារជីវភាពឡើងវិញ តាមរយៈ (១) ការដាក់ចេញនូវបណ្តុំវិធានការអន្តរាគមន៍ជាក់លាក់ដោយប្រើប្រាស់ប្រព័ន្ធទិន្នន័យ និងយន្តការបើកផ្តល់ដែលមានស្រាប់ តាមលំដាប់លំដោយ និងអាចពង្រីកវិសាលភាពគ្របដណ្តប់ ដើម្បីផ្តល់កិច្ចគាំទ្រដល់គ្រួសារ ដែលទទួលរងផលប៉ះពាល់ដោយគ្រោះអាសន្ន ឱ្យបានទាន់ពេលក្នុងការដោះស្រាយបញ្ហាជីវភាព និងទប់ស្កាត់ការធ្លាក់កាន់តែជ្រៅក្នុងភាពក្រីក្រ, (២) ការបង្កើតយន្តការសម្របសម្រួលដែលមានភាពប្រទាក់ក្រឡាគ្នា រវាងវិធានការអន្តរាគមន៍ និងវិធានការផ្សេងទៀត ដែលបានដាក់ចេញដោយស្ថាប័នមានសមត្ថកិច្ច និងស្ថាប័នមនុស្សធម៌ ដូចជាគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងកាកបាទក្រហមកម្ពុជាជាដើម សម្រាប់ឆ្លើយតបនឹងគ្រោះអាសន្ន តាមរយៈការធ្វើសុខដុមនីយកម្មយន្តការអនុវត្តកម្មវិធីដើម្បីបំពេញគ្នា ប្រកបដោយប្រសិទ្ធភាព។

ក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ចែកចេញជា ៦ផ្នែក ដូចខាងក្រោម៖

១. សេចក្តីផ្តើម ពិពណ៌នាអំពីភាពងាយរងនូវគ្រោះអាសន្ននៅកម្ពុជា, តួនាទីប្រព័ន្ធគាំពារសង្គមក្នុងការឆ្លើយតបនឹងគ្រោះអាសន្ន និងភាពចាំបាច់នៃកិច្ចគាំពារសង្គមក្នុងការឆ្លើយតបនឹងគ្រោះអាសន្ន។

២. ទស្សនាទានរួម ពិពណ៌នាអំពីគោលបំណង និងអភិក្រមរួម សម្រាប់ការរៀបចំក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន។

៣. ជម្រើសឧបករណ៍គោលនយោបាយគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ពិពណ៌នាអំពីជម្រើសឧបករណ៍គោលនយោបាយ ដែលអាចដាក់ចេញដើម្បីឆ្លើយតបនឹងគ្រោះអាសន្ន ដូចជាការកែសម្រួលយន្តការអនុវត្តកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមដែលមានស្រាប់, ការពង្រីកវិសាលភាពគ្របដណ្តប់កិច្ចគាំពារសង្គមតាមខ្សែបញ្ឈរ, ការពង្រីកវិសាលភាពគ្របដណ្តប់កិច្ចគាំពារសង្គមទៅដល់គ្រួសារថ្មីៗ ដែលរងផលប៉ះពាល់ដោយគ្រោះអាសន្ន, ការបំពេញតម្រូវការចាំបាច់ថ្មីៗ តាមរយៈការផ្សារភ្ជាប់កម្មវិធីជំនួយសាច់ប្រាក់បន្ទាន់ ក្នុងគ្រាអាសន្នរបស់ស្ថាប័នមនុស្សធម៌ទៅនឹងប្រព័ន្ធគាំពារសង្គម និងជម្រើសដែលត្រូវពិចារណាសម្រាប់អនាគត។

៤. **ភូមិសាស្ត្រអាទិភាព ដែលត្រូវដាក់វិធានការ និងសូចនាករប្រកាសអាសន្ន** ពិពណ៌នាអំពីការកំណត់ការឆ្លើយតបដែលមានលក្ខណៈខុសៗគ្នា ទៅតាមទីតាំងភូមិសាស្ត្រដែលរងផលប៉ះពាល់ទៅតាមប្រភេទនៃគ្រោះអាសន្ន ដូចជាគ្រោះធម្មជាតិ (គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត), វិបត្តិម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងវិបត្តិសុខភាពសាធារណៈជាដើម ព្រមទាំងពិពណ៌នាអំពីសូចនាករ ដែលកំណត់កម្រិតភាពធ្ងន់ធ្ងរនៃគ្រោះទឹកជំនន់នៅកម្ពុជា។

៥. **សកម្មភាពអាទិភាព** ពិពណ៌នាអំពីការរៀបចំក្របខណ្ឌគោលនយោបាយ និងស្ថាប័ន, ការរៀបចំយន្តការអនុវត្ត, ប្រព័ន្ធបើកផ្តល់, ប្រព័ន្ធទិន្នន័យ និងព័ត៌មាន និងយន្តការហិរញ្ញប្បទានសម្រាប់សកម្មភាពជាអាទិភាព ក្នុងការឆ្លើយតបនឹងគ្រោះអាសន្នក្នុងក្របខណ្ឌគាំពារសង្គម។

៦. **តួនាទី និងយន្តការសម្របសម្រួលរវាងក្រសួង-ស្ថាប័ន** ពិពណ៌នាអំពីតួនាទី និងការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន និងយន្តការសម្របសម្រួលសម្រាប់កិច្ចគាំពារសង្គមដើម្បីឆ្លើយតបនឹងគ្រោះអាសន្ន។

## ១. សេចក្តីផ្តើម

ជាមួយនឹងការប្រែប្រួលអាកាសធាតុនៅលើពិភពលោក ក៏ដូចជានៅក្នុងតំបន់ក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ, ព្រះរាជាណាចក្រកម្ពុជាក៏រងផលប៉ះពាល់ដោយផ្ទាល់ និងបានក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលរងគ្រោះមហន្តរាយជាញឹកញាប់ និងមានភាពធ្ងន់ធ្ងរ ដែលគ្រោះមហន្តរាយទាំងនោះ រួមមានគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់កន្រ្តាក់ ខ្យល់ព្យុះជាដើម។ ការត្រៀមបង្ការ និងកាត់បន្ថយគ្រោះថ្នាក់ពីគ្រោះមហន្តរាយត្រូវបានធ្វើឡើងដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយយ៉ាងសមស្រប ដើម្បីឆ្លើយតប និងជួយសហគមន៍មូលដ្ឋាន និងពលរដ្ឋឱ្យបានទាន់ពេល។ ក្នុងករណីមានគ្រោះមហន្តរាយ, គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ជាស្ថាប័នដឹកនាំ និងចាត់វិធានការឆ្លើយតបបន្ទាន់ ដោយបញ្ជារាល់ប្រតិបត្តិការជួយសង្គ្រោះបន្ទាន់, ត្រួតពិនិត្យតាមដានលើគ្រោះមហន្តរាយ និងធ្វើការទប់ស្កាត់ការរីករាលដាលនៃមុខសញ្ញាគ្រោះថ្នាក់ និងកៀរគរធនធានជាតិ និងជំនួយមនុស្សធម៌ ដើម្បីជួយជនរងគ្រោះ។ សកម្មភាពឆ្លើយតបបន្ទាន់ទាំងនេះ ផ្តោតលើការជួយសង្គ្រោះសហគមន៍ និងពលរដ្ឋ ដែលប្រឈមខ្ពស់នឹងគ្រោះថ្នាក់ ដោយកម្លាំង និងមធ្យោបាយសរុបរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ រួមទាំងកងកម្លាំងប្រដាប់អាវុធ, គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, អង្គការជំនួយមនុស្សធម៌ក្នុងស្រុក និងអន្តរជាតិ, និងកាកបាទក្រហមកម្ពុជា ក៏ដូចជាពង្រឹកទំនាក់ទំនងដល់សហគមន៍ម្ចាស់ជំនួយផងដែរ។

បន្ថែមលើការឆ្លើយតបនឹងការសង្គ្រោះបន្ទាន់នេះ, ប្រព័ន្ធគាំពារសង្គម តាមរយៈកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម មានសក្តានុពលក្នុងការគាំទ្របន្ថែមដល់ពលរដ្ឋដែលទទួលរងផលប៉ះពាល់ពីគ្រោះអាសន្ន ទាំងក្នុងអំឡុងពេលគ្រោះអាសន្នដើម្បីរក្សាលំនឹងជីវភាព និងក្រោយគ្រោះអាសន្នដើម្បីស្តារជីវភាពឡើងវិញ ដូចធ្លាប់បានអនុវត្តកន្លងមក ទាំងក្នុងការឆ្លើយតបនឹងជំងឺកូវីដ-១៩, សម្ពាធអតិផរណា និងគ្រោះទឹកជំនន់ ជាដើម។ ក្នុងន័យនេះ និងជាការបំពេញបន្ថែមលើកិច្ចខិតខំឆ្លើយតបនឹងគ្រោះអាសន្នពីសំណាក់រាជរដ្ឋាភិបាល ក្នុងការសង្គ្រោះបន្ទាន់ផង, **ក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន** ដែលជាការធ្វើស្ថាប័នូបនីយកម្មការឆ្លើយតបនឹងគ្រោះអាសន្នដោយប្រព័ន្ធគាំពារសង្គម ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តដោយគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល នាពេលនេះ។

### ១.១ ភាពងាយរងគ្រោះអាសន្ននៅកម្ពុជា

ចាប់ពីឆ្នាំ២០០០ ដល់ឆ្នាំ២០១៥, ពលរដ្ឋប្រមាណជាង ២០០ លាននាក់ នៅតំបន់អាស៊ីអាគ្នេយ៍ បានរងផលប៉ះពាល់ដោយគ្រោះមហន្តរាយធម្មជាតិ ដោយសារតែកត្តាប្រែប្រួលអាកាសធាតុដែលបណ្តាលឱ្យមានគ្រោះទឹកជំនន់ជារៀងរាល់ឆ្នាំ។ ជាមួយគ្នានេះ គ្រោះរាំងស្ងួតក៏បានកើតមានឡើងជាញឹកញាប់ និងកាន់តែធ្ងន់ធ្ងរទៅ។ ជាងពីរទសវត្សរ៍ចុងក្រោយនេះ តំបន់អាស៊ីអាគ្នេយ៍ទាំងមូលក៏បានរងឥទ្ធិពលពីវិបត្តិម៉ាក្រូសេដ្ឋកិច្ច រួមមានវិបត្តិហិរញ្ញវត្ថុអាស៊ីនៅឆ្នាំ១៩៩៧, វិបត្តិហិរញ្ញវត្ថុសកលនៅឆ្នាំ២០០៧-២០០៨ និងផលជះអវិជ្ជមានលើសង្គម-សេដ្ឋកិច្ច ក្នុងរយៈពេលប្រមាណ ៣ឆ្នាំចុងក្រោយ ដែលបណ្តាលមកពីការរាតត្បាតនៃជំងឺកូវីដ-១៩។

ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងមកនេះ, កម្ពុជាបានក្លាយជាប្រទេសមួយដែលស្ថិតនៅក្នុងតំបន់ងាយរងផលប៉ះពាល់ពីគ្រោះមហន្តរាយធម្មជាតិផ្សេងៗ ដែលនាំឱ្យពលរដ្ឋងាយប្រឈមនឹងគ្រោះអាសន្នធម្មជាតិនានា ដូចជាគ្រោះទឹកជំនន់, គ្រោះរាំងស្ងួត និងខ្យល់ព្យុះជាដើម។ តួយ៉ាងគ្រោះរាំងស្ងួតនៅក្នុងឆ្នាំ២០១៦ បានបង្កផលប៉ះពាល់ដល់ពលរដ្ឋប្រមាណ ២,៥ លាននាក់ និងគ្រោះជំនន់នៅក្នុងឆ្នាំ២០២០ បានបង្កផលប៉ះពាល់ដល់ពលរដ្ឋប្រមាណជាង ៨០៩ ៦០០ នាក់។ គ្រោះអាសន្នទាំងនេះ បានជះឥទ្ធិពលដោយផ្ទាល់លើប្រាក់ចំណូល, ជីវភាពរស់នៅ, សន្តិសុខស្បៀង, បំណុល និងសមត្ថភាពរបស់គ្រួសារនីមួយៗ ក្នុងការទទួលបានសេវាសង្គមនានា ជាពិសេសគ្រួសារក្រីក្រ និងជនងាយរងគ្រោះ រួមមានស្ត្រី, កុមារតូច, ជនមានពិការភាព និងជនចាស់ជរា ជាក្រុមដែលស្ថិតនៅក្នុងចំណោមក្រុមពលរដ្ឋងាយរងគ្រោះបំផុត ដោយសារគ្រោះអាសន្នបានរុញច្រានពួកគាត់ឱ្យធ្លាក់ចូលកាន់តែជ្រៅក្នុងភាពក្រីក្រ។ ទន្ទឹមនេះ ពលរដ្ឋរស់នៅក្បែរបន្ទាត់នៃភាពក្រីក្រមួយភាគធំ គឺពលរដ្ឋក្រុមទី២ (Quintile 2) និងពលរដ្ឋក្រុមទី៣ (Quintile 3) នៃស្រទាប់ដែលមានប្រាក់ចំណូលមានប្រមាណ ២០ដុល្លារ ក្នុងមួយនាក់ ក្នុងមួយខែ និងដែលងាយធ្លាក់ចូលក្នុងភាពក្រីក្រ ដោយសារតែគ្រោះអាសន្ន។ ដោយគ្មានជម្រើសសមស្របក្នុងការដោះស្រាយបញ្ហាជីវភាព, គ្រួសារនីមួយៗអាចជ្រើសរើសមធ្យោបាយក្នុងការឆ្លើយតបនឹងគ្រោះអាសន្នចំពោះមុខ តាមរយៈការកាត់បន្ថយរបបអាហារ, បញ្ឈប់ការសិក្សារបស់កូន ឬលក់សម្ភារៈ និងឧបករណ៍ផលិតកម្ម ជាដើម។ ប៉ុន្តែជម្រើសនេះ នឹងកាន់តែបង្កើនភាពងាយរងគ្រោះ, ធ្លាក់ចូលកាន់តែជ្រៅក្នុងភាពក្រីក្រ និងប្រឈមនឹងផលវិបាកនៅអនាគត។ ទន្ទឹមនេះ ផលប៉ះពាល់នៃគ្រោះអាសន្នផ្ទួនៗ បង្កការគំរាមកំហែងដល់ការអភិវឌ្ឍប្រកបដោយចីរភាពរបស់កម្ពុជា និងកិច្ចខិតខំរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ដែលនាំឱ្យការកសាងភាពធន់ដើម្បីកាត់បន្ថយផលប៉ះពាល់នៃគ្រោះអាសន្នលើពលរដ្ឋងាយរងគ្រោះ ក្លាយជាកិច្ចការអាទិភាពមួយរបស់រាជរដ្ឋាភិបាលកម្ពុជា។

## ១.២ តួនាទីកិច្ចគាំពារសង្គមក្នុងការឆ្លើយតបនឹងគ្រោះអាសន្ន

មុខងារស្នូលនៃប្រព័ន្ធគាំពារសង្គម គឺដើម្បីផ្តល់ការគាំទ្រដល់ពលរដ្ឋ ក្នុងការទប់ទល់នឹងហានិភ័យ និងភាពងាយរងគ្រោះ រួមទាំងគ្រោះអាសន្នដែលកើតឡើងចំពោះបុគ្គល **"នៅកម្រិតគ្រួសារ"** ដែលរមែងកើតមានក្នុងវដ្តជីវិត។ កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្នសំដៅដល់ការប្រើប្រាស់ប្រព័ន្ធគាំពារសង្គមដើម្បីកាត់បន្ថយភាពរងឥទ្ធិពលជាលក្ខណៈទ្រង់ទ្រាយធំ ឬឥទ្ធិពលនៃគ្រោះមហន្តរាយនានា ដែលបង្កផលប៉ះពាល់ដល់សហគមន៍, ថ្នាក់តំបន់ ឬថ្នាក់ជាតិទាំងមូល។ បទពិសោធន៍ពីប្រទេសជាច្រើនបានបង្ហាញថា កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្នមានគុណតម្លៃសម្រាប់ផ្តល់ជំនួយបានទាន់ពេល និងមានប្រសិទ្ធភាព ដល់ពលរដ្ឋដែលទទួលរងផលប៉ះពាល់, ការស្តារជីវភាពឡើងវិញឱ្យបានកាន់តែប្រសើរនៅក្រោយពេលគ្រោះអាសន្ន និងកសាងសមត្ថភាពរបស់ពួកគាត់ក្នុងការទប់ទល់នឹងបញ្ហាជីវភាព នៅពេលមានគ្រោះអាសន្នណាមួយកើតឡើង។

សក្តានុពលនៃកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន មានដូចជា៖ (ក) វត្តមាននៃប្រព័ន្ធគាំពារសង្គមដែលមានភាពធន់ដែលអាចបន្តបំពេញមុខងារ និងផ្តល់ការគាំពារជាប្រចាំ ក្នុងពេលមានគ្រោះអាសន្ន, (ខ) ការរៀបចំយន្តការអនុវត្ត ដើម្បីបំពេញតម្រូវការចាំបាច់ជាមូលដ្ឋានថ្មីៗ ដែលកើតឡើងនៅពេលមានគ្រោះអាសន្ន និង (គ) ការទាញប្រយោជន៍ពីប្រព័ន្ធ និងទិន្នន័យគាំពារសង្គម

ដែលមានស្រាប់។ ការណ៍នេះ នឹងផ្តល់ឱ្យគ្រួសារនីមួយៗ នូវភាពធន់កាន់តែប្រសើរ តាមរយៈការផ្តល់កិច្ចគាំទ្រជាមធ្យោបាយ និងលទ្ធភាពដោះស្រាយបញ្ហាជីវភាព និងការស្តារជីវភាពឡើងវិញ ទាំងក្នុងអំឡុងពេល និងបន្ទាប់ពីពេលរងផលប៉ះពាល់ដោយគ្រោះអាសន្ន។ ជាមួយគ្នានេះ កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ក៏អាចពន្លឿនការងារ និងកាត់បន្ថយបន្ទុកចំណាយក្នុងវិធានការឆ្លើយតប ព្រមទាំងកាត់បន្ថយភាពរាយប៉ាយ និងពង្រឹងយន្តការសម្របសម្រួលសម្រាប់ការផ្តល់ជំនួយបន្ទាន់ក្នុងគ្រាអាសន្នដល់គ្រួសាររងគ្រោះ ប្រកបដោយប្រសិទ្ធភាព និងបរិយាបន្ន។ សក្តានុពលនៃកិច្ចគាំពារសង្គមត្រូវបានបង្ហាញយ៉ាងច្បាស់ ក្នុងការឆ្លើយតបជាសាកលនឹងការរាតត្បាតនៃជំងឺកូវីដ-១៩ ដែលក្នុងនោះ ប្រទេសចំនួន ២១៥ បានដាក់ចេញផែនការ ឬវិធានការគាំពារសង្គមដើម្បីឆ្លើយតបនឹងការរាតត្បាតនេះ។

ប្រព័ន្ធគាំពារសង្គមត្រូវបានប្រើប្រាស់ដើម្បីឆ្លើយតបនឹងគ្រោះអាសន្ន តាមវិធីសាស្ត្រចម្រុះជាច្រើន ដូចបានបង្ហាញក្នុង **រូបភាពទី១**។

## រូបភាពទី១៖ វិធីសាស្ត្រដែលប្រព័ន្ធគាំពារសង្គមគាំទ្រដល់ការឆ្លើយតបនឹងគ្រោះអាសន្ន




### ១.៣ ភាពចាំបាច់នៃកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ននៅកម្ពុជា

បន្ថែមលើគ្រោះអាសន្ននាពេលកន្លងមក, វិបត្តិ និងគ្រោះអាសន្នដែលបានកើតឡើងក្នុងឆ្នាំ ២០២០ ដែលរួមមានការរាតត្បាតនៃជំងឺកូវីដ-១៩, គ្រោះទឹកជំនន់ និងការវិលត្រលប់នៃពលករចំណាកស្រុក ក៏ដូចជាសម្ពាធសេដ្ឋកិច្ចដែលនាំឱ្យមានអតិផរណាខ្ពស់ ដោយសារជម្លោះរវាងរុស្ស៊ី និងអ៊ុយក្រែន និងគ្រោះទឹកជំនន់ធ្ងន់ធ្ងរដែលកើតឡើងក្នុងឆ្នាំ២០២២ បានឆ្លុះបញ្ចាំងអំពីភាពចាំបាច់នៃកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ននៅកម្ពុជា។ វិបត្តិជំងឺកូវីដ-១៩, សម្ពាធអតិផរណា និងគ្រោះទឹកជំនន់ បានសបញ្ជាក់អំពីសារៈសំខាន់នៃកិច្ចគាំពារសង្គម ដូចជាការដាក់ឱ្យអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដើម្បីជួយដល់ពលរដ្ឋក្នុងការដោះស្រាយបញ្ហាជីវភាព ក្នុងអំឡុងពេលគ្រោះអាសន្ន និងការអនុវត្តកម្មវិធីសាច់ប្រាក់ពលកម្មជាដើម។ បទពិសោធន៍របស់ក្រុមប្រឹក្សាជាតិគាំពារសង្គម

ក្នុងការដឹកនាំការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានបង្ហាញថា ទោះបីជាប្រព័ន្ធគាំពារសង្គមនៅកម្ពុជានៅកំពុងត្រូវបានអភិវឌ្ឍក៏ប្រព័ន្ធនេះមានសក្តានុពលធំក្នុងការបំពេញតម្រូវការជាមូលដ្ឋានរបស់ពលរដ្ឋក្រីក្រ ដែលរងផលប៉ះពាល់ដោយគ្រោះអាសន្ន ព្រមទាំងបង្កើតឱ្យមានយន្តការបំពេញបន្ថែមលើកិច្ចខិតខំដែលមានស្រាប់របស់រាជរដ្ឋាភិបាល ក្នុងការឆ្លើយតបនឹងគ្រោះមហន្តរាយ។ ទន្ទឹមនេះ ការឆ្លើយតបនឹងគ្រោះទឹកជំនន់ក្នុងឆ្នាំ២០២០ បានឆ្លុះបញ្ចាំងពីភាពចាំបាច់នៃកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ក្នុងការជំរុញកិច្ចសម្របសម្រួលឱ្យកាន់តែប្រសើរ ដើម្បីផ្តល់ជំនួយបន្ទាន់ដល់គ្រួសារដែលរងឥទ្ធិពលពីគ្រោះអាសន្ន។ ជាមួយគ្នានេះ ក្នុងវិបត្តិនៃគ្រោះទឹកជំនន់នេះ សហគមន៍មនុស្សធម៌នានា ដូចជាវេទិកាឆ្លើយតបផ្នែកមនុស្សធម៌កម្ពុជា (HRF) បានរៀបចំយន្តការអនុវត្តកម្មវិធីជំនួយសាច់ប្រាក់បន្ទាន់ ឱ្យមានលក្ខណៈសមស្រប និងបំពេញបន្ថែមលើកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ នៅក្នុងតំបន់ដែលទទួលរងផលប៉ះពាល់ដោយគ្រោះទឹកជំនន់។ បទពិសោធន៍របស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ក្នុងការដឹកនាំដាក់ឱ្យអនុវត្តកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ ជូនគ្រួសារងាយរងហានិភ័យដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា ដើម្បីឆ្លើយតបនឹងគ្រោះអាសន្នផ្ទួនៗពីសម្ពាធអតិផរណា និងគ្រោះទឹកជំនន់ក្នុងឆ្នាំ២០២២ ក៏បានបង្ហាញពីសក្តានុពលនៃប្រព័ន្ធគាំពារសង្គមក្នុងការពង្រីកវិសាលភាពគ្របដណ្តប់លើក្រុមគោលដៅថ្មី គឺគ្រួសារងាយរងហានិភ័យ ដែលរស់នៅក្បែរបន្ទាត់ភាពក្រីក្រ នៅពេលមានគ្រោះអាសន្ន ព្រមគ្នាជាមួយបទពិសោធន៍នៃការសម្របសម្រួលជាមួយក្រសួង-ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកំណត់ភូមិសាស្ត្រគោលដៅជាក់លាក់ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរ និងកំណត់អត្តសញ្ញាណគ្រួសារគោលដៅ បានទាន់ពេល។

ជាទិសដៅបន្ត, ការប្រើប្រាស់ប្រព័ន្ធគាំពារសង្គមសម្រាប់ឆ្លើយតបនឹងគ្រោះអាសន្ន នឹងបំពេញបន្ថែម និងជួយសម្រួលដល់ការធ្វើសុខដុមនីយកម្ម និងកិច្ចសហការដែលមានលក្ខណៈរួមគ្នារវាងក្រសួង-ស្ថាប័ន ព្រមទាំងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ដែលដឹកនាំអនុវត្តវិធានការឆ្លើយតបនៅពេលមានគ្រោះអាសន្នកើតឡើង។ ប្រព័ន្ធគាំពារសង្គមដែលអាចគ្របដណ្តប់ទៅដល់ពលរដ្ឋដែលមានតម្រូវការ និងអាចពង្រីកវិសាលភាពគ្របដណ្តប់យ៉ាងឆាប់រហ័ស មានសក្តានុពលក្នុងការកាត់បន្ថយផលប៉ះពាល់ពីគ្រោះអាសន្ន និងរួមចំណែកដល់ការសន្សំថវិកាជាតិ ក៏ដូចជាការកសាងភាពធន់ និងការកាត់បន្ថយផលប៉ះពាល់ទៅលើពលរដ្ឋងាយរងគ្រោះជាដើម។ ការវិនិយោគលើកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន នឹងរួមចំណែកក្នុងការពង្រឹងប្រព័ន្ធគាំពារសង្គម ដែលនឹងធ្វើឱ្យប្រសើរឡើងនូវកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមដែលមានស្រាប់។ ជាមួយគ្នានេះ កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន នឹងបំពេញបន្ថែមយ៉ាងសំខាន់ លើកិច្ចខិតខំរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍប្រកបដោយចីរភាព, កាត់បន្ថយភាពក្រីក្រ និងភាពងាយរងគ្រោះ, អសន្តិសុខស្បៀង និងពង្រឹងភាពធន់រយៈពេលវែងសម្រាប់គ្រួសារនីមួយៗ ផងដែរ។

## ២. ទស្សនាទានរួម

**"ក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន"** ត្រូវបានរៀបចំឡើងអនុលោមតាមក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ សំដៅរួមចំណែកក្នុងការសម្រេចបាននូវគោលដៅក្នុងការធានានូវសន្តិសុខប្រាក់ចំណូល និងកាត់បន្ថយភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ពលរដ្ឋ ព្រមទាំងកាត់បន្ថយភាពក្រីក្រជាអតិបរមា។ ទន្ទឹមនេះ ក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ក៏ត្រូវបានចាត់ទុកជាវិធានការគោលនយោបាយគន្លឹះ ក្នុងក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ ២០២១-២០២៣ ផងដែរ។

### ២.១ គោលបំណង

**"ក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន"** មានគោលបំណងគាំទ្រការប្រើប្រាស់ប្រព័ន្ធគាំពារសង្គមក្នុងការផ្តល់កិច្ចគាំពារដែលមានលក្ខណៈជាប្រព័ន្ធ, អាចព្យាករទុកមុន, ទាន់ពេល, និងមានប្រសិទ្ធភាពខ្ពស់ ជូនពលរដ្ឋ ជាពិសេសពលរដ្ឋក្រីក្រ និងងាយរងគ្រោះ ដើម្បីឆ្លើយតបនឹង **គ្រោះអាសន្នធម្មជាតិ, វិបត្តិម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងវិបត្តិសុខភាពសាធារណៈ** ទាំងក្នុងអំឡុងពេលគ្រោះអាសន្ន ដើម្បីរក្សាលំនឹងជីវភាព និងក្រោយគ្រោះអាសន្ន ដើម្បីស្តារជីវភាពឡើងវិញ តាមរយៈ៖

**ក.** ការដាក់ចេញនូវបណ្តុំនៃវិធានការអន្តរាគមន៍ជាក់លាក់ ដោយប្រើប្រាស់ប្រព័ន្ធទិន្នន័យ យន្តការបើកផ្តល់ និងយន្តការផ្សេងៗដែលមានស្រាប់ ដោយរៀបចំតាមលំដាប់លំដោយ និងអាចពង្រីកវិសាលភាពគ្របដណ្តប់ ដើម្បីផ្តល់កិច្ចគាំទ្រដល់គ្រួសារដែលរងផលប៉ះពាល់ដោយគ្រោះអាសន្នបានទាន់ពេល និងទប់ស្កាត់គ្រួសារទាំងនោះពីការប្រើប្រាស់យុទ្ធសាស្ត្រអវិជ្ជមានសម្រាប់ដោះស្រាយបញ្ហាជីវភាព និងកុំឱ្យធ្លាក់កាន់តែជ្រៅក្នុងភាពក្រីក្រ។

**ខ.** ការបង្កើតឱ្យមានយន្តការសម្របសម្រួល និងភាពប្រទាក់ក្រឡាគ្នារវាងវិធានការអន្តរាគមន៍ និងវិធានការនានា សម្រាប់ឆ្លើយតបនឹងគ្រោះអាសន្ន ដែលបានដាក់ចេញដោយស្ថាប័នមានសមត្ថកិច្ច និងស្ថាប័នមនុស្សធម៌ ដូចជាគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ, កាកបាទក្រហមកម្ពុជា និងស្ថាប័នមនុស្សធម៌នានា តាមរយៈការធ្វើសុខដុមនីយកម្មយន្តការអនុវត្តកម្មវិធី និងការប្រើប្រាស់ប្រព័ន្ធរួមដើម្បីបំពេញភាពខ្វះចន្លោះប្រកបដោយប្រសិទ្ធភាព។

### ២.២ អភិក្រមនៃក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ននៅកម្ពុជា

ជម្រើសឧបករណ៍គោលនយោបាយ សម្រាប់ជាវិធានការឆ្លើយតប ក្នុងក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន មានការចូលរួមជាធាតុចូល, គំនិត, និងទស្សនៈពីក្រសួង-ស្ថាប័នដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ និងបណ្តាសហគមន៍មនុស្សធម៌ ដោយផ្អែកលើការវិភាគយ៉ាងលម្អិតលើស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ ក៏ដូចជាមេរៀន និងបទពិសោធន៍របស់ប្រទេសកម្ពុជាក្នុងការគ្រប់គ្រងវិបត្តិ, កត្តាអំណោយផល, កត្តារាំងស្ទះ និងអាទិភាពគោលនយោបាយសម្រាប់ពេលអនាគត។ រាល់ជម្រើសឧបករណ៍គោលនយោបាយដែលមានលក្ខណៈសមស្របសម្រាប់ឆ្លើយតបនឹងគ្រោះអាសន្នក្នុងក្របខណ្ឌនេះ ត្រូវបានវិភាគដោយរួមបញ្ចូលនូវប្រព័ន្ធ

សន្តិសុខសង្គម និងប្រព័ន្ធជំនួយសង្គម ព្រមទាំងវាយតម្លៃអំពីគុណសម្បត្តិ និងគុណវិបត្តិនៃជម្រើសឧបករណ៍គោលនយោបាយនីមួយៗ។ ការរៀបចំក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្នឈរលើអភិក្រមដូចមានខាងក្រោម៖

- **ភាពសាមញ្ញ៖** បទពិសោធន៍ជាសាកល បានបង្ហាញអំពីគុណតម្លៃក្នុងការរៀបចំក្របខណ្ឌ ឬប្រព័ន្ធ មិនមានភាពស្មុគស្មាញ និងផ្តោតអាទិភាពលើសមាសធាតុតូចៗ ក្នុងវិធានការអន្តរាគមន៍ ឬកម្មវិធីជាច់ៗពីគ្នា។ ការដាក់ឱ្យអនុវត្តកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម គួររៀបចំយន្តការអនុវត្តឱ្យមានលក្ខណៈស្របនឹងគោលការណ៍មួយចំនួន ដូចជាការកំណត់ទំហំអត្ថប្រយោជន៍, និងការកំណត់ក្រុមគោលដៅ ចៀសវាងភាពស្មុគស្មាញ និងបែបបទច្រើន។ ការណ៍នេះ មានសារៈសំខាន់ណាស់សម្រាប់កម្ពុជា ដែលប្រព័ន្ធគាំពារសង្គមកំពុងស្ថិតក្នុងដំណាក់កាលកំពុងអភិវឌ្ឍ។
- **ភាពអាចបត់បែន៖** ក្របខណ្ឌនេះ ផ្តល់លទ្ធភាពក្នុងការសម្របខ្លួនទៅតាមស្ថានភាពខុសៗគ្នាសម្រាប់ទទួលយកការចង្អុលបង្ហាញ ឬការតម្រង់ទិសនានា ដែលជាលទ្ធផលនៃការវិវឌ្ឍរបស់ប្រព័ន្ធគាំពារសង្គមក្នុងរយៈពេលវែង និងប្រព័ន្ធប្រកាសអាសន្ន សម្រាប់អនុវត្តវិធានការឱ្យបានទាន់ពេល។ ក្របខណ្ឌនេះ ត្រូវឆ្លើយតបនឹងលក្ខខណ្ឌ និងបរិបទខុសៗគ្នានៃគ្រោះអាសន្ន ដោយគិតគូរលើទិសដៅអនាគតរបស់ប្រព័ន្ធ និងចៀសវាងការកំណត់ជាក់លាក់ទៅលើចំណុចមួយចំនួន ដូចជាទំហំអត្ថប្រយោជន៍ កម្រិតវាស់វែង និងសូចនាករប្រកាសអាសន្ន ឬដំណើរការប្រតិបត្តិការ។
- **មូលដ្ឋានរឹងមាំ៖** ប្រព័ន្ធគាំពារសង្គម ដែលមានលក្ខណៈរឹងមាំ និងលក្ខខណ្ឌល្អប្រសើរ ជាប្រព័ន្ធដែលមានបទដ្ឋាន និងការទទួលស្គាល់ជាពិសេស ដែលមានវិសាលភាពអាចគ្របដណ្តប់ទៅលើពលរដ្ឋ, តម្រូវការចាំបាច់ជាមូលដ្ឋាន, ភាពងាយរងគ្រោះដែលមានក្នុងដំណាក់កាលនីមួយៗនៃវដ្តជីវិត និងការឧបត្ថម្ភគាំទ្រសមស្រប ព្រមទាំងការអនុវត្តតាមរយៈប្រព័ន្ធ និងយន្តការស្ថាប័នដែលមានលក្ខណៈរឹងមាំ និងមានគណនេយ្យភាព។
- **ការត្រៀមលក្ខណៈ៖** ការសម្រេចបានចក្ខុវិស័យនៃកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្នទាមទារពេលសមស្រប។ ក្របខណ្ឌនេះ គិតគូរយ៉ាងល្អិតល្អន់ និងតម្រង់ទិសភាគីពាក់ព័ន្ធ ដើម្បីឆ្ពោះទៅកំណត់សកម្មភាពអាទិភាព និងរយៈពេលអនុវត្តជាក់លាក់ ដើម្បីកសាងភាពត្រៀមខ្លួននៃប្រព័ន្ធគាំពារសង្គម មុនពេលមានគ្រោះអាសន្នកើតឡើង។
- **នវានុវត្តន៍៖** ក្របខណ្ឌនេះ មានគោលបំណងពង្រឹងប្រព័ន្ធ និងបច្ចេកវិទ្យាឌីជីថល ដើម្បីបម្រើដល់ការបំពេញមុខងារសម្រាប់ការចុះឈ្មោះ និងគណនេយ្យភាពនៃយន្តការបើកផ្តល់ដែលនឹងផ្តល់ផលប្រយោជន៍សម្រាប់ការឆ្លើយតបនឹងគ្រោះអាសន្ន។
- **ចីរភាព និងភាពជាម្ចាស់៖** ក្របខណ្ឌនេះ នឹងដាក់ចេញចំណាត់ការដែលពង្រឹងបន្ថែមលើអាទិភាពរបស់ប្រព័ន្ធគាំពារសង្គមដែលមានស្រាប់ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ក៏ដូចជាការកសាងសមត្ថភាព និងធនធានរបស់ស្ថាប័នជាដើម។
- **ភាពទ្រទ្រង់បាននៃថវិកាជាតិ៖** ដូចគ្នានឹងកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមដែលមានស្រាប់ កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្នត្រូវបានរៀបចំឡើង ឱ្យមានលក្ខណៈសមស្របនឹងធនធានដែលមាន និងភាពទ្រទ្រង់បាននៃថវិកាជាតិ ដោយគិត

បញ្ចូលនូវភាពមានកម្រិតនៃលំហថវិកា និងសម្ពាធដែលបណ្តាលមកពីឥទ្ធិពលនៃរាល់វិបត្តិនានាលើសេដ្ឋកិច្ចជាតិ។

- **គោលការណ៍មិនបោះបង់ពលរដ្ឋណាម្នាក់៖** ក្របខណ្ឌនេះ ព្យាយាមបញ្ចូលរាល់ពលរដ្ឋងាយរងគ្រោះ ដែលទទួលរងផលប៉ះពាល់ដោយគ្រោះអាសន្នតាមដែលអាចធ្វើទៅបាន ស្របតាមបរិបទនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមនាពេលបច្ចុប្បន្ន។
- **ភាពជាដៃគូ៖** ការឆ្លើយតបនឹងគ្រោះអាសន្នដោយប្រព័ន្ធគាំពារសង្គម គួរមានការបំពេញបន្ថែមដោយកិច្ចខិតខំផ្សេងទៀតរបស់ភាគីពាក់ព័ន្ធ ដែលជាដៃគូយ៉ាងសំខាន់ក្នុងការឆ្លើយតបនឹងគ្រោះមហន្តរាយ។ ការបង្កើតភាពជាដៃគូជាមួយស្ថាប័នខាងក្រៅ ដូចជាម្ចាស់ជំនួយ, ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងសង្គមស៊ីវិល មានភាពចាំបាច់ ក្នុងការធានាឱ្យបាននូវការអនុវត្តក្របខណ្ឌនេះ ប្រកបដោយវឌ្ឍនភាព។

ក្របខណ្ឌនេះបានដាក់បញ្ចូលជម្រើសឧបករណ៍គោលនយោបាយសមស្រប សម្រាប់ឆ្លើយតបនឹងគ្រោះអាសន្នទៅតាមប្រភេទខុសៗគ្នា ដូចជាគ្រោះទឹកជំនន់, គ្រោះរាំងស្ងួត, វិបត្តិម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងវិបត្តិសុខភាពសាធារណៈ។ ក្របខណ្ឌនេះ ព្យាយាមឆ្លើយតបនឹងតម្រូវការផ្នែកសេដ្ឋកិច្ច ដែលបណ្តាលមកពីវិបត្តិសុខភាពសាធារណៈ ដែលប៉ះពាល់ដោយផ្ទាល់លើបន្ទុកចំណាយចេញពីហោប៉ៅ សម្រាប់ការស្វែងរកសេវាសុខភាព និងការព្យាបាល ព្រមទាំងការរងឥទ្ធិពលដោយប្រយោលនៃវិធានការកាត់បន្ថយការចម្លង ដែលប៉ះពាល់ដល់ការងារ, ជីវភាព, ព្រមទាំងការជះឥទ្ធិពលដោយសារការធ្លាក់ចុះនៃសេដ្ឋកិច្ច ដូចជាអតិផរណា និងការបាត់បង់ការងារក្នុងវិស័យសំខាន់ៗ។ ជម្រើសឧបករណ៍គោលនយោបាយទាំងនេះ ក៏អាចត្រូវបានកែសម្រួលទៅតាមស្ថានការណ៍ជាក់ស្តែង និងផ្តល់ជាអំណះអំណាងក្នុងការរៀបចំដាក់ឱ្យអនុវត្ត ក្នុងករណីប្រទេសកម្ពុជាជួបប្រទះគ្រោះអាសន្នផ្សេងៗទៀត ក្រៅពីគ្រោះអាសន្នខាងលើ ឬជួបប្រទះគ្រោះអាសន្នកម្រិតសហគមន៍ដែលមិនសូវកើតឡើងញឹកញាប់។ ជម្រើសឧបករណ៍គោលនយោបាយដែលមានក្នុងក្របខណ្ឌនេះនឹងឆ្លើយតបនឹងតម្រូវការផ្នែកសេដ្ឋកិច្ច និងផ្តល់ការគាំពារនៅពេលមានការធ្លាក់ចុះប្រាក់ចំណូលរបស់គ្រួសារងាយរងគ្រោះអាសន្ន ដូចជាគ្រួសារកំពុងរស់នៅក្នុងភាពក្រីក្រ, ក្រុមជនងាយរងគ្រោះ និងគ្រួសាររស់នៅក្បែរបន្ទាត់ភាពក្រីក្រ ដែលងាយនឹងធ្លាក់ចូលទៅក្នុងភាពក្រីក្រវិញដោយសារគ្រោះអាសន្នជាដើម។ ជម្រើសឧបករណ៍គោលនយោបាយក្នុងក្របខណ្ឌនេះត្រូវបានលើកឡើង ដោយផ្អែកលើស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធគាំពារសង្គម។ ប្រព័ន្ធគាំពារសង្គមកម្ពុជា នឹងមានការវិវឌ្ឍបន្ថែមទៀតក្នុងពេលខាងមុខ ហើយឧបករណ៍គោលនយោបាយថ្មីៗ នឹងត្រូវបានដាក់ចេញ ឬកម្មវិធីដែលមានស្រាប់ត្រូវបានពង្រីកបន្ថែមទៀត។ កិច្ចការទាំងនេះ នឹងត្រូវកំណត់តាមរយៈការរៀបចំក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមជំហានបន្ទាប់។ ក្របខណ្ឌនេះ នឹងត្រូវធ្វើការពិនិត្យ និងធ្វើបច្ចុប្បន្នភាពឡើងវិញជាទៀងទាត់ ស្របតាមការវិវឌ្ឍនៃប្រព័ន្ធគាំពារសង្គម និងកសាង "ប្រព័ន្ធគាំពារសង្គមដែលមានភាពបត់បែន-Adaptive Social Protection" សម្រាប់ពេលអនាគត។

## ៣. ជម្រើសឧបករណ៍គោលនយោបាយគាំពារសង្គម សម្រាប់ឆ្លើយតបនឹងគ្រោះអាសន្ន

កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ជាពិសេសជាគុផ្សំដែលស្ថិតក្រោមប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គមមានសារៈសំខាន់ ដែលក្នុងនោះប្រព័ន្ធជំនួយសង្គមមានសក្តានុពលក្នុងការបំពេញតម្រូវការនៅពេលមានគ្រោះអាសន្ន ដោយសារប្រព័ន្ធនេះផ្តោតការយកចិត្តទុកដាក់លើការគ្របដណ្តប់ដល់ក្រុមពលរដ្ឋក្រីក្រ និងងាយរងគ្រោះ។ នៅពេលមានគ្រោះអាសន្ន, ប្រព័ន្ធជំនួយសង្គមមានលក្ខណៈងាយស្រួល ក្នុងការពង្រីកការគ្របដណ្តប់ដល់គ្រួសារដែលនៅក្រៅកម្មវិធី ឬរបបគាំពារសង្គមដែលមានស្រាប់ ដូចជាពលរដ្ឋរស់នៅក្បែរបន្ទាត់ភាពក្រីក្រ និងបុគ្គលក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយមិនតម្រូវឱ្យមានការបង់ភាគទាន។ កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្នតាមរយៈប្រព័ន្ធសន្តិសុខសង្គម ក៏មានសារៈប្រយោជន៍ ក្នុងការផ្តល់ការគាំពារដល់សមាជិកនៅពេលមានគ្រោះអាសន្នផងដែរ។

ការឧបត្ថម្ភជាសាច់ប្រាក់ជាវិធីសាស្ត្រដែលមានប្រសិទ្ធភាពខ្ពស់ ក្នុងការគាំទ្រគ្រួសារដែលរងផលប៉ះពាល់ដោយគ្រោះអាសន្ន ដើម្បីប្រើប្រាស់ក្នុងការបំពេញតម្រូវការជាមូលដ្ឋានបន្ទាន់នានាក៏ដូចជាការស្តារជីវភាពឡើងវិញទៅតាមអាទិភាពរបស់គ្រួសារនីមួយៗ ព្រមទាំងមានភាពងាយស្រួលក្នុងការពង្រីកវិសាលភាពផងដែរ។ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ ជាការឆ្លើយតបប្រកបដោយប្រសិទ្ធភាពដើម្បីធានាដល់ចំណាយលើថ្លៃទំនិញប្រើប្រាស់ប្រចាំថ្ងៃ ក៏ដូចជាការចាក់បញ្ចូលសាច់ប្រាក់ទៅក្នុងសេដ្ឋកិច្ច ដោយសារគ្រួសារដែលទទួលផលមានទំនោរប្រើប្រាស់ប្រាក់ឧបត្ថម្ភមួយផ្នែកធំលើទំនិញប្រើប្រាស់ប្រចាំថ្ងៃ និងចំណាយសម្រាប់បំពេញតម្រូវការចាំបាច់ជាមូលដ្ឋាន។ ជម្រើសឧបករណ៍គោលនយោបាយដែលសមស្រប និងអាចអនុវត្តបានសម្រាប់ឆ្លើយតបនឹងគ្រោះអាសន្ន នៅកម្ពុជាពាក់ព័ន្ធយ៉ាងជិតស្និតនឹងកម្មវិធីជំនួយសង្គមជាសាច់ប្រាក់។ ទន្ទឹមនេះ ការធ្វើសមាហរណកម្មវិធីជាតិជំនួយសង្គមនានា ដែលផ្តោតលើអភិក្រមហានិភ័យនៃវដ្តជីវិត ទៅក្នុង **កញ្ចប់គ្រួសារ** ជាកិច្ចការសំខាន់ថ្មីមួយ ដើម្បីបន្តគាំទ្រដល់វិធានការឆ្លើយតបក្នុងការបំពេញតម្រូវការបន្ថែម និងជួយឧបត្ថម្ភដល់គ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលមានគ្រោះអាសន្ន។

វិធានការឆ្លើយតបពីប្រព័ន្ធគាំពារសង្គមត្រូវអនុវត្តយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាព ដើម្បីផ្តល់ការគាំទ្រពលរដ្ឋដែលរងផលប៉ះពាល់ដោយគ្រោះអាសន្នបានទាន់ពេល ដោយប្រើប្រាស់ប្រព័ន្ធនិងយន្តការដែលមានស្រាប់។ ក្របខណ្ឌនេះកំណត់ជម្រើសឧបករណ៍គោលនយោបាយគាំពារសង្គមដោយឈរលើមូលដ្ឋាននៃកម្មវិធី, ប្រព័ន្ធប្រតិបត្តិការ និងកិច្ចដំណើរការកម្មវិធី និងរបបគាំពារសង្គមដែលមានស្រាប់ និងអាចប្រើប្រាស់បានយ៉ាងរហ័ស ដើម្បីជួយដល់ពលរដ្ឋដែលរងផលប៉ះពាល់ដោយគ្រោះអាសន្ន ដោយផ្តោតជាពិសេសលើក្រុមពលរដ្ឋក្រីក្រ, ពលរដ្ឋដែលរស់នៅក្បែរបន្ទាត់ភាពក្រីក្រ និងក្រុមជនងាយរងគ្រោះ ក្នុងរង្វង់ពណ៌ក្រហមក្នុង **រូបភាពទី២**។

### ១. ពលរដ្ឋស្ថិតក្រោមការគ្របដណ្តប់នៃប្រព័ន្ធគាំពារសង្គម

សម្រាប់ពលរដ្ឋដែលបានចុះឈ្មោះក្នុងកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមដែលមានស្រាប់ (**ក្រុម ក ក្នុងរូបភាពទី២**), ក្របខណ្ឌនេះ បានកំណត់ជម្រើសឧបករណ៍គោលនយោបាយដូចខាងក្រោម៖

ក. ការកែសម្រួលយន្តការអនុវត្ត៖ ការកែសម្រួលយន្តការ និងការអនុវត្តកម្មវិធី ដើម្បីធានាថាកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមដែលមានស្រាប់ មានភាពធន់, អាចដំណើរការបាន និងមានប្រសិទ្ធភាព ក្នុងអំឡុងពេលគ្រោះអាសន្ន។

ខ. ការពង្រីកវិសាលភាពគ្របដណ្តប់តាមខ្សែបញ្ឈរ៖ ការបង្កើន ឬការកែសម្រួលកញ្ចប់អត្ថប្រយោជន៍នៃកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម ដើម្បីធានាបាននូវភាពគ្រប់គ្រាន់ក្នុងការបំពេញតម្រូវការចាំបាច់ជាមូលដ្ឋានថ្មីៗ ដែលបណ្តាលមកពីឥទ្ធិពលនៃគ្រោះអាសន្ន។

## ២. ក្រុមពលរដ្ឋដែលមិនស្ថិតក្រោមការគ្របដណ្តប់នៃប្រព័ន្ធគាំពារសង្គម

សម្រាប់ក្រុមពលរដ្ឋដែលមិនស្ថិតក្រោមការគ្របដណ្តប់នៃប្រព័ន្ធគាំពារសង្គម (**ក្រុម ខ និង គ ក្នុងរូបភាពទី២**), ក្របខណ្ឌនេះ បានកំណត់ជម្រើសឧបករណ៍គោលនយោបាយ ដើម្បីធានាបាននូវការកំណត់អត្តសញ្ញាណ និងពង្រីកការគ្របដណ្តប់ឱ្យបានឆាប់រហ័ស នៅក្រោយគ្រោះអាសន្ន តាមរយៈ៖

ក. ការដាក់ឱ្យអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់បន្ទាន់ថ្មីជាបណ្តោះអាសន្ន ដើម្បីគ្របដណ្តប់គ្រួសារខាងលើ ដោយប្រើប្រាស់យន្តការស្ថាប័ន និងប្រព័ន្ធបើកផ្តល់សាច់ប្រាក់ដែលមានស្រាប់។ ក្នុងគ្រាមានគ្រោះអាសន្នធ្ងន់ធ្ងរ, ជំនួយជាសាច់ប្រាក់សម្រាប់តម្រូវការជាមូលដ្ឋាន ក៏ត្រូវបានអនុវត្តបន្ថែមដោយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ដោយប្រើប្រាស់ទិន្នន័យនៃប្រព័ន្ធគាំពារសង្គមផងដែរ។

ខ. ការពង្រីកវិសាលភាពគ្របដណ្តប់របស់កម្មវិធី និងរបបគាំពារសង្គមដែលមានស្រាប់ ដើម្បីបញ្ចូលគ្រួសារ ឬពលរដ្ឋបន្ថែម **តាមរយៈការពង្រីកវិសាលភាពគ្របដណ្តប់តាមខ្សែផ្តេក**។

ជម្រើសឧបករណ៍គោលនយោបាយខាងលើនេះ អាចអនុវត្តរួមគ្នាដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធដើម្បីបន្តអនុវត្តកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមដែលមានស្រាប់ ក៏ដូចជាពង្រីកកម្មវិធីគាំពារសង្គមដែលមានលក្ខណៈបណ្តោះអាសន្ន ទៅដល់គ្រួសារដែលរងផលប៉ះពាល់ដោយគ្រោះអាសន្ន ទាំងគ្រួសារស្ថិតក្រោម និងគ្រួសារដែលមិនស្ថិតក្រោមកម្មវិធី ឬរបបគាំពារសង្គមដែលមានស្រាប់។

### រូបភាពទី២. កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ននៅកម្ពុជា៖ ការគ្របដណ្តប់ទៅដល់ពលរដ្ឋដែលងាយរងគ្រោះដោយសារគ្រោះអាសន្ន



តារាងក្នុងផ្នែក ៣.១ ដល់ ៣.៤ ខាងក្រោម កំណត់ជម្រើសឧបករណ៍គោលនយោបាយក្រោមក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន និងបង្ហាញអំពីសារៈប្រយោជន៍នៃជម្រើសឧបករណ៍គោលនយោបាយនីមួយៗ ក៏ដូចជាការពិចារណាអំពីបញ្ហាប្រឈមដែលត្រូវដោះស្រាយ ដើម្បីធានាថាជម្រើសឧបករណ៍គោលនយោបាយទាំងនេះមានប្រសិទ្ធភាព ក្នុងការកាត់បន្ថយហានិភ័យ ក៏ដូចជាមានលក្ខណៈសមស្របទៅតាមប្រភេទនៃគ្រោះអាសន្ន។

## ៣.១ ការកែសម្រួលយន្តការអនុវត្តកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមដែលមានស្រាប់

ជម្រើសនេះកំណត់អំពីការកែសម្រួលសមាសធាតុលម្អិតនៃយន្តការអនុវត្តកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមដែលមានស្រាប់ ដើម្បីធានានូវការបន្តទទួលបានអត្ថប្រយោជន៍ និងមានប្រសិទ្ធភាពនៅពេលមានគ្រោះអាសន្ន (ជម្រើសនេះផ្តល់អត្ថប្រយោជន៍ដល់គ្រួសារទាំងឡាយដែលស្ថិតក្នុងក្រុម "ក" **ក្នុងរូបភាពទី២**)។

| | ជម្រើសឧបករណ៍គោលនយោបាយ | សេចក្តីបញ្ជាក់ | ការពិចារណាគន្លឹះៗ (បញ្ហាដែលត្រូវដោះស្រាយ) | អាចត្រូវអនុវត្តក្នុងការឆ្លើយតបនឹង | | | |
|---|---|---|---|---|---|---|---|
| | | | | គ្រោះទឹកជំនន់ | គ្រោះរាំងស្ងួត | វិបត្តិម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | វិបត្តិសុខភាពសាធារណៈ |
| ១ | កម្មវិធីផ្តល់អាហារតាមសាលារៀន ដោយប្រើប្រាស់កសិផលក្នុងសហគមន៍៖ ការផ្លាស់ប្តូរពីការផ្តល់អាហារតាមសាលារៀនទៅជាការចែកស្បៀងយកទៅចម្អិននៅផ្ទះ | – ការផ្លាស់ប្តូរនេះ ជាវិធានការឆ្លើយតបនឹងការរាតត្បាតនៃជំងឺកូវីដ-១៩ ដើម្បីរក្សាបាននូវការផ្តល់ជំនួយជាអាហារ និងធានានូវការបន្តបំពេញតម្រូវការអាហារដល់កុមារក្នុងករណីមានការបិទសាលារៀន<br>– អាហារ ជាតម្រូវការមូលដ្ឋានចាំបាច់របស់កុមារទាំងឡាយដែលរងផលប៉ះពាល់ដោយគ្រោះអាសន្ន | – កម្មវិធីនេះ ស្ថិតក្នុងដំណាក់កាលនៃការផ្ទេរការអនុវត្តទៅក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល<br>– អាចមានភាពស្មុគស្មាញក្នុងការធានាបាននិរន្តរភាពនៃការផ្គត់ផ្គង់នៅតាមមូលដ្ឋាននៅពេលមានគ្រោះអាសន្នដែលមានការរំខានដល់ខ្សែប្រវាក់ផ្គត់ផ្គង់។ កម្មវិធីនេះគួរផ្តោតអាទិភាពលើកុមារងាយរងគ្រោះ ដូចជាកុមារនៃគ្រួសារមាន | ពាក់ព័ន្ធក្នុងករណីបិទសាលារៀន | មិនពាក់ព័ន្ធ | មិនពាក់ព័ន្ធ | ពាក់ព័ន្ធក្នុងករណីបិទសាលារៀន |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | – កម្មវិធីនេះ អាចអនុវត្តនៅក្នុងតំបន់មួយចំនួនដែលងាយនឹងទទួលរងផលប៉ះពាល់ដោយគ្រោះអាសន្ន។ | បណ្ណសមធម៌ ដូចដែលបានអនុវត្តក្នុងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងពិចារណាបន្ថែមលើខ្សែច្រវាក់ផ្គត់ផ្គង់តាមរយៈលទ្ធកម្មដែលមានលក្ខណៈប្រមូលផ្តុំសម្រាប់ផ្នែកណាមួយ។ | | | | |
| ២ | កម្មវិធីជំនួយសង្គមជាសាច់ប្រាក់៖ ព្យួរការអនុវត្តលក្ខខណ្ឌ, ព្យួរការចាកចេញដោយស្វ័យប្រវត្តិរបស់គ្រួសារពីមូលដ្ឋានទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (បណ្ណសមធម៌មានសុពលភាពរយៈពេល៣ឆ្នាំ), និងព្យួរការចាកចេញដោយស្វ័យប្រវត្តិពីកម្មវិធីដោយសារកុមារលើសអាយុទទួលបានអត្ថប្រយោជន៍ក្នុងអំឡុងពេលមានគ្រោះអាសន្ន។ | – ជានាបានការបន្តអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ដែលមានស្រាប់ និងផ្តល់ការគាំទ្របន្ថែមនៅពេលមានតម្រូវការចាំបាច់ជាមូលដ្ឋានដោយចៀសវាងការដាក់ពិន័យចំពោះការមិនអនុវត្តលក្ខខណ្ឌខ្ជាប់ខ្ជួន។ ចំពោះកម្មវិធីដែលប្រើប្រាស់បណ្ណសមធម៌ ឬអាយុរបស់កុមារជាលក្ខណៈវិនិច្ឆ័យសម្រាប់ទទួលបានអត្ថប្រយោជន៍, មិនគួរដេកអ្នកទទួលផលចេញពីកម្មវិធីក្នុងអំឡុងពេលមានគ្រោះអាសន្ន<br>– ងាយស្រួលក្នុងការអនុវត្ត។ | – ការព្យួរការអនុវត្តលក្ខខណ្ឌត្រូវការធន្ទះនយោបាយនៅតាមស្ថាប័នអនុវត្ត<br>– ត្រូវមានការផ្សព្វផ្សាយច្បាស់លាស់ដើម្បីចៀសវាងការភ័ន្តច្រឡំអំពីកម្មវិធី។ | ពាក់ព័ន្ធក្នុងគ្រោះអាសន្នគ្រប់កម្រិតសម្រាប់ព្យួរការអនុវត្តលក្ខខណ្ឌ, និងគ្រោះអាសន្នកម្រិត ២ និង ៣ សម្រាប់ព្យួរការចាកចេញ | ពាក់ព័ន្ធសម្រាប់ភាពធ្ងន់ធ្ងរកម្រិតពីមធ្យមទៅខ្ពស់ | ពាក់ព័ន្ធ | ពាក់ព័ន្ធ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣ | របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពៈកាត់បន្ថយ, ផ្អាកទាំងស្រុង ឬឧបត្ថម្ភធនដោយរដ្ឋលើការបង់ភាគទានរបស់សមាជិកសម្រាប់រយៈពេលកំណត់មួយនៃគ្រោះអាសន្ន និងរយៈពេលអនុគ្រោះដែលសមាជិកត្រូវបង់សងភាគទានដែលខកខាន។ | – ចៀសវាងការលុប ឬដកសមាជិកចេញ ក្នុងករណីនិយោជក និងនិយោជិតមិនបានបង់ភាគទានដើម្បីអនុញ្ញាតឱ្យសមាជិកនៅបន្តទទួលបានរបបថែទាំសុខភាពនៅពេលមានគ្រោះអាសន្ន<br>– អនុវត្តតាមជាក់ស្តែង។ | – ហានិភ័យនៃកំណើនបន្ទុកចំណាយ នឹងប៉ះពាល់ដល់ចីរភាពរបស់ស្ថាប័នជាប្រតិបត្តិករ<br>– ផ្តោតលើមន្ត្រីរាជការ និងកម្មករនិយោជិត<br>– ត្រូវរៀបចំតាមដំណាក់កាលជាបន្តបន្ទាប់ចាប់ពីឆ្នាំ២០២៥ តទៅ។ | ពាក់ព័ន្ធក្នុងគ្រោះអាសន្ន កម្រិត ៣ នៅពេលមានការគ្របដណ្តប់លើបុគ្គលក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ | ពាក់ព័ន្ធសម្រាប់ភាពធ្ងន់ធ្ងរ កម្រិតខ្ពស់ នៅពេលមានការគ្របដណ្តប់លើបុគ្គលក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ | ពាក់ព័ន្ធសម្រាប់គ្រោះអាសន្នធ្ងន់ធ្ងរ | ពាក់ព័ន្ធសម្រាប់គ្រោះអាសន្នធ្ងន់ធ្ងរ |

## ៣.២ ការពង្រីកវិសាលភាពគ្របដណ្តប់តាមខ្សែបញ្ឈរ

ការពង្រីកវិសាលភាពគ្របដណ្តប់កិច្ចគាំពារសង្គមតាមខ្សែបញ្ឈរសំដៅដល់ការបន្ថែម ឬបង្កើនកញ្ចប់អត្ថប្រយោជន៍ ក្រោមកម្មវិធីជំនួយសង្គម ឬរបបសន្តិសុខសង្គមដែលមានស្រាប់ ដល់អ្នកទទួលផលនៅក្នុងប្រព័ន្ធគាំពារសង្គមបច្ចុប្បន្ន។ ការគាំទ្រពលរដ្ឋក្នុងក្រុម "ក" នៅក្នុង **រូបភាពទី២** នឹងធានាថាអត្ថប្រយោជន៍ដែលត្រូវផ្តល់ អាចបំពេញតម្រូវការជាមូលដ្ឋាន ឬការប្រឈមផ្នែកសេដ្ឋកិច្ច និងប្រាក់ចំណូល ដោយសារផលប៉ះពាល់នៃគ្រោះអាសន្ន។

| ជម្រើសឧបករណ៍គោលនយោបាយ | | សេចក្តីបញ្ជាក់ | ការពិចារណាគន្លឹះៗ (បញ្ហាដែលត្រូវដោះស្រាយ) | អាចត្រូវអនុវត្តក្នុងការឆ្លើយតបនឹង | | | |
|---|---|---|---|---|---|---|---|
| | | | | គ្រោះទឹកជំនន់ | គ្រោះរាំងស្ងួត | វិបត្តិម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | វិបត្តិសុខភាពសាធារណៈ |
| ៤ | ការពង្រីកវិសាលភាពគ្របដណ្តប់តាមខ្សែបញ្ឈរចំពោះកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់ | – ការឧបត្ថម្ភសាច់ប្រាក់ជាវិធីសាស្រ្តមួយ សម្រាប់បំពេញតម្រូវការចាំបាច់ជាមូលដ្ឋាន | – សម្រាប់កម្មវិធី ដែលផ្តោតលើក្រុមគោលដៅ ជាពលរដ្ឋក្រីក្រ, ចំណុចខ្វះខាតមួយចំនួនក្នុងការរៀបចំ និងអនុវត្តយន្តការកំណត់ | ពាក់ព័ន្ធក្នុងគ្រោះអាសន្ន គ្រប់កម្រិត | ពាក់ព័ន្ធ | ពាក់ព័ន្ធ | ពាក់ព័ន្ធ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | គ្រួសារ ដែលនឹងត្រូវបានបង្កើតឡើង។ | – ដើម្បីងាយស្រួលក្នុងការអនុវត្ត, ការកែសម្រួលគួរផ្តោតលើការកំណត់អត្ថប្រយោជន៍ និងយន្តការបើកផ្តល់សាច់ប្រាក់<br>– ប្រព័ន្ធឌីជីថល ដែលមានការរៀបចំល្អ នឹងធ្វើឱ្យដំណើរការមានលក្ខណៈងាយស្រួល, មិនស្មុគស្មាញ និងមានបន្ទុកការងារបន្ថែមតិចតួច<br>– អ្នកទទួលផលរបស់កម្មវិធីជំនួយសង្គម អាចត្រូវបានកំណត់ថាជាគ្រួសារដែលងាយទទួលរងគ្រោះនៅពេលមានគ្រោះអាសន្ន។<br>– ជម្រើសនេះ នឹងមានភាពពាក់ព័ន្ធកាន់តែខ្លាំង នៅពេលដែលមានការពង្រីកការគ្របដណ្តប់កម្មវិធីជំនួយសង្គម។ | អត្តសញ្ញាណគ្រួសារក្រីក្រ អាចកាត់បន្ថយនូវសុក្រឹត្យភាពនៃការកំណត់អត្តសញ្ញាណគ្រួសារគោលដៅរបស់កម្មវិធី និងប៉ះពាល់ដល់ប្រសិទ្ធភាពនៃវិធានការឆ្លើយតបនឹងគ្រោះអាសន្ន<br>– ជម្រើសនេះ មានភាពចាំបាច់ក្នុងការតភ្ជាប់ទៅនឹងជម្រើសផ្សេងទៀតដើម្បីឈានទៅគ្របដណ្តប់ និងដាក់បញ្ចូលគ្រួសារគោលដៅផ្សេង ដែលមិនមែនជាគ្រួសារក្រីក្រ (ដូចជាការពង្រីកវិសាលភាពតាមខ្សែផ្តេក)។ | | | | |

## ៣.៣ ការពង្រីកការគ្របដណ្តប់ដល់គ្រួសារថ្មីៗ ដែលទទួលរងផលប៉ះពាល់ដោយគ្រោះអាសន្ន

ការពង្រីកនេះ នឹងត្រូវធ្វើឡើងតាមវិធីចំនួន ៣ ដូចខាងក្រោម៖

១. ការរៀបចំយន្តការ និងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់បន្ទាន់ក្នុងគ្រាអាសន្នជាកម្មវិធីពិសេស ដោយសិក្សាពីបទពិសោធន៍នានា ដែលទទួលបានពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩, កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យក្នុងអំឡុងពេលមានសម្ពាធអតិផរណា។ កម្មវិធីឧបត្ថម្ភសាច់ប្រាក់បន្ទាន់ពិសេសនឹងត្រូវពង្រីកនៅពេលមានគ្រោះអាសន្ន ដើម្បីផ្តល់ជំនួយបណ្តោះអាសន្នដល់គ្រួសារដែលមិនទទួលបានអត្ថប្រយោជន៍ពីកម្មវិធីជំនួយសង្គមដែលមានស្រាប់ នៅពេលរងផលប៉ះពាល់ពីគ្រោះអាសន្ន។ ជម្រើសឧបករណ៍គោលនយោបាយនេះអាចត្រូវបានប្រើប្រាស់ក្នុងគ្រោះអាសន្នគ្រប់ប្រភេទ និងទៅតាមកម្រិតផលប៉ះពាល់ខុសៗគ្នា។

២. ដើម្បីជួយគ្រួសារទាំងឡាយ ដែលនៅក្រៅវិសាលភាពគ្របដណ្តប់នៃប្រព័ន្ធគាំពារសង្គមបច្ចុប្បន្ន, គ្រួសារទាំងនោះត្រូវចុះបញ្ជីចូលក្នុងកម្មវិធី ឬរបបគាំពារសង្គមដែលមានស្រាប់នៅពេលមានគ្រោះអាសន្ន (**ការពង្រីកវិសាលភាពគ្របដណ្តប់តាមខ្សែផ្តេក**)។ កិច្ចការនេះ អាចសម្រេចបានតាមរយៈយុទ្ធនាការបញ្ជ្រាបការយល់ដឹង និងការចុះឈ្មោះទ្រង់ទ្រាយធំសម្រាប់កម្មវិធីជំនួយសង្គមដែលមានស្រាប់ ក្នុងតំបន់ដែលទទួលរងផលប៉ះពាល់ដោយគ្រោះអាសន្ន និងជាពិសេសនៅតំបន់ងាយទទួលរងគ្រោះមហន្តរាយធម្មជាតិ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីកម្មវិធី ក៏ដូចជាកំណត់អត្តសញ្ញាណគ្រួសារដែលអាចមានសិទ្ធិទទួលបានអត្ថប្រយោជន៍ ប៉ុន្តែមិនទាន់ត្រូវបានបញ្ចូលទៅក្នុងកម្មវិធីនៅឡើយ។ គ្រួសារដែលត្រូវបានកំណត់អត្តសញ្ញាណតាមរយៈយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំ អាចត្រូវចាត់ទុកជាក្រុមគោលដៅអាទិភាពសម្រាប់ការជ្រើសរើសដើម្បីទទួលបានអត្ថប្រយោជន៍ពីកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ។

៣. ការប្រែក្លាយមូលដ្ឋានទិន្នន័យគ្រួសារក្រីក្រ ឱ្យទៅជាសំណុំទិន្នន័យដែលមានសក្តានុពលសម្រាប់មូលដ្ឋានទិន្នន័យសង្គមដែលនឹងផ្តល់នូវការចុះបញ្ជី និងលក្ខណៈសមស្របសម្រាប់ការកំណត់អត្តសញ្ញាណគ្រួសារងាយរងហានិភ័យ សម្រាប់ជម្រើសឧបករណ៍គោលនយោបាយទី៥។ ការណ៍នេះ អនុញ្ញាតឱ្យមានទិន្នន័យគ្រួសារងាយរងហានិភ័យកាន់តែទូលាយ (ក្រុម "ខ" នៅក្នុង**រូបភាពទី២**)។ តាមការចង្អុលបង្ហាញពីក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម, វិសាលភាពគ្របដណ្តប់នៃប្រព័ន្ធសន្តិសុខសង្គមលើបុគ្គលក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងទិន្នន័យអំពីក្រុមគោលដៅនេះនឹងត្រូវបានពង្រីក។ គ្រួសារទាំងឡាយដែលមិនទាន់ស្ថិតក្នុងមូលដ្ឋានទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ឬប្រព័ន្ធទិន្នន័យរបស់ ប.ស.ស. (ក្រុម "**គ**" នៅក្នុង**រូបភាពទី២**) នឹងត្រូវចុះបញ្ជីថ្មីតាមលក្ខណៈរហ័ស បន្ទាប់ពីគ្រោះអាសន្នទៅតាមស្ថានភាពជាក់ស្តែង ដោយប្រើប្រាស់យន្តការកំណត់អត្តសញ្ញាណតាមការស្នើសុំ។

| ជម្រើសឧបករណ៍គោលនយោបាយ | | សេចក្តីបញ្ជាក់ | ការពិចារណាគន្លឹះៗ (បញ្ហាដែលត្រូវដោះស្រាយ) | អាចត្រូវអនុវត្តក្នុងការឆ្លើយតបនឹង | | | |
|---|---|---|---|---|---|---|---|
| | | | | គ្រោះទឹកជំនន់ | គ្រោះរាំងស្ងួត | វិបត្តិម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | វិបត្តិសុខភាពសាធារណៈ |
| ៥ | កម្មវិធីឧបត្ថម្ភសាច់ប្រាក់ពិសេសបន្ទាន់ជាបណ្តោះអាសន្នទៅតាម | – ការធ្វើឱ្យប្រសើរឡើងនូវមុខងារស្ថាប័ន, ប្រព័ន្ធឌីជីថល និងប្រតិបត្តិការដែលមានស្រាប់នៃ | – យន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ជាឧបករណ៍សំខាន់សម្រាប់ការកំណត់អត្តសញ្ញាណ | ពាក់ព័ន្ធក្នុងគ្រោះអាសន្ន | ពាក់ព័ន្ធសម្រាប់ភាពធ្ងន់ធ្ងរកម្រិត | ពាក់ព័ន្ធ | ពាក់ព័ន្ធ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ប្រភេទគ្រោះអាសន្នជាក់លាក់ដែលអនុវត្តដោយរាជរដ្ឋាភិបាលដោយប្រើប្រាស់យន្តការ និងប្រព័ន្ធដែលមានស្រាប់។ | កម្មវិធីជំនួយសង្គមជាសាច់ប្រាក់អាចពន្លឿនប្រតិបត្តិការ និងមានប្រសិទ្ធភាពចំណាយ។ កិច្ចការនេះបានអនុវត្តនៅក្នុងបរិបទនៃជំងឺកូវីដ-១៩ និងសម្ពាធអតិផរណារួចហើយ<br>– ជាវិធីសាស្ត្រមួយ ដើម្បីគ្របដណ្តប់ដល់គ្រួសារទាំងឡាយដែលមិនមែនជាអ្នកទទួលផលក្រោមកម្មវិធីជំនួយសង្គមដែលមានស្រាប់ និងដែលទទួលរងគ្រោះដោយគ្រោះអាសន្ន ដោយត្រូវមានការបញ្ជ្រាបការយល់ដឹងអំពីកម្មវិធីឱ្យបានច្បាស់លាស់។ កិច្ចការនេះ បានអនុវត្តក្នុងបរិបទនៃការឆ្លើយតបនឹងសម្ពាធអតិផរណា និងគ្រោះទឹកជំនន់ រួចហើយ<br>– ការបញ្ជ្រាបការយល់ដឹង អំពីយន្តការចាកចេញ ឬការបញ្ចប់កម្មវិធីជំនួយសង្គមពិសេសដែលមានលក្ខណៈបណ្តោះអាសន្ន មានសារៈសំខាន់ណាស់។ សម្រាប់គ្រួសារទាំងឡាយ ដែលឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់សម្រាប់ទទួលបានអត្ថប្រយោជន៍ពីកម្មវិធី | និងបញ្ចូលទិន្នន័យគ្រួសារក្រីក្រកម្រិត ១ និងកម្រិត ២។ ប្រព័ន្ធនេះត្រូវបាន និងកំពុងពង្រីក និងកែសម្រួល ដើម្បីបញ្ចូលគ្រួសារងាយរងហានិភ័យដែលរស់នៅក្បែរបន្ទាត់នៃភាពក្រីក្រ។ បន្ថែមពីនេះ ចំណុចខ្វះខាតមួយចំនួនក្នុងការរៀបចំ និងអនុវត្តយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រអាចប៉ះពាល់ដល់សុក្រឹត្យភាពរបស់ទិន្នន័យ<br>– ការពឹងផ្អែកលើក្រុមប្រឹក្សាឃុំសង្កាត់ សម្រាប់ការចុះបញ្ជីតាមយន្តការអត្តសញ្ញាណគ្រួសារក្រីក្រតាមការស្នើសុំ នៅក្រោយពេលគ្រោះអាសន្ន អាចប្រឈមនូវបញ្ហាមួយចំនួន ដូចជាបន្ទុកការងារ និងការរាំងស្ទះ ព្រមទាំងហានិភ័យពាក់ព័ន្ធនឹងបញ្ហានយោបាយ និងភាពលម្អៀងក្នុងកិច្ចដំណើរការ ជាដើម។ ជនចំណាកស្រុក និងជនអនាថា អាចមិនត្រូវបានដាក់បញ្ចូលសម្រាប់ការចុះបញ្ជីដោយសារតែខ្វះឯកសារបញ្ជាក់ទីលំនៅ ជាដើម។ | កម្រិត ២ និង ៣ | មធ្យម និង ខ្ពស់ | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ឬរបបគាំពារសង្គមដែលមានស្រាប់ ត្រូវបានចុះឈ្មោះចូលតែម្តង<br>– បច្ចុប្បន្ន មូលដ្ឋានទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ត្រូវបានប្រែក្លាយជាសំណុំមូលដ្ឋានទិន្នន័យ ដែលផ្ទុកអត្តសញ្ញាណគ្រួសារងាយរងហានិភ័យដែលជាគ្រួសាររស់នៅក្បែរបន្ទាត់នៃភាពក្រីក្រ និងងាយធ្លាក់ទៅក្នុងភាពក្រីក្រនៅពេលមានគ្រោះអាសន្នតាមរយៈយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។<br>– អត្ថគាហកនៃប្រព័ន្ធសន្តិសុខសង្គម អាចត្រូវបានដាក់បញ្ចូលផងដែរ។ ប្រព័ន្ធចុះបញ្ជីរបស់ ប.ស.ស អាចគ្របដណ្តប់ដល់បុគ្គលនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ហើយសមាជិក ប.ស.ស នៅក្នុងវិស័យដែលទទួលរងផលប៉ះពាល់ អាចត្រូវបានដាក់បញ្ចូលដោយស្វ័យប្រវត្តិ ដើម្បីទទួលបានអត្ថប្រយោជន៍។ | | | | | |
| ៦ | ការពង្រីកវិសាលភាពកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ តាម | – អាចគ្របដណ្តប់គ្រួសារទាំងឡាយដែលមិនមែនជាអ្នកទទួលផលក្នុងកម្មវិធីជំនួយសង្គមដែលមាន | – យន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ជាឧបករណ៍សម្រាប់ការកំណត់អត្តសញ្ញាណ និងបញ្ចូល | ពាក់ព័ន្ធក្នុងគ្រោះអាសន្ន | ពាក់ព័ន្ធសម្រាប់ភាព | ពាក់ព័ន្ធ | ពាក់ព័ន្ធ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | រយៈយុទ្ធនាការចុះបញ្ជីរហ័សនៅក្នុងតំបន់ដែលរងផលប៉ះពាល់ដោយគ្រោះអាសន្នដើម្បីកំណត់អត្តសញ្ញាណ និងចុះឈ្មោះគ្រួសារដែលលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ ប៉ុន្តែមិនទាន់បានបញ្ចូលក្នុងបញ្ជីគ្រួសារគោលដៅ **(ការពង្រីកវិសាលភាពគ្របដណ្តប់តាមខ្សែផ្តេក)។** | ស្រាប់ ប៉ុន្តែរងផលប៉ះពាល់ដោយគ្រោះអាសន្ន<br>– មិនតម្រូវឱ្យមានការផ្លាស់ប្តូរលក្ខណៈវិនិច្ឆ័យនៃការកំណត់ក្រុមគោលដៅរបស់កម្មវិធីដែលមានស្រាប់ទេ ដោយគ្រាន់តែបញ្ចូលអ្នកដែលមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ ប៉ុន្តែមិនទាន់បានកំណត់អត្តសញ្ញាណ<br>– ការពង្រីកនេះ នឹងជួយបង្កើនការគ្របដណ្តប់របស់កម្មវិធីជំនួយសង្គម ដែលមានស្រាប់នៅក្នុងតំបន់ ដែលប្រឈមនឹងគ្រោះអាសន្ន និងរួមចំណែកក្នុងការកសាងភាពធន់។ | ទិន្នន័យគ្រួសារក្រីក្រកម្រិត១ និងកម្រិត២ និងគ្រួសារងាយរងហានិភ័យដែលរស់នៅក្បែរបន្ទាត់នៃភាពក្រីក្រផងដែរ<br>– ការពឹងផ្អែកលើក្រុមប្រឹក្សាឃុំសង្កាត់ ក្នុងការចុះបញ្ជីតាមរយៈយន្តការ អត្តសញ្ញាណគ្រួសារក្រីក្រ តាមការស្នើសុំ នៅក្រោយពេលគ្រោះអាសន្ន អាចប្រឈមបញ្ហាមួយចំនួនដូចបានរៀបរាប់ខាងលើ។ ជនចំណាកស្រុក និងជនអនាថា គួរត្រូវបានដាក់បញ្ចូលសម្រាប់ការចុះបញ្ជី ដោយសិក្សាពីយន្តការ និងលទ្ធភាពដោះស្រាយបញ្ហាខ្វះឯកសារបញ្ជាក់<br>– ការពង្រីកការគ្របដណ្តប់របស់កម្មវិធីឬរបបដែលមានស្រាប់ ទាមទារឱ្យមានការពិចារណាដោយប្រុងប្រយ័ត្នទៅលើចីរភាព និងភាពអាចទ្រទ្រង់បាននៃថវិកាជាតិ។ | កម្រិត ២ និង ៣ | ធ្ងន់ធ្ងរកម្រិតខ្ពស់ | | |
| ៧ | ការពង្រីកវិសាលភាពគ្របដណ្តប់នៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរយៈខ្សែផ្តេកទៅដល់គ្រួសាររបស់សមាជិក ប.ស.ស នៅពេលគ្រោះអាសន្ន។ | – ជម្រើសនេះ នឹងពង្រីកវិសាលភាពគ្របដណ្តប់របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពដែលមានស្រាប់ ទៅដល់ពលរដ្ឋដទៃទៀតនៅក្នុងតំបន់ប្រឈមនឹងគ្រោះអាសន្ន | – ហានិភ័យនៃការកើនឡើងនូវបន្ទុកចំណាយ និងចីរភាពនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពដែលកំពុងស្ថិតក្នុងដំណាក់កាលកំពុងអភិវឌ្ឍ។ | ពាក់ព័ន្ធក្នុងគ្រោះអាសន្នកម្រិត ៣ | ពាក់ព័ន្ធសម្រាប់ភាពធ្ងន់ធ្ងរកម្រិតខ្ពស់ | ពាក់ព័ន្ធនៅក្នុងគ្រោះអាសន្នធ្ងន់ធ្ងរ | ពាក់ព័ន្ធនៅក្នុងគ្រោះអាសន្នធ្ងន់ធ្ងរ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | – មិនតម្រូវឱ្យមានការផ្លាស់ប្តូរលក្ខខណ្ឌនៃការចូលជាសមាជិក ប.ស.ស ឡើយ ដោយគ្រាន់តែបញ្ចូលគ្រួសាររបស់សមាជិក ប.ស.ស ដែលមិនស្ថិតក្រោមការគ្របដណ្តប់នៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ដោយអាចគិតគូរអំពីការបន្ថែមភាគទានតាមការចាំបាច់។ | | | | | |

## ៣.៤ ការបំពេញតម្រូវការថ្មីៗ តាមរយៈការផ្សាភ្ជាប់កម្មវិធីជំនួយសាច់ប្រាក់ពិសេសបន្ទាន់ក្នុងគ្រាអាសន្នរបស់ស្ថាប័នមនុស្សធម៌ និងប្រព័ន្ធគាំពារសង្គម

ប្រព័ន្ធគាំពារសង្គមស្ថិតក្នុងដំណាក់កាលកំពុងអភិវឌ្ឍជាបន្តបន្ទាប់ ហើយក្នុងករណីមានគ្រោះអាសន្នធ្ងន់ធ្ងរខ្លាំង ប្រព័ន្ធនេះនឹងអាចមានភាពខ្វះចន្លោះក្នុងការពង្រីកវិសាលភាពគ្របដណ្តប់ ក៏ដូចជាការបំពេញតម្រូវការចាំបាច់។ ជម្រើសនេះនឹងបើកផ្លូវឱ្យមានការធ្វើសុខដុមនីយកម្មរវាងការឆ្លើយតបនៃប្រព័ន្ធគាំពារសង្គមរបស់រាជរដ្ឋាភិបាល ជាមួយនឹងកម្មវិធីជំនួយជាសាច់ប្រាក់របស់ស្ថាប័នមនុស្សធម៌ ជាពិសេសវេទិកាឆ្លើយតបមនុស្សធម៌ ក្នុងការឆ្លើយតបនឹងគ្រោះអាសន្ន។ កម្មវិធីជំនួយជាសាច់ប្រាក់ពិសេសបន្ទាន់ ក្រោមយន្តការសម្របសម្រួលរបស់ស្ថាប័នមនុស្សធម៌ អាចត្រូវបានរៀបចំឡើងដោយផ្សាភ្ជាប់ជាមួយនឹងមូលដ្ឋានទិន្នន័យគ្រួសារក្រីក្រ សម្រាប់ជាអភិក្រមឆ្ពោះទៅធ្វើសុខដុមនីយកម្មក្នុងការកំណត់ក្រុមគោលដៅ សម្រាប់ផ្តល់កិច្ចអន្តរាគមន៍ដើម្បីបំពេញភាពខ្វះចន្លោះ។ កម្រិតអត្ថប្រយោជន៍នៃប្រព័ន្ធគាំពារសង្គមរបស់រាជរដ្ឋាភិបាល និងស្ថាប័នមនុស្សធម៌ អាចនឹងត្រូវបានសម្របសម្រួល និងបំពេញគ្នាទៅវិញទៅមក។

| | ជម្រើសឧបករណ៍គោលនយោបាយ | សេចក្តីបញ្ជាក់ | ការពិចារណាគន្លឹះៗ (បញ្ហាដែលត្រូវដោះស្រាយ) | អាចត្រូវអនុវត្តក្នុងការឆ្លើយតបនឹង: គ្រោះទឹកជំនន់ | គ្រោះរាំងស្ងួត | វិបត្តិម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | វិបត្តិសុខភាពសាធារណៈ |
|---|---|---|---|---|---|---|---|
| ៨ | កម្មវិធីឧបត្ថម្ភសាច់ប្រាក់ពិសេសបន្ទាន់ជា | – ការប្រើប្រាស់ទិន្នន័យពីមូលដ្ឋានទិន្នន័យគាំពារសង្គម អាចពន្លឿន | – ត្រូវការភស្តុតាងបន្ថែម និងការវិភាគរួមគ្នាអំពីកម្រិតអត្ថប្រយោជន៍ និងដែនកំណត់នៃការទទួលបាន | ពាក់ព័ន្ធក្នុងគ្រោះអាសន្ន | ពាក់ព័ន្ធ | ពាក់ព័ន្ធ | ពាក់ព័ន្ធ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | បណ្ដោះអាសន្នទៅតាមប្រភេទគ្រោះអាសន្ន ដែលផ្ដល់ហិរញ្ញប្បទាន និងអនុវត្តដោយស្ថាប័នមនុស្សធម៌ ដោយប្រើប្រាស់យន្តការនៃប្រព័ន្ធគាំពារសង្គមរបស់រាជរដ្ឋាភិបាល។ | និងបង្កើនប្រសិទ្ធភាពនៃការចុះបញ្ជីអ្នកទទួលផលរបស់កម្មវិធីជំនួយជាសាច់ប្រាក់របស់ស្ថាប័នមនុស្សធម៌<br>– ផ្ដល់លក្ខណៈឱ្យមានការរៀបចំសម្របសម្រួលរវាងយន្តការអនុវត្តកម្មវិធីរបស់រាជរដ្ឋាភិបាល និងស្ថាប័នមនុស្សធម៌។ ស្ថាប័នមនុស្សធម៌ អាចមិនរាប់បញ្ចូលអ្នកទទួលផលនៃកម្មវិធីជំនួយសង្គម ឬគ្រួសារមានបណ្ណសមធម៌ ដែលស្ថិតក្រោមការគ្របដណ្ដប់នៃកិច្ចគាំពារសង្គម ឆ្លើយតបនឹងគ្រោះអាសន្នរបស់រាជរដ្ឋាភិបាល និងផ្ដោតលើគ្រួសារងាយរងហានិភ័យ និងជនងាយរងគ្រោះដទៃដែលមិនទាន់រាប់បញ្ចូលក្នុងកម្មវិធីជំនួយសង្គមដែលមានស្រាប់។ ស្ថាប័នមនុស្សធម៌ក៏អាចផ្ដល់ជំនួយបន្ថែមដល់គ្រួសារដែលស្ថិតក្រោមការគ្របដណ្ដប់នៃកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្នរបស់រាជរដ្ឋាភិបាលដើម្បីបំពេញតម្រូវការបន្ថែមផងដែរ។ | ទិន្នន័យពីមូលដ្ឋានទិន្នន័យគាំពារសង្គម ដើម្បីបំពេញគោលបំណងនៃជម្រើសនេះ ក៏ដូចជាស្វែងរកវិធីសាស្ត្រកែលម្អ<br>– បច្ចុប្បន្ន មិនទាន់មានប្រព័ន្ធសម្រាប់ធ្វើសមាហរណកម្មទិន្នន័យនៅឡើយ<br>– ការផ្ដល់លទ្ធភាពទទួលបានទិន្នន័យពីមូលដ្ឋានទិន្នន័យគាំពារសង្គម ធ្វើឡើងតាមការស្នើសុំផ្លូវការ និងឆ្លងកាត់ការបំពេញបែបបទមួយចំនួន ដើម្បីទទួលបានទិន្នន័យ<br>– យកចិត្តទុកដាក់លើការការពារទិន្នន័យ និងឯកជនភាពនៃទិន្នន័យ<br>– ពង្រឹងយន្តការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងស្ថាប័នមនុស្សធម៌ និងក្នុងចំណោមស្ថាប័នមនុស្សធម៌ដូចជាការចុះអនុស្សរណៈនៃការយោគយល់គ្នាជាដើម។ | កម្រិត ២ និង ៣ | សម្រាប់ភាពធ្ងន់ធ្ងរកម្រិតខ្ពស់ | | |

### ៣.៥ ជម្រើសឧបករណ៍គោលនយោបាយសម្រាប់អនាគត

**ក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន** ក៏កំណត់ផងដែរនូវជម្រើសឧបករណ៍គោលនយោបាយផ្សេងទៀត ដែលអាចលើកយកមកគិតគូរសម្រាប់ការអនុវត្តនៅអនាគត ដែលមានដូចខាងក្រោម៖

#### ៣.៥.១.ការពង្រីកវិសាលភាពគ្របដណ្តប់នៃមូលនិធិសមធម៌សុខាភិបាល

ការពង្រីកវិសាលភាពគ្របដណ្តប់នៃមូលនិធិសមធម៌សុខាភិបាលដល់ក្រុមគោលដៅថ្មី ក្នុងអំឡុងពេលគ្រោះអាសន្ន ជាជម្រើសមួយដែលអាចធ្វើទៅបាន។ បច្ចុប្បន្ន មូលដ្ឋានទិន្នន័យគ្រួសារក្រីក្រកំពុងត្រូវបានធ្វើការតភ្ជាប់ជាមួយមូលដ្ឋានទិន្នន័យផ្សេងៗ ដូច្នេះមូលនិធិសមធម៌សុខាភិបាលអាចត្រូវបានពង្រីកវិសាលភាពគ្របដណ្តប់លើក្រុមគោលដៅដទៃ នៅពេលមានគ្រោះអាសន្ន។ ទោះយ៉ាងណា ការទទួលយកអត្ថប្រយោជន៍ក្រោមមូលនិធិសមធម៌សុខាភិបាលរបស់គ្រួសារមានបណ្ណសមធម៌ នៅមានកម្រិតនៅឡើយ បច្ចុប្បន្ននេះ។ ម្យ៉ាងទៀត តម្រូវការចំណាយលើសេវាសុខភាពរបស់គ្រួសាររស់នៅក្បែរបន្ទាត់ភាពក្រីក្រ ក្នុងអំឡុងពេលគ្រោះអាសន្ន ក៏អាចត្រូវបានបំពេញដោយជម្រើសឧបករណ៍គោលនយោបាយទី៤ និងទី៥។ ទន្ទឹមនេះ បន្ទុកចំណាយពាក់ព័ន្ធនឹងសេវាសុខភាពទូទៅអាចត្រូវបានគិតគូរ នៅពេលរៀបចំដាក់ឱ្យអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ហើយបន្ថែមប្រាក់ឧបត្ថម្ភទៅតាមលក្ខខណ្ឌសុខភាពជាក់លាក់ ដើម្បីបំពេញតម្រូវការចំណាយផ្នែកសុខភាពរបស់ក្រុមពលរដ្ឋទាំងនោះ។

#### ៣.៥.២.ប្រព័ន្ធស្បៀងបម្រុង

ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមបានឆ្លុះបញ្ចាំងអំពីប្រព័ន្ធស្បៀងបម្រុង សម្រាប់ឆ្លើយតបនឹងគ្រោះអាសន្ន ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការប្រព័ន្ធគ្រប់គ្រងស្បៀងបម្រុងកម្ពុជា ដែលមានរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធាន។ កន្លងមក ប្រព័ន្ធស្បៀងបម្រុងត្រូវបានកំណត់ជាវិធានការអន្តរាគមន៍ ក្រោមក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ប៉ុន្តែមិនស្ថិតនៅក្រោមការតាមដាន និងសម្របសម្រួលរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គមទេ។ ប្រព័ន្ធស្បៀងបម្រុងនេះ ជាការបំពេញបន្ថែម ដែលមានសក្តានុពលក្នុងការគាំទ្រការអនុវត្តកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ននៅកម្ពុជា ក៏ដូចជាកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ដោយត្រូវមានការពិនិត្យ និងរៀបចំយន្តការសម្របសម្រួលជាមួយប្រព័ន្ធនេះ។ ប្រព័ន្ធស្បៀងបម្រុងក៏មានសក្តានុពលក្នុងការជួយស្តារជីវភាពរបស់គ្រួសារជាកសិករឡើងវិញ តាមរយៈការផ្តល់ពូជស្រូវ ពូជដំណាំ និងពូជសត្វជាដើម បន្ទាប់ពីមានគ្រោះអាសន្ន។

ការឧបត្ថម្ភសាច់ប្រាក់អាចត្រូវបានប្រើប្រាស់ដើម្បីបំពេញតម្រូវការបន្ទាន់ និងចាំបាច់ជាមូលដ្ឋាន ដូចជាស្បៀង, ឈ្នួលផ្ទះ, ថ្លៃអគ្គិសនី និងទឹកស្អាត, ថ្លៃធ្វើដំណើរ, សុខភាព, អនាម័យ និងការសងបំណុលជាដើម។ ការឧបត្ថម្ភជាសាច់ប្រាក់ក៏អាចត្រូវបានប្រើប្រាស់ដើម្បីជួយស្តារជីវភាពគ្រួសារឡើងវិញបន្ទាប់ពីមានគ្រោះអាសន្នផងដែរ ដូចជាការកសាង និងជួសជុលជម្រកស្នាក់នៅ ឬទិញសម្ភារៈចាំបាច់នានា។ ក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ននឹងក្លាយជាយន្តការឆ្លើយតបនឹងតម្រូវការនៃការស្តារជីវភាពឡើងវិញ រួមទាំងការស្តារជម្រកស្នាក់នៅ ដោយចាំបាច់ត្រូវរៀបចំ

យន្តការផ្សេងពីការឧបត្ថម្ភសម្រាប់តម្រូវការជាមូលដ្ឋាន ដែលបំពេញបន្ថែមដោយប្រព័ន្ធស្បៀងបម្រុង។

### ៣.៥.៣.ជម្រើសផ្សេងទៀត

ចំពោះជម្រើសឧបករណ៍គោលនយោបាយសម្រាប់វិធានការអន្តរាគមន៍ផ្សេងៗទៀត នៃកម្មវិធីជំនួយសង្គម ឬរបបសន្តិសុខសង្គមដែលមានស្រាប់ និងកម្មវិធី ឬរបបដែលនឹងត្រូវដាក់ឱ្យអនុវត្តនៅអនាគត ដូចជារបបសន្តិសុខសង្គមផ្នែកប្រាក់សោធន ទាំងវិស័យឯកជន និងសាធារណៈ, របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ទាំងវិស័យឯកជន និងសាធារណៈ, របបសន្តិសុខសង្គមផ្នែកនិកម្មភាព និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម សម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន អាចត្រូវដាក់ឱ្យអនុវត្តតាមស្ថានភាពជាក់ស្តែងទៅតាមកម្រិត និងប្រភេទជាក់លាក់នៃគ្រោះអាសន្ននីមួយៗ។

ក្រៅពីវិបត្តិម៉ាក្រូសេដ្ឋកិច្ច, វិបត្តិសុខភាពសាធារណៈ, គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត, ក្របខណ្ឌនេះ អាចគិតគូរអំពីវិធានការអន្តរាគមន៍នៅអនាគត សម្រាប់គ្រោះមហន្តរាយផ្សេងទៀត ដូចជាខ្យល់ព្យុះ និងខ្យល់កន្ត្រាក់ ព្រមទាំងកត្តាបម្រែបម្រួលអាកាសធាតុ ដែលជំរុញឱ្យមុខសញ្ញាគ្រោះអាសន្នទាំងនេះកើតឡើងកាន់តែញឹកញាប់។ ក្នុងន័យនេះ វិធានការអន្តរាគន៍ដើម្បីត្រៀមឆ្លើយតបនឹងគ្រោះអាសន្ន ប្រភេទខ្យល់ព្យុះ និងខ្យល់កន្ត្រាក់ គួរត្រូវបានគិតគូរ និងដាក់ស្នើនូវវិធានការអន្តរាគមន៍ តាមស្ថានភាពជាក់ស្តែងដែលនឹងដាក់ចេញដោយរាជរដ្ឋាភិបាល។

## ៤. ភូមិសាស្ត្រអាទិភាព និងសូចនាករប្រកាសអាសន្ន

**ក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន** កំណត់ការឆ្លើយតបរបស់ប្រព័ន្ធគាំពារសង្គមទល់នឹងគ្រោះអាសន្នប្រភេទខុសៗគ្នា ដូចជាគ្រោះធម្មជាតិ (គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត), វិបត្តិម៉ាក្រូសេដ្ឋកិច្ច និងវិបត្តិសុខភាពសាធារណៈ ដោយហេតុថាផលប៉ះពាល់នៃគ្រោះអាសន្នមានលក្ខណៈខុសៗគ្នាផងដែរទៅតាមភូមិសាស្ត្រនីមួយៗ។ ប្រភពទិន្នន័យ និងសូចនាករដែលកំណត់កម្រិតវាស់វែងសម្រាប់ដាក់ចេញឧបករណ៍គោលនយោបាយឆ្លើយតប ក៏ត្រូវមានលក្ខណៈខុសៗគ្នាផងដែរ។

ការដាក់ឱ្យអនុវត្តឧបករណ៍គោលនយោបាយឆ្លើយតបនឹងគ្រោះទឹកជំនន់ ពឹងផ្អែកលើទិន្នន័យនៃផលប៉ះពាល់នៅក្រោយពេលគ្រោះទឹកជំនន់ **(សូមមើលតារាងទី២)**។ ការប្រមូល និងផ្សព្វផ្សាយទិន្នន័យ ដែលអនុវត្តតាមបែបប្រមូលផ្តុំ ដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់រាជធានី-ខេត្ត ជៀសវាងបាននូវការពន្យារពេលក្នុងការធ្វើអន្តរាគមន៍ ដែលបណ្តាលមកពីតម្រូវការពេលដើម្បីចងក្រង និងចែករំលែកទិន្នន័យដោយអាជ្ញាធរថ្នាក់ក្រោមជាតិ។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងក្រសួងធនធានទឹក និងឧតុនិយម បាន និងកំពុងរៀបចំដាក់ឱ្យអនុវត្តប្រព័ន្ធប្រកាសអាសន្ន (Early Warning System) អំពីគ្រោះទឹកជំនន់ ដោយប្រើប្រាស់ទិន្នន័យកម្រិតកម្ពស់ទឹកទន្លេសម្រាប់ធ្វើជាម៉ូដែល ដែលអាចព្យាករទំហំនៃផលប៉ះពាល់។ បច្ចុប្បន្ន ទិន្នន័យនេះត្រូវបានប្រើប្រាស់ដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់រាជធានី-ខេត្ត ដើម្បីក្រើនរំលឹកដល់សហគមន៍ តាមរយៈការផ្ញើសារតាមទូរសព្ទ។ បន្ថែមពីនេះ ប្រព័ន្ធតាមដានត្រួតពិនិត្យទឹកជំនន់ និងវាយតម្លៃផលប៉ះពាល់ (Flood Monitoring and Impact Assessment System) កំពុងត្រូវបានប្រើប្រាស់នៅកម្ពុជា ក្នុងគោលបំណងបង្កើតឱ្យមានថ្នាលដែលផ្តល់ព័ត៌មានរហ័ស, ទាន់ហេតុការណ៍ និងអាចជឿទុកចិត្តបាន ដោយប្រើប្រាស់បច្ចេកវិទ្យាព្យាករណ៍ដែលមានលក្ខណៈទំនើប។ សម្រាប់ការអនុវត្តនៅដំណាក់កាលដំបូង, សូចនាករដែលកំណត់កម្រិតភាពធ្ងន់ធ្ងរនៃគ្រោះទឹកជំនន់ ដែលមានលក្ខណៈឯកភាព និងទទួលស្គាល់នៅថ្នាក់ជាតិ គួរត្រូវបានប្រើប្រាស់សម្រាប់ជាមគ្គុទេសក៍ សម្រាប់ការអនុវត្តកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន។

**តារាងទី១៖ សូចនាករកំណត់កម្រិតភាពធ្ងន់ធ្ងរនៃគ្រោះទឹកជំនន់នៅកម្ពុជា**[1]

| |
|---|
| **កម្រិត ១** |
| – រាជធានី-ខេត្ត ចំនួន ៤ ចុះក្រោម រងផលប៉ះពាល់៖ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់រាជធានី-ខេត្ត ស្នើសុំអន្តរាគមន៍ពីគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| **កម្រិត ២** |
| – រាជធានី-ខេត្ត ចំនួន ៥ ទៅ ១០ រងផលប៉ះពាល់៖ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់រាជធានី-ខេត្ត ស្នើសុំអន្តរាគមន៍ពីគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។ |
| **កម្រិត ៣** |
| – រាជធានី-ខេត្ត ចាប់ពី ១១ ឡើងទៅ រងផលប៉ះពាល់៖ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់រាជធានី-ខេត្ត ស្នើសុំអន្តរាគមន៍ពីគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។ |

[1] ប្រភព៖ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ, ផែនការត្រៀមបម្រុងសម្រាប់ឆ្លើយតបការសង្គ្រោះបន្ទាន់គ្រោះមហន្តរាយទឹកជំនន់ ឆ្នាំ ២០២៣។

បច្ចុប្បន្ន សូចនាករ និងកម្រិតវាស់វែងសម្រាប់ជំរុញឱ្យមានវិធានការឆ្លើយតបនឹងគ្រោះរាំងស្ងួត មិនទាន់មានលក្ខណៈឯកភាព និងទទួលស្គាល់ថ្នាក់ជាតិនៅឡើយ។ ការកំណត់លក្ខខណ្ឌដែលត្រូវប្រកាសអាសន្នត្រូវធ្វើឡើងដោយផ្អែកលើកម្រិតធ្ងន់ធ្ងរខុសៗគ្នានៃគ្រោះរាំងស្ងួត។ បច្ចុប្បន្ន កិច្ចការនេះកំពុងរៀបចំក្រោមការដឹកនាំរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ។ នៅពេលត្រូវបានកំណត់ច្បាស់លាស់, សូចនាករទាំងនេះនឹងត្រូវបានប្រើប្រាស់ ដើម្បីបង្កើតយន្តការជំរុញសម្រាប់ការឆ្លើយតបពីប្រព័ន្ធគាំពារសង្គម ហើយប្រព័ន្ធគ្រប់គ្រង និងផ្តល់ទិន្នន័យទាន់ហេតុការណ៍ (PRISM) ក៏អាចត្រូវបានប្រើប្រាស់ដើម្បីរៀបចំជាម៉ូដែលសម្រាប់ព្យាករផលប៉ះពាល់ទៅតាមកម្រិតភាពធ្ងន់ធ្ងរខុសៗគ្នានៃគ្រោះរាំងស្ងួត ដើម្បីផ្តល់ព័ត៌មានអំពីទីតាំងភូមិសាស្រ្តអាទិភាព និងទំហំផលប៉ះពាល់ដែលត្រូវការវិធានការឆ្លើយតបពីប្រព័ន្ធគាំពារសង្គម។

ករណីវិបត្តិម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងវិបត្តិសុខភាពសាធារណៈដែលជាទូទៅមិនកើតឡើងញឹកញាប់, ការកំណត់ការឆ្លើយតបពីប្រព័ន្ធគាំពារសង្គម នឹងត្រូវធ្វើឡើងទៅតាមបរិបទជាក់លាក់នៃប្រភេទគ្រោះអាសន្ននីមួយៗ។ បទពិសោធន៍អំពីវិបត្តិម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០០៩ និងសម្ពាធអតិផរណាក្នុងឆ្នាំ២០២២ និងការរាតត្បាតនៃជំងឺកូវីដ-១៩ បានឆ្លុះបញ្ចាំងអំពីភាពចាំបាច់នៃតម្រូវការអន្តរាគមន៍គាំពារសង្គមដើម្បីឆ្លើយតបនឹងវិបត្តិដែលកើតឡើង។ ការងារជាអាទិភាព គឺការកំណត់សូចនាករសំខាន់ៗ និងការរៀបចំយន្តការតាមដានត្រួតពិនិត្យផ្អែកលើសូចនាករទាំងនេះ ដោយសហការជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ។ ទន្ទឹមនេះ លទ្ធផលនៃការសិក្សាអំពីគ្រោះអាសន្ន ដែលបង្ហាញពីការប៉ាន់ស្មានកំណើននៃភាពក្រីក្រ និងផលប៉ះពាល់លើវិស័យសេដ្ឋកិច្ច និងជីវភាពរបស់គ្រួសារក្រីក្រ និងគ្រួសាររស់នៅក្បែរបន្ទាត់នៃភាពក្រីក្រ ព្រមទាំងក្នុងលក្ខខណ្ឌនៃការដាក់ប្រទេសក្នុងភាពអាសន្ន ឬវិធានការបិទខ្ទប់ ក៏អាចត្រូវបានប្រើប្រាស់ដើម្បីបំពេញបន្ថែមទៅនឹងសូចនាករសម្រាប់ប្រកាសអាសន្នផងដែរ។

## តារាងទី២៖ ទីតាំងភូមិសាស្រ្តអាទិភាព និងតម្រូវការព័ត៌មានក្នុងការដាក់ឱ្យអនុវត្តឧបករណ៍គោលនយោបាយគាំពារសង្គម សម្រាប់ឆ្លើយតប ទៅតាមប្រភេទគ្រោះអាសន្ន

តារាងខាងក្រោម បង្ហាញលម្អិតអំពីការអនុវត្តកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្នទៅតាមទីតាំងភូមិសាស្រ្ត, ប្រភេទនៃគ្រោះអាសន្ននីមួយៗ, សូចនាករ ព្រមទាំងប្រភពទិន្នន័យដែលអាចប្រើប្រាស់ ដើម្បីដាក់ឱ្យអនុវត្តឧបករណ៍គោលនយោបាយឆ្លើយតបរបស់ប្រព័ន្ធគាំពារសង្គម។

| ប្រភេទគ្រោះអាសន្ន | ទីតាំងភូមិសាស្រ្តអាទិភាព | ព័ត៌មានចាំបាច់សម្រាប់ការដាក់ឱ្យអនុវត្តឧបករណ៍គោលនយោបាយឆ្លើយតប |
|---|---|---|
| គ្រោះទឹកជំនន់ | ទីតាំងភូមិសាស្រ្តរាជធានី-ខេត្ត និងឃុំ-សង្កាត់ដែលរងផលប៉ះពាល់ដោយគ្រោះទឹកជំនន់។ ទីតាំងភូមិសាស្រ្តដែលងាយរងការជន់លិចគួរត្រូវបានយកចិត្តទុកដាក់ដូចជា៖ (១)រាជធានី-ខេត្តនៅជុំវិញបឹងទន្លេសាប និងនៅតាមដងទន្លេមេគង្គ, (២) ខេត្តមានហានិភ័យខ្ពស់ ដោយគ្រោះទឹកជំនន់ដូចជា៖ ខេត្តកំពង់ធំ, កំពង់ឆ្នាំង, កំពង់ចាម, កណ្តាល, | – សូចនាករប្រកាសអាសន្នអំពីគ្រោះទឹកជំនន់ដូចមានកំណត់ក្នុង **តារាងទី២**<br>– ផ្តល់អាទិភាពដល់ឃុំ-សង្កាត់ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរ និងមានចំនួនគ្រួសារក្រីក្រច្រើន<br>– បញ្ចូលបច្ចេកវិទ្យាទំនើប និងឈានមុខសម្រាប់ការវិភាគភាពងាយរងគ្រោះផ្អែកអាកាសធាតុ និងការប្រកាសអាសន្នអំពី |

| | | |
|---|---|---|
| | ព្រៃវែង និងតាកែវ, (៣) ខេត្តអាចនឹងរងផលប៉ះពាល់ធ្ងន់ធ្ងរដោយការធ្លាក់ភ្លៀងខ្លាំងបង្កឱ្យមានជំនន់ទឹកភ្លៀងដូចជា៖ ខេត្តព្រះវិហារ, ឧត្តរមានជ័យ, បន្ទាយមានជ័យ, បាត់ដំបង, ប៉ៃលិន, ពោធិសាត់, កំពង់ស្ពឺ, កំពត, និងរតនគិរី។<br>**ក្រសួង-ស្ថាប័នពាក់ព័ន្ធ គួររៀបចំយន្តការ និងដាក់ឱ្យអនុវត្តសាកល្បងកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន នៅក្នុងឃុំ-សង្កាត់ នៃរាជធានី-ខេត្តណា ដែលបានបង្ហាញដោយប្រព័ន្ធគ្រប់គ្រង និងផ្តល់ទិន្នន័យទាន់ហេតុការណ៍ (PRISM) ថាមានហានិភ័យខ្ពស់ ដោយផ្អែកលើព័ត៌មានអំពីគ្រោះទឹកជំនន់ និងប្រព័ន្ធទិន្នន័យគ្រួសារក្រីក្រ។** | គ្រោះទឹកជំនន់ ដើម្បីចាត់វិធានការឱ្យបានទាន់ពេល (Early Warning, Early Action)។<br><br>ប្រភពព័ត៌មាន៖ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| គ្រោះរាំងស្ងួត | ផ្អែកលើទិន្នន័យឆ្នាំ២០១៦ ហានិភ័យនៃគ្រោះរាំងស្ងួត បានរីករាលដាលនៅទូទាំងប្រទេស។ រាជធានី-ខេត្តទាំងអស់ទទួលរងគ្រោះរាំងស្ងួត ដែលបណ្តាលមកពីភ្លៀងធ្លាក់មិនគ្រប់គ្រាន់ លើកលែងរាជធានីភ្នំពេញ, ខេត្តតាកែវ, ខេត្តកណ្តាល, ខេត្តព្រៃវែង និងខេត្តស្វាយរៀង។ ការវិភាគរបស់កម្មវិធីស្បៀងអាហារពិភពលោក ស្តីពីភាពងាយរងគ្រោះ និងហានិភ័យនៃគ្រោះរាំងស្ងួត បានរកឃើញថាតំបន់ចំនួន៣ ដែលមានហានិភ័យខ្ពស់ដោយគ្រោះរាំងស្ងួត ពាក់ព័ន្ធនឹងកត្តាឧតុនិយម និងកសិកម្ម។ តំបន់ទាំងនេះ រួមមានខេត្តស្ថិតនៅភាគខាងលិច, ភាគកណ្តាល និងភាគឦសាននៃប្រទេស។ | សូចនាករ និងការកំណត់កម្រិតវាស់វែងអំពីការកើតឡើង និងភាពធ្ងន់ធ្ងរនៃគ្រោះរាំងស្ងួត នឹងត្រូវបានអភិវឌ្ឍ។ បច្ចុប្បន្ន ការងារនេះបាន និងកំពុងរៀបចំដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ។ |
| វិបត្តិម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ការគ្របដណ្តប់កម្រិតថ្នាក់ជាតិដោយផ្តោតលើទីតាំងភូមិសាស្ត្រ ដូចខាងក្រោម៖<br>i) ទីតាំងភូមិសាស្ត្រ ជាពិសេសទីប្រជុំជនដែលប្រមូលផ្តុំដោយគ្រួសារក្រីក្រ, គ្រួសារងាយរងហានិភ័យ, កម្មករនិយោជិត និងបុគ្គលក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។<br>ii) ទីតាំងភូមិសាស្ត្រដែលប្រមូលផ្តុំដោយរោងចក្រសហគ្រាស ដែលប្រើប្រាស់ | បម្រែបម្រួលនៃស្ថានភាពសង្គម-សេដ្ឋកិច្ច ដែលអាចជាសញ្ញាណបឋមនៃវិបត្តិម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាចប្រើប្រាស់ដើម្បីជំរុញការដាក់ចេញនូវវិធានការឆ្លើយតបពីប្រព័ន្ធគាំពារសង្គម មានដូចជា៖<br>– ការកើនឡើងខ្ពស់នៃថ្លៃទំនិញប្រើប្រាស់ប្រចាំថ្ងៃ<br>– ការកើនឡើងនៃចំនួនជនចំណាកស្រុកវិលត្រលប់មកវិញ និង/ឬការបិទវិស័យ ឬឧស្សាហកម្មណាមួយ |

| | | |
|---|---|---|
| | កម្មករនិយោជិត និងអ្នកធ្វើការដែលមានប្រាក់ឈ្នួលទាប, ជំនាញទាប និងរងផលប៉ះពាល់ធ្ងន់ធ្ងរ។<br>iii) ទីតាំងភូមិសាស្ត្រដែលប្រមូលផ្តុំទៅដោយជនចំណាកស្រុកដែលវិលត្រលប់មកវិញច្រើន។ | – ការធ្លាក់ចុះប្រាក់បញ្ញើពីបរទេស ឬប្រាក់ចំណូលជាតិ<br>– ការកើនឡើងនៃចំនួនពាក្យស្នើសុំកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ<br>– ការកើនឡើងនៃចំនួនសមាជិក ប.ស.ស ដែលមិនបង់ភាគទាន<br>– ការកើនឡើងនៃបំណុលដែលមិនមានលទ្ធភាពសង<br>– ការធ្លាក់ចុះនៃកម្រិតជីវភាពរស់នៅ និងសេដ្ឋកិច្ចមូលដ្ឋានក្នុងទ្រង់ទ្រាយធំ និងការបង្ខំឱ្យផ្លាស់ទីលំនៅដែលបង្កដោយគ្រោះមហន្តរាយ។<br>– សេចក្តីប្រកាសផ្លូវការថ្នាក់ជាតិអំពីវិបត្តិសេដ្ឋកិច្ចជាតិឬការរៀបចំវិធានការកាត់បន្ថយហានិភ័យសង្គម-សេដ្ឋកិច្ច ដោយរាជរដ្ឋាភិបាល ឬក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។<br><br>ក្រៅពីសញ្ញាណអាសន្នខាងលើ, ការអង្កេត និងការសិក្សាវាយតម្លៃលើស្ថានភាពសង្គម-សេដ្ឋកិច្ច និងស្ថានភាពជីវភាពពលរដ្ឋ អាចបំពេញបន្ថែម និងដែលអាចព្យាករពីផលប៉ះពាល់។<br><br>ប្រភពព័ត៌មាន៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ប.ស.ស., ក្រសួងផែនការ, និងដៃគូអភិវឌ្ឍន៍។ |
| វិបត្តិសុខភាពសាធារណៈ | ប្រសិនបើការរាតត្បាតនៃជំងឺត្រូវបានគ្រប់គ្រងតាមទីតាំងភូមិសាស្ត្រ, ត្រូវផ្តោតលើរាជធានី-ខេត្ត និងឃុំ-សង្កាត់ ដែលទទួលរងផលប៉ះពាល់។សម្រាប់គ្រោះអាសន្ន ដែលរីករាលដាលទ្រង់ទ្រាយធំ (កម្រិតជាតិ/កម្រិតតំបន់/ការរាតត្បាតជាសកល) វិធានការឆ្លើយតប នឹងធ្វើឡើងនៅកម្រិតថ្នាក់ជាតិ ប៉ុន្តែផ្តោតអាទិភាព លើការផ្តល់ការគាំពារទៅតាមភូមិសាស្ត្រដូចខាងក្រោម៖<br>i) ទីតាំងភូមិសាស្ត្រ ជាពិសេស ទីប្រជុំជនដែលប្រមូលផ្តុំដោយគ្រួសារក្រីក្រ, គ្រួសារងាយរងហានិភ័យ, បុគ្គលក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ | បម្រែបម្រួលនៃស្ថានភាពសង្គម-សេដ្ឋកិច្ចដែលបណ្តាលមកពីជំងឺរាតត្បាត នឹងអាចប្រើប្រាស់ ដើម្បីជំរុញការដាក់ចេញវិធានការឆ្លើយតបពីប្រព័ន្ធគាំពារសង្គម មានដូចជា៖<br>– ការកើនឡើងខ្ពស់នៃថ្លៃទំនិញប្រើប្រាស់ប្រចាំថ្ងៃ<br>– ឧស្សាហកម្មសំខាន់ៗ រងឥទ្ធិពលពីការធ្លាក់ចុះនៃសេដ្ឋកិច្ចតំបន់ ឬសកល រួមមានការបាត់បង់ការបញ្ជាទិញ, ការបិទធុរកិច្ច, និងការកាត់បន្ថយចំនួនកម្មករនិយោជិតជាដើម<br>– កំណើនជនចំណាកស្រុកដែលវិលត្រលប់មកវិញ<br>– ការកើនឡើងនៃចំនួនពាក្យស្នើសុំកំណត់ |

| | | |
|---|---|---|
| | ii ) ទីតាំងភូមិសាស្ត្រដែលប្រមូលផ្តុំដោយឧស្សាហកម្មដែលប្រើប្រាស់កម្មករនិយោជិតដែលមានប្រាក់ឈ្នួលទាប, ជំនាញទាប និងទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ<br>iii ) ទីតាំងដែលមានការប្រមូលផ្តុំដោយជនចំណាកស្រុកវិលត្រលប់មកវិញច្រើន។ | អត្តសញ្ញាណគ្រួសារក្រីក្រ<br>– ការកើនឡើងនៃចំនួនសមាជិក ប.ស.ស ដែលមិនបង់ភាគទាន<br>– ការកើនឡើងនៃចំនួនករណីឆ្លងជំងឺ<br>– សេវាសាធារណៈភាគច្រើនមិនដំណើរការ ដោយសារងផលប៉ះពាល់ពីការរាត្បាតនៃជំងឺ<br>– សេចក្តីប្រកាសផ្លូវការថ្នាក់ជាតិអំពីវិបត្តិសុខភាពសាធារណៈ ដោយរាជរដ្ឋាភិបាល ឬក្រសួងសុខាភិបាល។<br>ក្រៅពីសញ្ញាណអាសន្នខាងលើ, ការដាក់ចេញវិធានការបិទខ្ទប់នៅថ្នាក់តំបន់ ឬថ្នាក់ជាតិ ដើម្បីគ្រប់គ្រងការរាតត្បាតនៃជំងឺ និងការសិក្សានានាដែលឆ្លុះបញ្ចាំងអំពីផលប៉ះពាល់ផ្នែកសង្គម-សេដ្ឋកិច្ច និងស្ថានភាពជីវភាពពលរដ្ឋ អាចជួយបំពេញបន្ថែម និងដែលអាចព្យាករណ៍ពីផលប៉ះពាល់។<br><br>ប្រភពព័ត៌មានៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងសុខាភិបាល និងទិន្នន័យពីដៃគូអភិវឌ្ឍន៍។ |

## ៥. សកម្មភាពអាទិភាព

ការបោះជំហានទៅមុខនៃក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន នៅកម្ពុជា និងការដាក់ឱ្យអនុវត្តជម្រើសឧបករណ៍គោលនយោបាយ ដែលបានកំណត់ក្នុងក្របខណ្ឌនេះ ចាំបាច់ត្រូវការការដឹកនាំអនុវត្តពីក្រុមប្រឹក្សាជាតិគាំពារសង្គម ដោយមានកិច្ចសហការយ៉ាងជិតស្និតពីក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ដើម្បីកសាងបណ្តុំជាមូលដ្ឋាន (Building Blocks) នៃក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ដូចបានបង្ហាញនៅក្នុង **រូបភាពទី៣**។

ដើម្បីកសាងបណ្តុំជាមូលដ្ឋានទាំង៥ នៃក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន, សកម្មភាពអាទិភាពត្រូវបានដាក់ចេញក្រោមក្របខណ្ឌនេះ ដើម្បីកសាង និងពង្រឹងផ្នែកនីមួយៗនៃបណ្តុំជាមូលដ្ឋានទាំង៥។ ការដាក់ចេញនូវសកម្មភាពអាទិភាពទាំងនេះ ត្រូវបានធ្វើឡើងដោយមានការវិភាគយ៉ាងល្អិតល្អន់លើលក្ខខណ្ឌអំណោយផលនៃប្រព័ន្ធគាំពារសង្គមបច្ចុប្បន្ន, ភាពខ្វះចន្លោះ និងបញ្ហាប្រឈម ដែលត្រូវដោះស្រាយ និងសកម្មភាពដែលចាំបាច់ត្រូវអនុវត្ត។ សកម្មភាពអាទិភាពដែលបានដាក់ចេញក្រោមក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន នឹងត្រូវចូលរួមសហការអនុវត្តដោយក្រុមប្រឹក្សាជាតិគាំពារសង្គម, ក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ។

**រូបភាពទី៣៖ មូលដ្ឋានគ្រឹះនៃក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន**



## ៥.១ ការរៀបចំក្របខណ្ឌគោលនយោបាយ និងស្ថាប័ន

១. ពិនិត្យ និងពិគ្រោះយោបល់ជាមួយអ្នកជំនាញផ្នែកច្បាប់អំពីភាពចាំបាច់ និងតម្រូវការក្នុងការកែសម្រួលក្របខណ្ឌគតិយុត្តក្នុងប្រព័ន្ធគាំពារសង្គម, ប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ និងហិរញ្ញប្បទានសម្រាប់ហានិភ័យគ្រោះមហន្តរាយ ដើម្បីអាចដាក់បញ្ចូលបន្ថែមនូវកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន។

២. បញ្ចូលកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ទៅក្នុងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម និងបន្តយកចិត្តទុកដាក់ពង្រីកវិសាលភាពគ្របដណ្ដប់នៃកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមដែលមានស្រាប់ ជាពិសេសនៅក្នុងទីតាំងភូមិសាស្ត្រដែលត្រូវបានកំណត់ថាមានហានិភ័យខ្ពស់ ដែលក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្នត្រូវដាក់ចេញវិធានការឆ្លើយតបជាអាទិភាព ក៏ដូចជាពិនិត្យលទ្ធភាពក្នុងការពង្រីកវិសាលភាពគ្របដណ្ដប់ទៅដល់ក្រុមពលរដ្ឋដទៃ។

៣. បញ្ចូលកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្នទៅក្នុងក្របខណ្ឌយុទ្ធសាស្ត្រ និងផែនការជាតិគ្រប់គ្រងគ្រោះមហន្តរាយរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីរៀបចំវិធានការឆ្លើយតបពីប្រព័ន្ធគាំពារសង្គម ឱ្យបានច្បាស់លាស់ និងកាន់តែទូលំទូលាយទៅតាមលំដាប់លំដោយស្របនឹងវិធានការឆ្លើយតបនឹងគ្រោះមហន្តរាយ និងសកម្មភាពស្ដារឡើងវិញ។

៤. រៀបចំយន្តការអនុវត្តកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ននៅកម្ពុជា ដែលនឹងមានតម្រូវការជាតុចូលបច្ចេកទេសជាក់លាក់ ព្រមទាំងកិច្ចសហការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ រួមទាំងស្ថាប័នមនុស្សធម៌ និងដៃគូអភិវឌ្ឍន៍ក្នុងប្រព័ន្ធគាំពារសង្គម ព្រមទាំងសហការជាមួយវិស័យឯកជនក្នុងការសម្របសម្រួល និងពន្លឿនការអនុវត្តកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ននៅកម្ពុជា។

៥. បង្កើតយន្តការស្ថាប័នសម្រាប់សម្របសម្រួល និងកសាងទំនាក់ទំនងរវាងក្រសួង-ស្ថាប័នក្នុងប្រព័ន្ធគាំពារសង្គម និងស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយ ក៏ដូចជាកំណត់តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន ក្នុងការរៀបចំផែនការត្រៀមលក្ខណៈសម្រាប់អនុវត្តក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន និងដាក់ចេញវិធានការឆ្លើយតបសម្រាប់អនាគត។

៦. ធ្វើការវាយតម្លៃលើសមត្ថភាព និងសេវាកម្មរបស់ភ្នាក់ងារផ្ទេរប្រាក់នៅក្នុងភូមិសាស្ត្រដែលមានហានិភ័យខ្ពស់ដោយផ្អែកលើសេណារីយ៉ូនៃការព្យាករដែលបង្កើតឡើងដោយកម្មវិធីស្បៀងអាហារពិភពលោក និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ តាមរយៈប្រព័ន្ធគ្រប់គ្រង និងផ្ដល់ទិន្នន័យទាន់ហេតុការណ៍ (PRISM)។

៧. ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ និងអាជ្ញាធរមូលដ្ឋាន ដើម្បីវាយតម្លៃសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការឆ្លើយតបនឹងគ្រោះអាសន្ន នៅក្នុងទីតាំងភូមិសាស្ត្រដែលមានហានិភ័យខ្ពស់ដោយសហការជាមួយក្រសួងមហាផ្ទៃ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

៨. ពិភាក្សា និងរៀបចំផែនការសម្រាប់កៀរគរ និងបង្កើនសមត្ថភាពធនធានមនុស្សបន្ថែម ដើម្បីអនុវត្តការងារដូចជាការកំណត់អត្តសញ្ញាណគ្រួសារគោលដៅ, ការលើកកម្ពស់ការយល់ដឹង និងសកម្មភាពចុះផ្សព្វផ្សាយដល់មូលដ្ឋាន ដោយសហការជាមួយក្រសួងមហាផ្ទៃ, ក្រសួង-ស្ថាប័នពាក់ព័ន្ធ, និងដៃគូអភិវឌ្ឍន៍ ដើម្បីធានានិរន្តរភាពនៃការអនុវត្តកម្មវិធីគាំពារសង្គម និងការពង្រីកកិច្ចគាំពារសង្គម នៅក្រោយពេលគ្រោះអាសន្ន នៅតាមទីតាំងភូមិសាស្ត្រដែលមានហានិភ័យខ្ពស់។

៩. ពិភាក្សា និងកំណត់យន្តការសម្របសម្រួល សម្រាប់រំហូរហិរញ្ញប្បទានថវិកាក្នុងការអនុវត្តកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ព្រមទាំងកែសម្រួល និងពង្រីកយន្តការដែលបានប្រើប្រាស់សម្រាប់ផ្តល់ហិរញ្ញប្បទាន ដល់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ទៅតាមភាពចាំបាច់ ដោយបញ្ជាក់អំពីថវិកាសម្រាប់បើកផ្តល់អត្ថប្រយោជន៍ និងថវិកាសម្រាប់ចំណាយប្រតិបត្តិការសម្រាប់ការបំពេញការងារបន្ថែម ដូចជាការផ្សព្វផ្សាយ, ការកំណត់អត្តសញ្ញាណតាមការស្នើសុំ, ការលើកកម្ពស់ការយល់ដឹង និងគណនេយ្យភាព។

១០.សហការជាមួយក្រសួងសុខាភិបាល ស្វែងយល់ពីភាពខ្វះចន្លោះ និងវឌ្ឍនភាពនៃការពង្រឹងប្រព័ន្ធសុខាភិបាលនៅតាមមូលដ្ឋានដែលស្ថិតនៅតំបន់អាទិភាព សម្រាប់ការអនុវត្តកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន និងពិភាក្សាអំពីចំណុចដែលត្រូវកែលម្អតាមដែលអាចធ្វើទៅបាន។

## ៥.២ ការរៀបចំយន្តការអនុវត្តកម្មវិធី

១. ប្រែក្លាយប្រព័ន្ធគាំពារសង្គម ទៅជាប្រព័ន្ធមួយមានប្រសិទ្ធភាពដើម្បីបំពេញតម្រូវការក្នុងគ្រាអាសន្ន និងពង្រីកវិសាលភាពគ្របដណ្តប់ ដោយផ្តល់អាទិភាពលើការពង្រីកការគ្របដណ្តប់កម្មវិធីជំនួយសង្គមដែលមានស្រាប់ និងការគ្របដណ្តប់របបសន្តិសុខសង្គមដល់បុគ្គលក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

២. ពិនិត្យ និងវាយតម្លៃលើប្រសិទ្ធភាព និងសុក្រឹត្យភាពនៃយន្តការអត្តសញ្ញាណកម្មគ្រួសារប្រសិទ្ធភាព នៃការរៀបចំយន្តការកំណត់ក្រុមគោលដៅសម្រាប់កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ដោយផ្អែកលើមូលដ្ឋានទិន្នន័យដែលមានស្រាប់ និងកំណត់កត្តានានាដែលចាំបាច់ត្រូវធ្វើការកែសម្រួល ដូចជាការរៀបចំយន្តការ និងដំណើរការអនុវត្ត ជាដើម។

៣. រៀបចំបង្កើតគោលការណ៍ណែនាំ អំពីការកំណត់ក្រុមគោលដៅសម្រាប់ពង្រីកវិសាលភាពគ្របដណ្តប់នៃកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន តាមខ្សែបញ្ឈរ និងការកំណត់ក្រុមគោលដៅគ្រួសារថ្មីៗ តាមប្រភេទ និងកម្រិតធ្ងន់ធ្ងរនៃគ្រោះអាសន្ន។ សម្រាប់ការពង្រីកវិសាលភាពគ្របដណ្តប់តាមខ្សែបញ្ឈរ, ត្រូវរៀបចំគោលការណ៍ណែនាំអំពីស្ថានភាព និងលក្ខខណ្ឌដែលត្រូវផ្តល់អត្ថប្រយោជន៍បន្ថែម ដល់អ្នកទទួលផលនៅក្នុងតំបន់រងផលប៉ះពាល់ និងពិនិត្យមើលបន្ថែមលើភាពងាយរងគ្រោះ។ សម្រាប់ការពង្រីកវិសាលភាពគ្របដណ្តប់តាមខ្សែផ្តេកដល់អ្នកទទួលផលថ្មី, ត្រូវរៀបចំគោលការណ៍ណែនាំអំពីស្ថានភាព និងលក្ខខណ្ឌ ដែលត្រូវផ្តល់អត្ថប្រយោជន៍ដល់ក្រុមគោលដៅថ្មី ដែលមិនមែនជាអ្នក

ទទួលផលក្រោមកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម ក្នុងគ្រាមិនមានអាសន្ន ជាពិសេសគ្រួសារងាយរងហានិភ័យដែលរស់នៅក្បែរបន្ទាត់ភាពក្រីក្រ និងងាយធ្លាក់ចូលក្នុងភាពក្រីក្រវិញពេលជួបគ្រោះអាសន្ន ដោយបច្ចុប្បន្នក្រុមគ្រួសារនេះ ត្រូវបានកំណត់អត្តសញ្ញាណតាមរយៈយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ យុទ្ធសាស្ត្រចាកចេញ ឬបញ្ចប់ការអនុវត្តការពង្រីកវិសាលភាពតាមខ្សែបញ្ឈរ និងខ្សែផ្ដេក មានសារៈសំខាន់ណាស់ និងគួរត្រូវបានគិតគូរបញ្ចូលទៅក្នុងគោលការណ៍ណែនាំ។

៤. សិក្សាលើប្រសិទ្ធភាព និងភាពគ្រប់គ្រាន់នៃកម្រិតប្រាក់ឧបត្ថម្ភ ដែលបានអនុវត្តក្នុងកម្មវិធីជំនួយសង្គមពិសេស ដែលរាជរដ្ឋាភិបាលបានដាក់ឱ្យដំណើរការ ដោយសហការជាមួយស្ថាប័នមនុស្សធម៌ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ព្រមទាំងរៀបចំឱ្យមានមូលដ្ឋានគ្រឹះសម្រាប់កំណត់ "កម្រិតប្រាក់ឧបត្ថម្ភមូលដ្ឋាន" នៃកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន សម្រាប់បំពេញតម្រូវការជាមូលដ្ឋាន ឱ្យមានលក្ខណៈជាប្រព័ន្ធ ដែលជាផ្នែកមួយនៃការរៀបចំផែនការត្រៀមលក្ខណៈ ព្រមទាំងគោលការណ៍ណែនាំអំពីរបៀប និងរយៈពេលដែលអាចដាក់ឱ្យអនុវត្ត និង/ឬកែសម្រួលបន្ថែមនៅក្រោយគ្រោះអាសន្ន។

៥. បន្ទាប់ពីរៀបចំគោលការណ៍ណែនាំសម្រាប់កំណត់ក្រុមគោលដៅ និងកម្រិតអត្ថប្រយោជន៍នៃកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន, ត្រូវរៀបចំគោលការណ៍ណែនាំរួម សម្រាប់សម្របសម្រួលជាមួយស្ថាប័នមនុស្សធម៌ ដើម្បីធ្វើសុខដុមនីយកម្មនៃវិធានការឆ្លើយតបជាសាច់ប្រាក់ ដើម្បីបំពេញបន្ថែមភាពខ្វះចន្លោះនានា។

## ៥.៣ ប្រព័ន្ធបើកផ្តល់

១. ផ្សារភ្ជាប់នឹងផ្នែកប្រព័ន្ធទិន្នន័យ និងព័ត៌មានខាងក្រោម ត្រូវរៀបចំកែសម្រួលនីតិវិធីប្រតិបត្តិស្តង់ដារនៃយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំ ដើម្បីបញ្ចូល និងរក្សាទុកកំណត់ត្រាគ្រួសារទាំងអស់ដែលបានវាយតម្លៃរួច។

២. សិក្សាពីមេរៀន និងបទពិសោធន៍នៃការកែសម្រួលដំណើរការប្រតិបត្តិការនៃកម្មវិធីជំនួយសង្គម និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ និងសម្ពាធអតិផរណា ទៅតាមដំណាក់កាលនីមួយៗនៃខ្សែច្រវាក់មុខងារ រហូតដល់ដំណាក់កាលនៃការបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភ និងទៅតាមកម្រិតនៃស្ថាប័នអនុវត្តកម្មវិធី។

៣. សិក្សាអំពីបទពិសោធន៍ មេរៀនល្អៗ និងបញ្ហាប្រឈម ដែលបានជួបប្រទះកន្លងមកក្នុងបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភជូនគ្រួសារក្រោមកម្មវិធីជំនួយសង្គមពិសេស។

៤. រៀបចំគណនាកញ្ចប់ថវិកាចំណាយសម្រាប់ការអនុវត្តយុទ្ធសាស្ត្រផ្សព្វផ្សាយ សម្រាប់កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ និងកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន។ យុទ្ធសាស្ត្រផ្សព្វផ្សាយ ត្រូវកំណត់សារនយោបាយសំខាន់ៗ ដើម្បីផ្សព្វផ្សាយក្នុងលក្ខខណ្ឌធម្មតា និងបណ្តាញផ្សព្វផ្សាយក្នុងការបញ្ជូនសារនយោបាយទៅកាន់អ្នកទទួលផល ព្រមទាំងការកែសម្រួល ឬបន្ថែមសារនយោបាយសំខាន់ៗ សម្រាប់ផ្សព្វផ្សាយ ក្នុងអំឡុងពេល

គ្រោះអាសន្ន។ ទន្ទឹមនេះ ត្រូវប្រើប្រាស់បណ្តាញ និងមន្ត្រីអនុវត្តកម្មវិធី ដើម្បីធ្វើការទំនាក់ទំនង និងផ្សព្វផ្សាយទៅកាន់ពលរដ្ឋនៅមូលដ្ឋានដើម្បីផ្តល់ភាពងាយស្រួល សម្រាប់ពលរដ្ឋងាយរងគ្រោះ ជាពិសេសស្ត្រី, កុមារ, ជនមានពិការភាព និងជនចាស់ជរា។ ចំណុចគន្លឹះៗ ដែលត្រូវបញ្ចូលទៅក្នុងសារនយោបាយ រួមមាន៖ (១) អ្នកដែលមានលក្ខខណ្ឌវិនិច្ឆ័យគ្រប់គ្រាន់សម្រាប់កម្មវិធី, (២) យន្តការចុះឈ្មោះ, (៣) កម្រិតអត្ថប្រយោជន៍ និងរយៈពេលនៃការផ្តល់អត្ថប្រយោជន៍, (៤) យន្តការសាកសួរព័ត៌មាន ឬបណ្តឹងតវ៉ា និង (៥) ការបញ្ចប់ការអនុវត្តកម្មវិធី។

៥. រៀបចំនីតិវិធីស្តង់ដារប្រតិបត្តិសម្រាប់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ពិសេសបន្ទាន់ ក្នុងគ្រាអាសន្ន ដើម្បីគ្របដណ្តប់គ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ នៅពេលគ្រោះអាសន្ន ដោយប្រើប្រាស់បេកគំហើញនានា និងរៀបចំដោយកែសម្រួលលើនីតិវិធីប្រតិបត្តិស្តង់ដាររបស់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩, កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ និងសម្ពាធអតិផរណា តាមការចាំបាច់។ ការរៀបចំនីតិវិធីប្រតិបត្តិស្តង់ដារ ត្រូវយកចិត្តទុកដាក់លើស្ថានភាព និងបញ្ហាប្រឈមជាក់ស្តែងក្នុងដំណើរការអនុវត្តកម្មវិធី តាមប្រភេទ និងកម្រិតគ្រោះអាសន្ន។

៦. រៀបចំសៀវភៅណែនាំស្តង់ដារប្រតិបត្តិរបស់ក្របខណ្ឌកញ្ចប់គ្រួសារ ត្រូវបញ្ចូល និងកំណត់នីតិវិធី ដូចជា៖ (១) ការកែសម្រួលយន្តការ និងការអនុវត្តកម្មវិធីនៅពេលគ្រោះអាសន្ន និងកំណត់នីតិវិធីសម្រាប់ការផ្សព្វផ្សាយទៅដល់អ្នកទទួលផល, (២) ដំណើរការបញ្ជ្រាបការយល់ដឹង ត្រូវធ្វើឡើងឱ្យបានទូលំទូលាយ, ការចុះដល់មូលដ្ឋាន និងការចុះបញ្ជីរហ័សសម្រាប់ការពង្រីកវិសាលភាពគ្របដណ្តប់តាមខ្សែផ្តេក និង (៣) ការបញ្ជ្រាបការយល់ដឹង និងការផ្ទៀងផ្ទាត់នៅក្រោយគ្រោះអាសន្នតាមការចាំបាច់ សម្រាប់ការពង្រីកវិសាលភាពគ្របដណ្តប់តាមខ្សែបញ្ឈរ។

៧. ពង្រឹងមូលដ្ឋានគ្រឹះនៃប្រព័ន្ធបើកផ្តល់របស់ប្រព័ន្ធគាំពារសង្គម ដើម្បីបង្កើនប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព និងគណនេយ្យភាពនៃកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមដែលមានស្រាប់ និងកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន។

៨. រៀបចំនីតិវិធីស្តង់ដារប្រតិបត្តិ សម្រាប់កម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ដើម្បីណែនាំអំពីការផ្លាស់ប្តូរការផ្តល់អាហារតាមសាលារៀនទៅជាការផ្តល់ស្បៀងយកទៅចម្អិននៅតាមផ្ទះ នៅពេលបិទសាលារៀន។ ការរៀបចំនីតិវិធីនេះ ត្រូវផ្អែកលើនីតិវិធីស្តង់ដារប្រតិបត្តិ ដែលបានរៀបចំក្នុងអំឡុងពេលនៃរាតត្បាតនៃជំងឺកូវីដ-១៩ កាលពីឆ្នាំ២០២០ ព្រមទាំងបញ្ចូលកិច្ចការមួយចំនួន ដូចជា (១) នីតិវិធីទំនាក់ទំនង និងផ្សព្វផ្សាយទៅកាន់គ្រួសារ ដែលត្រូវបានបញ្ចូលក្នុងបញ្ជីផ្តល់របបស្បៀងទៅចម្អិននៅតាមផ្ទះ និង (២) វិធីសាស្ត្រក្នុងការធានាបាននូវចំនួនកុមារដែលត្រូវទទួលអត្ថប្រយោជន៍ពីកម្មវិធីឱ្យបានជាអតិបរមា តាមរយៈការធានាឱ្យមានការបន្ត និងបំពេញបន្ថែមនៃខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងពេលគ្រោះអាសន្ន។

៩. រៀបចំយន្តការតាមដាន និងវាយតម្លៃកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្នដើម្បីបញ្ចូលទៅក្នុងក្របខណ្ឌយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម ព្រមទាំងដាក់ចេញសូចនាករថ្មីៗ តាមការចាំបាច់។

១០. ដាក់ឱ្យអនុវត្តសាកល្បងកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្នថ្មីៗ នៅក្នុងឃុំ-សង្កាត់អាទិភាព ដោយមានយន្តការតាមដាន និងត្រួតពិនិត្យយ៉ាងត្រឹមត្រូវ ដើម្បីទាញយកមេរៀន ឬបទពិសោធន៍ពីការអនុវត្តសាកល្បងនេះ។

១១.សម្រាប់កម្មវិធីជំនួយសង្គមថ្មីៗ ដែលនឹងត្រូវបង្កើតនៅពេលអនាគត, ត្រូវរៀបចំនីតិវិធីស្តង់ដារប្រតិបត្តិ សម្រាប់កម្មវិធីទាំងនេះ ដោយបញ្ចូលសមាសធាតុការឆ្លើយតបនឹងគ្រោះអាសន្ន ដើម្បីធានាថាកិច្ចដំណើរការកម្មវិធីមានភាពធន់នឹងគ្រោះអាសន្ន និងការផ្តល់ជំនួយឧបត្ថម្ភត្រូវធ្វើឡើងទៅតាមវិធីសាស្ត្រសមស្របបំផុត ទាំងក្នុងអំឡុងពេលគ្រោះអាសន្ន និងនៅក្រោយពេលគ្រោះអាសន្ន។

១២.នៅពេលមានការពង្រីកការចុះបញ្ជីសមាជិករបស់ ប.ស.ស. ដើម្បីបញ្ចូលបុគ្គលក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងការរៀបចំប្រព័ន្ធអន្តរប្រតិបត្តិការសម្រាប់ពេលអនាគត, ត្រូវរៀបចំនីតិវិធីបន្ថែមសម្រាប់កម្មវិធីឧបត្ថម្ភសាច់ប្រាក់បន្ទាន់ក្នុងគ្រាអាសន្ន ដូចជាការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងការកំណត់អត្តសញ្ញាណសមាជិក ប.ស.ស. ដែលស្ថិតក្នុងក្រុមងាយរងគ្រោះ ដើម្បីផ្តល់ការឧបត្ថម្ភគាំទ្រ (ផ្អែកតាមវិស័យដែលរងផលប៉ះពាល់)។

## ៥.៤ ប្រព័ន្ធទិន្នន័យ និងព័ត៌មាន

១. ការរៀបចំយុទ្ធសាស្ត្រសម្រាប់ធ្វើការកែទម្រង់ និងធ្វើសមាហរណកម្មមូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គមរវាងកម្មវិធីរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដោយនឹងមានការរួមបញ្ចូលនូវ៖ (១) ការធ្វើបរិវត្តកម្មមូលដ្ឋានទិន្នន័យគ្រួសារក្រីក្រ ឱ្យទៅជាសំណុំមូលដ្ឋានទិន្នន័យចុះបញ្ជីសង្គម ដើម្បីរក្សាទុកកំណត់ត្រា និងពិន្ទុនៃភាពក្រីក្រសម្រាប់គ្រួសារ ដែលត្រូវបានវាយតម្លៃក្រោមយន្តការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រតាមការស្នើសុំ, (២) ការកំណត់កម្រិតវាស់វែងភាពក្រីក្រ ឬស្ថានភាពជីវភាពរបស់គ្រួសារដែលមានក្នុងប្រព័ន្ធ សម្រាប់ប្រើប្រាស់ក្នុងការអនុវត្តកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន, (៣) ការបង្កើតការតភ្ជាប់ប្រព័ន្ធចុះបញ្ជីផ្សេងៗជាមួយនឹងមូលដ្ឋានទិន្នន័យគាំពារសង្គមថ្នាក់ជាតិ ដើម្បីធានាបាននូវការធ្វើអន្តរប្រតិបត្តិការនៃមូលដ្ឋានទិន្នន័យគាំពារសង្គម ដែលប្រើប្រាស់សម្រាប់ឆ្លើយតបនឹងគ្រោះអាសន្ន ជាមួយនឹងកម្មវិធីគាំពារសង្គមផ្សេងទៀត។

២. កំណត់នីតិវិធីដែលអាចឱ្យមូលដ្ឋានទិន្នន័យរបស់ដៃគូអភិវឌ្ឍន៍ អាចមានតំណភ្ជាប់ជាមួយមូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គម ខណៈធានាឱ្យបាននូវការការពារទិន្នន័យ ដើម្បីពង្រីកការគ្របដណ្តប់ពលរដ្ឋនៅក្នុងមូលដ្ឋានទិន្នន័យគាំពារសង្គម ក៏ដូចជាសម្រួលដល់ការកំណត់អត្តសញ្ញាណរហ័សដល់ក្រុមពលរដ្ឋក្រីក្រ និងងាយរងគ្រោះ។

៣. សហការជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ដើម្បីស្វែងរកវិធីសាស្ត្រក្នុងការធ្វើសមាហរណឧបករណ៍វាយតម្លៃគ្រោះមហន្តរាយ របស់គណៈកម្មាធិការគ្រប់គ្រងមហន្តរាយថ្នាក់រាជធានី-ខេត្ត ដើម្បីផ្តល់ជាអំណះអំណាង សម្រាប់

កំណត់ក្រុមគោលដៅនៃកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន និងបញ្ជាក់ពីតម្រូវការ វិធានការឆ្លើយតបនឹងគ្រោះអាសន្នពីប្រព័ន្ធគាំពារសង្គម ដោយរៀបចំឱ្យមានស្តង់ដាររួម សម្រាប់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់រាជធានី-ខេត្ត ធ្វើការវាយតម្លៃលើ គ្រួសារដែលទទួលរងផលប៉ះពាល់។ ក្នុងករណីចាំបាច់ បង្កើតមុខងារ ឬប្រព័ន្ធបញ្ចូល ទិន្នន័យផលប៉ះពាល់ពីគ្រោះអាសន្ន ដែលអនុវត្តដោយគណៈកម្មាធិការគ្រប់គ្រងមហន្តរាយ ថ្នាក់រាជធានី-ខេត្តទូទាំងប្រទេស និងបញ្ជូនទិន្នន័យមកប្រព័ន្ធថ្នាក់ជាតិ ដែលតភ្ជាប់ជាមួយ មូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គម។

៤. ពង្រឹងភាពជាដៃគូជាមួយនឹងក្រសួងផែនការ, គណៈកម្មាធិការជាតិគ្រប់គ្រងមហន្តរាយ និងដៃគូអភិវឌ្ឍន៍ ក្រោមការសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារ សង្គម ដើម្បីរៀបចំបង្កើតតំណភ្ជាប់មុខងារទាញយកទិន្នន័យដោយស្វ័យប្រវត្តិ (API) ជាមួយ ប្រព័ន្ធគ្រប់គ្រង និងផ្តល់ទិន្នន័យទាន់ពេល (PRISM) ដើម្បីផ្តល់លក្ខណៈងាយស្រួល ដល់ការវិភាគអំពីទំហំនៃផលប៉ះពាល់ជាមួយនឹងភាពងាយរងគ្រោះផ្នែកសង្គម-សេដ្ឋកិច្ច ដោយចាប់ផ្តើមពីមូលដ្ឋានទិន្នន័យគាំពារសង្គម និងមូលដ្ឋានទិន្នន័យគ្រួសារក្រីក្រ។ បន្ថែម លើនេះ ប្រើប្រាស់ការវិភាគរបស់ប្រព័ន្ធគ្រប់គ្រង និងផ្តល់ទិន្នន័យទាន់ពេល (PRISM) ដើម្បីកំណត់ឃុំ-សង្កាត់អាទិភាព ដើម្បីរៀបចំត្រៀមដាក់ឱ្យអនុវត្តសាកល្បងកិច្ចគាំពារ សង្គមឆ្លើយតបនឹងគ្រោះអាសន្ន និងបង្កើតសេណារីយ៉ូទៅតាមកម្រិត និងភាពធ្ងន់ធ្ងរខុស ៗគ្នានៃគ្រោះទឹកជំនន់ ដើម្បីជាជំនួយដល់ការរៀបចំផែនការត្រៀមលក្ខណៈ នៅក្នុង ទីតាំងភូមិសាស្ត្រអាទិភាព។ សេណារីយ៉ូទាំងនេះ នឹងត្រូវបានប្រើប្រាស់ដើម្បីផ្តល់អំណះ អំណាងសម្រាប់រៀបចំម៉ូដែលតម្រូវការហិរញ្ញវត្ថុ សម្រាប់កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះ អាសន្ន។ តំណភ្ជាប់មុខងារទាញយកទិន្នន័យដោយស្វ័យប្រវត្តិ (API) នឹងទិន្នន័យទាន់ ហេតុការណ៍, ទិន្នន័យផលប៉ះពាល់នៃគ្រោះមហន្តរាយ និងទិន្នន័យពាក់ព័ន្ធផ្សេងៗ មាន សារៈសំខាន់យ៉ាងខ្លាំង ដើម្បីធានាថាវិធានការឆ្លើយតបនឹងគ្រោះអាសន្នមានប្រសិទ្ធភាព និងត្រូវបានដាក់ចេញទាន់ពេល។

៥. សហការជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងមហន្តរាយ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ រៀបចំ និងអភិវឌ្ឍប្រព័ន្ធតាមដានតម្លៃលើទីផ្សារ និងវាយតម្លៃស្ថានភាពបន្ទាប់ពីគ្រោះអាសន្ន។

៦. ធានាឱ្យបាននូវការបញ្ជ្រាបការយល់ដឹង និងពង្រឹងសមត្ថភាពរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អំពីសូចនាករសំខាន់ៗ សម្រាប់ប្រព័ន្ធប្រកាសអាសន្នអំពីគ្រោះរាំងស្ងួតដែលនឹងត្រូវបាន កំណត់ និងប្រើប្រាស់ជាបុរេលក្ខខណ្ឌសម្រាប់រៀបចំ និងអភិវឌ្ឍប្រព័ន្ធប្រកាសអាសន្ន ព្រមទាំងរៀបចំដាក់ឱ្យអនុវត្តសាកល្បង និងបញ្ចូលទៅក្នុងក្របខណ្ឌកិច្ចគាំពារសង្គម ឆ្លើយតបនឹងគ្រោះអាសន្ន។

៧. កំណត់សូចនាករសំខាន់ៗសម្រាប់តាមដាន និងប្រកាសអាសន្នអំពីវិបត្តិម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងវិបត្តិសុខភាពសាធារណៈ ដែលតម្រូវឱ្យមានវិធានការឆ្លើយតបពី ប្រព័ន្ធគាំពារសង្គម និងរៀបចំយន្តការតាមដាន និងវាយតម្លៃគ្រោះអាសន្នជាប្រចាំ តាម រយៈការសម្របសម្រួលទិន្នន័យពីប្រភពផ្សេងៗគ្នា។

## ៥.៥ យន្តការហិរញ្ញប្បទាន

១. ត្រួតពិនិត្យគម្រោងចំណាយដែលនឹងកើតឡើងនាពេលខាងមុខ និងបង្កើតប្រព័ន្ធព្យាករណ៍តម្រូវការហិរញ្ញប្បទានសម្រាប់កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន និងតម្រូវការហិរញ្ញប្បទានសម្រាប់រយៈពេល ១០ឆ្នាំទៅមុខ។ ការព្យាករណ៍តម្រូវការហិរញ្ញប្បទាននេះអាចចាប់ផ្តើមពីវិធានការឆ្លើយតបនឹងគ្រោះទឹកជំនន់ ដែលតែងកើតឡើងរៀងរាល់ឆ្នាំ។ តម្រូវការថវិកាប៉ាន់ស្មាននេះ គួរត្រូវបានគ្រោងក្នុងច្បាប់ថវិកាប្រចាំឆ្នាំ សម្រាប់ឆ្លើយតបនឹងគ្រោះទឹកជំនន់ដែលអាចកើតឡើង ឬវិភាជក្នុងមូលនិធិពិសេសជាក់លាក់ សម្រាប់ប្រើប្រាស់ក្នុងក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន។

២. សហការជាមួយនឹងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធស្វែងរកការគាំទ្រ ដើម្បីទទួលបានការវិភាជថវិកាត្រៀមបម្រុងនៃថវិកាជាតិសម្រាប់គ្រប់គ្រងគ្រោះមហន្តរាយ។

៣. សិក្សាលើការជំរុញបរិយាបន្នកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន នៅក្នុងយុទ្ធសាស្ត្រហិរញ្ញប្បទានសម្រាប់ហានិភ័យគ្រោះមហន្តរាយ។ បន្ថែមពីនេះ ប្រើប្រាស់សេណារីយ៉ូ និងម៉ូដែលសម្រាប់គណនាចំណាយ ដើម្បីរៀបចំយុទ្ធសាស្ត្រហិរញ្ញប្បទានសម្រាប់អនុវត្តជម្រើសឧបករណ៍គោលនយោបាយគាំពារសង្គម ដើម្បីឆ្លើយតបនឹងគ្រោះអាសន្ន រួមទាំងបន្ទុកចំណាយលើការរៀបចំយន្តការអនុវត្ត, បន្ទុកចំណាយលើប្រតិបត្តិការ និងបន្ទុកចំណាយលើរបបឧបត្ថម្ភ សម្រាប់គ្រោះអាសន្នកម្រិតខ្ពស់ ដែលកើតឡើងញឹកញាប់, គ្រោះអាសន្នធ្ងន់ធ្ងរកម្រិតទាប, ព្រមទាំងហេតុការណ៍ដែលកើតឡើងរៀងរាល់ប្រាំឆ្នាំម្តង និងដប់ឆ្នាំម្តង។ ការសិក្សានេះគួរគិតគូរទៅដល់គ្រប់ជម្រើសប្រភពហិរញ្ញប្បទាន ដែលសមស្រប រួមទាំងឧបករណ៍ហិរញ្ញប្បទានហានិភ័យគ្រោះមហន្តរាយ។

៤. សិក្សាលទ្ធភាពចូលជាសមាជិករបស់ចលនាភាពជាដៃគូសកល និងគំនិតផ្តួចផ្តើមក្នុងតំបន់ពាក់ព័ន្ធ ដើម្បីទទួលបានបច្ចុប្បន្នភាពនៃមូលនិធិសកលសម្រាប់កិច្ចគាំពារសង្គម និងវឌ្ឍនភាពពាក់ព័ន្ធដទៃទៀត ក៏ដូចជាទាញយកសក្តានុពលសម្រាប់ប្រទេសកម្ពុជាពីចលនានេះ ដើម្បីគាំទ្រដល់ការពង្រីកការគ្របដណ្តប់នៃប្រព័ន្ធគាំពារសង្គម និងគាំទ្រការអនុវត្តកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន។

# ៦. តួនាទី និងយន្តការសម្របសម្រួលរវាងក្រសួង-ស្ថាប័ន

## ៦.១ តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន

កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន មានលក្ខណៈពហុវិស័យ។ ក្រសួង-ស្ថាប័ន ទាំងក្នុងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ មានតួនាទីសំខាន់ក្នុងការអនុវត្តក្របខណ្ឌនេះ។ តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ននឹងត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត តាមការជាក់ស្តែង។

**តារាងទី៣៖ តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន**

| ក្រសួង-ស្ថាប័ន | តួនាទី និងការទទួលខុសត្រូវក្នុងក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន |
|---|---|
| ក្រុមប្រឹក្សាជាតិគាំពារសង្គម | – រៀបចំ និងដាក់ចេញគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ក្របខណ្ឌ និងលិខិតបទដ្ឋានគតិយុត្ត<br>– គ្រប់គ្រង សម្របសម្រួល និងតម្រង់ទិសក្នុងការរៀបចំផែនការត្រៀមលក្ខណៈ និងយន្តការអនុវត្តកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន<br>– សម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍លើការរៀបចំផែនការ និងអនុវត្តកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន តាមរយៈយន្តការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គម<br>– ដឹកនាំសម្របសម្រួលកិច្ចពិភាក្សាថវិកា និងគ្រប់គ្រងថវិកាសម្រាប់កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន<br>– តាមដាន ត្រួតពិនិត្យការអនុវត្ត និងវាយតម្លៃវឌ្ឍនភាពកម្មវិធី និងរបបគាំពារសង្គម<br>– សហការជាមួយក្រសួង-ស្ថាប័នមានសមត្ថកិច្ច ពិនិត្យតាមដានអំពីបម្រែបម្រួលនៃសូចនាករ ដែលជាសញ្ញាណព្រមាន អំពីគ្រោះមហន្តរាយធម្មជាតិ, វិបត្តិម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងវិបត្តិសុខភាពសាធារណៈ ដែលតម្រូវឱ្យមានវិធានការឆ្លើយតបពីប្រព័ន្ធគាំពារសង្គម។ |
| គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | – ដឹកនាំការរៀបចំផែនទីនៃទីតាំងភូមិសាស្ត្រដែលមានហានិភ័យខ្ពស់ និងរៀបចំសេណារីយ៉ូ តាមរយៈប្រព័ន្ធគ្រប់គ្រង និងផ្តល់ទិន្នន័យទាន់ពេល (PRISM)<br>– ដឹកនាំកំណែទម្រង់អភិបាលកិច្ចក្នុងការដាក់ចេញវិធានការឆ្លើយតបនឹងគ្រោះមហន្តរាយដើម្បីគាំទ្រដល់ការអនុវត្តកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្នសម្រាប់គ្រោះមហន្តរាយធម្មជាតិ<br>– គ្រប់គ្រង និងវិភាគទិន្នន័យពីប្រព័ន្ធប្រកាសអាសន្ន (EWS), ចែករំលែកទិន្នន័យជាមួយអនុគណៈកម្មាធិការកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន និងប្រកាសភាពអាសន្នដើម្បីដាក់ចេញវិធានការកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្នសម្រាប់គ្រោះមហន្តរាយធម្មជាតិ<br>– ធានាឱ្យបាននូវការបញ្ចូលវិធានការឆ្លើយតបជាសាច់ប្រាក់ តាមរយៈកិច្ចគាំពារសង្គមទៅក្នុងផែនការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |

| | |
|---|---|
| | – ប្រមូលផ្តុំវិធានការរបស់គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ ដើម្បីគាំទ្រការអនុវត្តកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន តាមការចាំបាច់។ |
| ក្រសួងមហាផ្ទៃ | – កែលម្អបទដ្ឋានគតិយុត្ត ដើម្បីបង្កើនប្រសិទ្ធភាពតួនាទីរបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការអនុវត្តកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន<br>– ធានាអនុលោមភាពនៃការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមបទដ្ឋានគតិយុត្តដែលមានជាធរមាន<br>– កសាងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រការអនុវត្តកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ដោយសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>– ពង្រឹងយន្តការត្រួតពិនិត្យ នៅកម្រិតថ្នាក់ក្រោមជាតិ និងសហការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី។ |
| ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | – វិភាជថវិកា និងគិតគូរអំពីថវិកាត្រៀមបម្រុងជាក់លាក់ សម្រាប់ពង្រីកវិសាលភាពគ្របដណ្តប់កម្មវិធី និងរបបគាំពារសង្គមដែលមានស្រាប់ និងសម្រាប់ពង្រីកវិសាលភាពគ្របដណ្តប់កិច្ចគាំពារសង្គម ឆ្លើយតបនឹងគ្រោះអាសន្ន ផ្អែកលើសេណារីយ៉ូនីមួយៗ<br>– ពិភាក្សាអំពីហិរញ្ញប្បទានសម្រាប់ហានិភ័យគ្រោះមហន្តរាយ<br>– ត្រួតពិនិត្យរបាយការណ៍អនុវត្តថវិកា និងលទ្ធផលនៃការអនុវត្តកម្មវិធី។ |
| ក្រសួងផែនការ | – ដឹកនាំរៀបចំកែសម្រួលយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ តាមការស្នើសុំ និងពង្រីកវិសាលភាពទៅគ្របដណ្តប់គ្រួសារងាយរងហានិភ័យដែលរស់នៅក្បែរបន្ទាត់ភាពក្រីក្រ និងក្រុមគោលដៅផ្សេងៗទៀត តាមការសម្រេចរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម<br>– ធានានូវការទទួលបានទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យសម្រាប់ ក្រសួង-ស្ថាប័នពាក់ព័ន្ធ តាមការចាំបាច់សម្រាប់អនុវត្តជម្រើសឧបករណ៍គោលនយោបាយគាំពារសង្គម ក្នុងការឆ្លើយតបនឹងគ្រោះអាសន្នប្រកបដោយប្រសិទ្ធភាព។ |
| ក្រសួងអប់រំ យុវជន និងកីឡា | – ដឹកនាំការរៀបចំផែនការផ្លាស់ប្តូរកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ទៅជាការចែកស្បៀងយកទៅចម្អិននៅតាមផ្ទះ និងពង្រឹងខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងពេលគ្រោះអាសន្ន។ |
| ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | – រៀបចំបទដ្ឋានគតិយុត្ត និងកែសម្រួលនីតិវិធីស្តង់ដារប្រតិបត្តិ តាមការចាំបាច់សម្រាប់ការលើកលែងការបង់ភាគទានរបស់សមាជិកបេឡាជាតិសន្តិសុខសង្គម ក្នុងពេលគ្រោះអាសន្ន<br>– ដឹកនាំការរៀបចំយន្តការអនុវត្ត និងនីតិវិធីស្តង់ដារប្រតិបត្តិសម្រាប់ការពង្រីកវិសាលភាពគ្របដណ្តប់របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ទៅដល់ក្រុមគោលដៅផ្សេងក្នុងពេលមានគ្រោះអាសន្ន |

| | |
|---|---|
| | – ដឹកនាំរាល់សកម្មភាពពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់បន្ទាន់ដែលផ្តោតលើក្រុមគោលដៅ ដែលជាកម្មករនិយោជិត និងបុគ្គលក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលបម្រើការក្នុងវិស័យរងផលប៉ះពាល់ដោយគ្រោះអាសន្ន។ |
| ក្រសួងសុខាភិបាល | – ចែករំលែកទិន្នន័យ អំពីចំនួនករណីនៃការផ្តល់សេវាថែទាំសុខភាព នៅក្នុងទីតាំងភូមិសាស្ត្រអាទិភាព សម្រាប់ការអនុវត្តកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន<br>– ពង្រឹង និងកែលម្អប្រព័ន្ធផ្តល់សេវាសុខាភិបាលនៅតាមទីតាំងភូមិសាស្ត្រអាទិភាព<br>– ដឹកនាំការរៀបចំយុទ្ធសាស្ត្រ និងការតាមដាន និងត្រួតពិនិត្យ ដើម្បីស្វែងយល់អំពីការបំពេញមុខងាររបស់មូលនិធិសមធម៌សុខាភិបាល និងការប្រើប្រាស់មូលនិធិសមធម៌សុខាភិបាលក្នុងចំណោមគ្រួសារមានបណ្ណសមធម៌ ក្នុងពេលមានគ្រោះអាសន្ន។ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | – គាំទ្រដល់ការរៀបចំផែនការត្រៀមលក្ខណៈ សម្រាប់ការពង្រីកប្រព័ន្ធបើកផ្តល់សាច់ប្រាក់ក្នុងពេលមានគ្រោះអាសន្ន<br>– គាំទ្រមូលនិធិជាតិជំនួយសង្គមក្នុងការរៀបចំបទដ្ឋានគតិយុត្តិ, នីតិវិធីស្តង់ដារប្រតិបត្តិ និងយន្តការអនុវត្តជម្រើសឧបករណ៍គោលនយោបាយគាំពារសង្គម ដើម្បីឆ្លើយតបនឹងគ្រោះអាសន្ន ដែលមានលក្ខណៈជាការឧបត្ថម្ភសាច់ប្រាក់<br>– គាំទ្រ និងជំរុញការអនុវត្តកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ដែលមានលក្ខណៈជាការឧបត្ថម្ភសាច់ប្រាក់ ដែលអនុវត្តដោយមូលនិធិជាតិជំនួយសង្គម<br>– តាមដានត្រួតពិនិត្យរាល់សកម្មភាពក្រោមកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ដែលអនុវត្តដោយមូលនិធិជាតិជំនួយសង្គម<br>– ផ្តល់អនុសាសន៍ដល់មូលនិធិជាតិជំនួយសង្គមក្នុងការដោះស្រាយវិវាទទាំងឡាយកើតឡើងក្នុងដំណាក់កាលនៃការអនុវត្តកម្មវិធី មុនពេលបញ្ជូនទៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។ |
| ក្រសួងកិច្ចការនារី | – ផ្តល់យោបល់ និងអនុសាសន៍អំពីយេនឌ័រ ទៅក្នុងការគិតគូរវិធានការអន្តរាគមន៍នានា ដើម្បីឆ្លើយតបនឹងគ្រោះអាសន្ន<br>– ផ្តល់ធាតុចូលដើម្បីធានាឱ្យមានប្រសិទ្ធភាពក្នុងការចែករំលែកព័ត៌មាន និងបទពិសោធន៍លើការបញ្ជ្រាបយេនឌ័រ ក្នុងការអនុវត្តកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន តាមការចាំបាច់<br>– ចូលរួមសហការពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ ពាក់ព័ន្ធនឹងការបញ្ជ្រាបយេនឌ័រ និងតួនាទីរបស់ស្ត្រីក្នុងការឆ្លើយតបនឹងការគ្រប់គ្រងគ្រោះអាសន្ន។ |
| បេឡាជាតិសន្តិសុខសង្គម | – ពង្រឹង និងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធបើកផ្តល់របបសន្តិសុខសង្គមដែលមានស្រាប់ សម្រាប់អនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ដើម្បីធានាឱ្យបាននូវប្រក្រតីភាពលើការបើកផ្តល់ក្នុងពេលមានគ្រោះអាសន្ន<br>– តាមដាន និងផ្តល់ព័ត៌មាន អំពីការកើនឡើងចំនួនករណីនៃការផ្អាកបង់ភាគទានរបបសន្តិសុខសង្គម ដែលជាសញ្ញាណគ្រោះអាសន្ន ដែលតម្រូវឱ្យមានវិធានការឆ្លើយតបពីប្រព័ន្ធគាំពារសង្គម |

| | |
|---|---|
| | – សិក្សា និងវិភាគ អំពីហានិភ័យហិរញ្ញវត្ថុ និងម៉ូដែលហិរញ្ញវត្ថុ ដើម្បីជាមូលដ្ឋានក្នុងការពិនិត្យ និងសម្រេចកាត់បន្ថយ ឬលើកលែងការបង់ភាគទានរបស់សមាជិកក្នុងពេលមានគ្រោះអាសន្ន<br>– រៀបចំផែនការត្រៀមលក្ខណៈ សម្រាប់ការពង្រីកវិសាលភាពគ្របដណ្តប់របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពដល់ក្រុមគោលដៅផ្សេង<br>– អនុវត្តការពង្រីកវិសាលភាពគ្របដណ្តប់របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពដល់ក្រុមគោលដៅផ្សេង និងផ្សព្វផ្សាយអំពីការលើកលែងការបង់ភាគទានក្នុងពេលគ្រោះអាសន្ន<br>– ធានានូវការទទួលបានទិន្នន័យចំនួនសមាជិក ក្រោមរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព តាមការចាំបាច់ សម្រាប់ការអនុវត្តជម្រើសឧបករណ៍គោលនយោបាយគាំពារសង្គម ដើម្បីឆ្លើយតបនឹងគ្រោះអាសន្ន ប្រកបដោយប្រសិទ្ធភាព<br>– តាមដានលើផលប៉ះពាល់នៃការលើកលែង ឬកាត់បន្ថយការបង់ភាគទានរបស់សមាជិកក្រោមរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ព្រមទាំងដឹកនាំកិច្ចពិភាក្សាអំពីការដាក់ចេញវិធានការកែតម្រូវ ដោយសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ។ |
| មូលនិធិជាតិជំនួយសង្គម | – រៀបចំផែនការ និងក្រមប្រតិបត្តិកម្មវិធីសម្រាប់ការពង្រីកប្រព័ន្ធបើកផ្តល់សាច់ប្រាក់ក្នុងពេលមានគ្រោះអាសន្ន<br>– ពង្រឹង និងពង្រីកប្រព័ន្ធបើកផ្តល់ ដើម្បីធានាប្រក្រតីភាពនៃការបើកផ្តល់សម្រាប់កម្មវិធីគាំពារសង្គមដែលមានស្រាប់ក្នុងពេលមានគ្រោះអាសន្ន<br>– រៀបចំផែនការអន្តរាគមន៍ និងឆ្លើយតបសម្រាប់កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន នៅតាមទីតាំងភូមិសាស្ត្រអាទិភាព<br>– អនុវត្តជម្រើសឧបករណ៍គោលនយោបាយគាំពារសង្គម ដើម្បីឆ្លើយតបនឹងគ្រោះអាសន្ន ដែលមានលក្ខណៈជាការឧបត្ថម្ភសាច់ប្រាក់<br>– ធានាដល់ការអនុវត្តជាបរិយាបន្ននូវប្រព័ន្ធឌីជីថល និងហិរញ្ញវត្ថុសម្រាប់កម្មវិធីឆ្លើយតបនឹងគ្រោះអាសន្ន ដែលមានលក្ខណៈជាការឧបត្ថម្ភសាច់ប្រាក់<br>– រៀបចំផែនការគ្រប់គ្រង ផែនការប៉ាន់ប្រមាណតម្រូវការ និងផែនទីសេវាក្នុងការអន្តរាគមន៍ជំនួយសង្គម ដើម្បីឆ្លើយតបនឹងគ្រោះអាសន្ន។ |

## ៦.២ យន្តការសម្របសម្រួលសម្រាប់កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន

យន្តការសម្របសម្រួលសម្រាប់កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ត្រូវបានរៀបចំឡើងដោយផ្អែកលើក្របខណ្ឌសម្របសម្រួលអន្តរក្រសួង-ស្ថាប័នដែលមានស្រាប់ក្នុងប្រព័ន្ធគាំពារសង្គម និងការគ្រប់គ្រងគ្រោះមហន្តរាយ ព្រមទាំងក្របខណ្ឌសម្របសម្រួលរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នៅក្នុងប្រព័ន្ធគាំពារសង្គម។ យន្តការនេះ មានភាពចាំបាច់ក្នុងការកសាងអន្តរទំនាក់ទំនងក្រសួង-ស្ថាប័នរវាងប្រព័ន្ធគាំពារសង្គម និងការគ្រប់គ្រងគ្រោះមហន្តរាយ ព្រមទាំងធានាឱ្យបាននូវការចូលរួមរបស់ក្រសួង-ស្ថាប័ន ដែលមានតួនាទី និងការទទួលខុសត្រូវក្នុងការរៀបចំផែនការ និងការអនុវត្តកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន។

### ៦.២.១ យន្តការសម្របសម្រួលអន្តរក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល

យន្តការសម្របសម្រួលសម្រាប់កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ននឹងត្រូវធ្វើសមាហរណ័ទៅក្នុងក្របខណ្ឌស្ថាប័នដែលមានស្រាប់ សម្រាប់កិច្ចសម្របសម្រួលក្នុងប្រព័ន្ធគាំពារសង្គម ខណៈជានាឱ្យបាននូវការភ្ជាប់ទំនាក់ទំនងជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។ យន្តការសម្របសម្រួលនេះ នឹងធានាឱ្យមានការបញ្ចូលកិច្ចគាំពារសង្គម ជាមុខងារដែលមានការទទួលស្គាល់សម្រាប់ការត្រៀមលក្ខណៈ និងដាក់ចេញវិធានការឆ្លើយតបគ្រោះមហន្តរាយ ព្រមទាំងបំពេញបន្ថែមទៅនឹងមុខងារគ្រប់គ្រងគ្រោះមហន្តរាយ ដែលមានស្រាប់របស់រាជរដ្ឋាភិបាល។ យន្តការនេះ ស្ថិតក្រោមការដឹកនាំ និងតម្រង់ទិសរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ដែលក្នុងនោះគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក៏ត្រូវបានស្នើឱ្យមានសមាសភាពដើម្បីចូលរួមក្នុងគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គមផងដែរ។ ទន្ទឹមនេះ អនុគណៈកម្មាធិការកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្នមួយអាចនឹងត្រូវបានបង្កើតឡើង ដើម្បីបំពេញតួនាទីជាសេនាធិការរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។ អនុគណៈកម្មាធិការនេះ គួរដឹកនាំដោយក្រសួង-ស្ថាប័ន ដែលនឹងត្រូវជ្រើសរើសដោយប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។ តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់នឹងត្រូវបញ្ចូលជាសមាជិកនៃអនុគណៈកម្មាធិការនេះ។

**រូបភាពទី៤៖ ក្របខណ្ឌសម្របសម្រួលស្ថាប័នសម្រាប់ប្រព័ន្ធគាំពារសង្គមនៅកម្ពុជា**




ចំពោះករណីគ្រោះអាសន្នទាំងឡាយ ដែលមានទំហំ និងស្ថានភាពប្រហាក់ប្រហែលនឹងវិបត្តិជំងឺកូវីដ-១៩ ដែលតម្រូវឱ្យមានការរៀបចំបង្កើតក្រុមការងារចំពោះកិច្ច, អនុគណៈកម្មាធិការកិច្ច

គាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន នឹងត្រូវបញ្ចូលជាអនុក្រុមការងារស្នូលនៃក្រុមការងារចំពោះកិច្ចនេះ។

### ៦.២.២ យន្តការសម្របសម្រួលរវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍

ក្រុមប្រឹក្សាជាតិគាំពារសង្គមបានរៀបចំបង្កើតយន្តការសម្របសម្រួលរវាងរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ ក្នុងប្រព័ន្ធគាំពារសង្គមនៅឆ្នាំ២០២០។ យន្តការសម្របសម្រួលនេះ ផ្តោតលើកិច្ចសហការក្នុងផ្នែកចំនួន ៣ រួមមាន ប្រព័ន្ធជំនួយសង្គម, ប្រព័ន្ធសន្តិសុខសង្គមពាក់ព័ន្ធនឹងវិស័យការងារ និងប្រព័ន្ធគាំពារសង្គមផ្នែកថែទាំសុខភាព ដែលមានគោលបំណងលើកកម្ពស់ភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍, ពង្រឹងកិច្ចសហប្រតិបត្តិការ, បង្កើនប្រសិទ្ធភាព និងសង្គតិភាពការរៀបចំគោលនយោបាយ និងអនុវត្តកម្មវិធី និងរបបគាំពារសង្គម និងការធ្វើសុខដុមនីយកម្មកិច្ចគាំពារសង្គមនៅកម្ពុជាឱ្យកាន់តែប្រសើរឡើង។ យន្តការនេះ ក៏មានក្រុមការងារកម្រិតខ្ពស់មួយទៀតសម្រាប់សម្របសម្រួលកម្រិតជាតុចូលគោលនយោបាយ ដែលបង្កើតបន្ថែមលើក្រុមការងារសម្រាប់ផ្នែកទាំង៣។ ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធមានតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ហើយការអនុវត្តសកម្មភាពក្រោមក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្នរបស់ដៃគូអភិវឌ្ឍន៍ នឹងត្រូវសម្របសម្រួលក្រោមយន្តការដែលមានស្រាប់នេះ។ ក្រុមប្រឹក្សាជាតិគាំពារសង្គមនឹងប្រើប្រាស់យន្តការនេះ ដើម្បីធ្វើការទំនាក់ទំនង និងពិភាក្សាលើការងារអាទិភាព ព្រមទាំងពង្រឹងភាពជាដៃគូយុទ្ធសាស្ត្រ ជាមួយដៃគូអភិវឌ្ឍន៍ដើម្បីគាំទ្រដល់ការអនុវត្តការងារអាទិភាពខាងលើ។

ក្រោមយន្តការសម្របសម្រួលខាងលើ, សម្រាប់រយៈពេលខ្លី សកម្មភាពដែលត្រូវអនុវត្តសម្រាប់កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ននឹងផ្តោតជាចម្បងលើប្រព័ន្ធជំនួយសង្គម ហើយការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ នឹងត្រូវធ្វើឡើងតាមរយៈក្រុមការងារផ្នែកប្រព័ន្ធជំនួយសង្គមផងដែរ។ ទន្ទឹមនេះ វេទិកាឆ្លើយតបមនុស្សធម៌នឹងត្រូវអញ្ជើញឱ្យចូលរួមក្នុងយន្តការសម្របសម្រួលនេះ ព្រមទាំងជានាឱ្យមានការនាំយកមកនូវជំនាញ និងបច្ចេកទេសរបស់ស្ថាប័នមនុស្សធម៌ដើម្បីប្រើប្រាស់ក្នុងកិច្ចសហប្រតិបត្តិការសម្រាប់កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន។ ប្រព័ន្ធសន្តិសុខសង្គមក៏មានកិច្ចការជាក់លាក់មួយចំនួនដែលត្រូវអនុវត្ត ដូចជាការធ្វើសមាហរណកម្មប្រព័ន្ធចុះបញ្ជីរបស់បេឡាជាតិសន្តិសុខសង្គម និងការពង្រីកវិសាលភាពគ្របដណ្តប់នៃរបបសន្តិសុខផ្នែកថែទាំសុខភាពទៅដល់អ្នកក្នុងបន្ទុករបស់សមាជិក។

## យន្តការតាមដាន និងវាយតម្លៃ

ក្របខណ្ឌតាមដាន និងវាយតម្លៃកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន នឹងត្រូវបានរៀបចំឡើង ដោយបន្សុីជាមួយយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម។ ក្របខណ្ឌតាមដាន និងវាយតម្លៃ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ នឹងត្រូវបានរៀបចំឡើងដើម្បីគាំទ្រដល់ការតាមដានការអនុវត្តកម្មវិធីឆ្លើយតបនឹងគ្រោះអាសន្ននៅពេលដាក់ឱ្យអនុវត្ត។ ស្ថាប័នប្រតិបត្តិករនៃប្រព័ន្ធគាំពារសង្គម មានភារកិច្ចតាមដានការអនុវត្តកម្មវិធីឆ្លើយតបនឹងគ្រោះអាសន្ន ដោយមានការគាំទ្រពីអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម និងស្ថាប័នពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ការតាមដាន និងវាយតម្លៃមានគោលបំណងសំខាន់ៗ រួមមានស្វែងយល់អំពីភាពជាប់ពាក់ព័ន្ធរបស់កម្មវិធី និងពិនិត្យវឌ្ឍនភាពរបស់កម្មវិធី, សិក្សាទាញយកមេរៀន និងឧត្តមានុវត្តន៍នៃកម្មវិធីឆ្លើយតបនឹងគ្រោះអាសន្ន រួមទាំងការបើកផ្តល់, ស្វែងរកផលជះ បច្ច័យ និងលទ្ធផលចុងក្រោយនៃកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន និងពិនិត្យលើប្រសិទ្ធភាពចំណាយ។ ការវាយតម្លៃនេះ ត្រូវដឹកនាំដោយ **អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម** ដោយមានការគាំទ្រពីក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងន័យពង្រឹង និងកែលម្អការអនុវត្តកម្មវិធី និងពង្រីកវិសាលភាពគ្របដណ្តប់។

## សេចក្តីសន្និដ្ឋាន

រាជរដ្ឋាភិបាលមើលឃើញពីសារៈសំខាន់នៃការកសាងប្រព័ន្ធគាំពារសង្គម ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ សមាហរណ៍ និងស្វ័យប្រវត្តិកម្ម ក្នុងការគាំពារប្រជាពលរដ្ឋ ជាពិសេសក្នុងអំឡុងពេលមានវិបត្តិ ឬគ្រោះអាសន្ន។ ការរៀបចំ និងដាក់ចេញគោលការណ៍ណែនាំស្តីពីក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ជាការធ្វើស្ថាប័នូបនីយកម្មការឆ្លើយតបនឹងគ្រោះអាសន្នពីប្រព័ន្ធគាំពារសង្គមដើម្បីត្រៀមលក្ខណៈឆ្លើយតប និងកសាងភាពធន់។

ក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ននេះ នឹងអនុញ្ញាតឱ្យរាជរដ្ឋាភិបាលប្រើប្រាស់ប្រព័ន្ធគាំពារសង្គម ដើម្បីផ្តល់នូវការគាំពារដែលមានលក្ខណៈជាប្រព័ន្ធ, អាចព្យាករទុកមុនទាន់ពេល និងមានប្រសិទ្ធភាព ក្នុងការឆ្លើយតបនឹងគ្រោះអាសន្ន តាមរយៈការដាក់ចេញនូវសំណុំវិធានការអន្តរាគមន៍ជាក់លាក់ ដោយប្រើប្រាស់ប្រព័ន្ធទិន្នន័យ និងយន្តការបើកផ្តល់ដែលមានស្រាប់ដើម្បីជួយគាំពារដល់ពលរដ្ឋ ជាពិសេសពលរដ្ឋក្រីក្រ, ងាយរងគ្រោះ និងងាយរងហានិភ័យនៅពេលមានគ្រោះអាសន្ន។ ក្របខណ្ឌនេះ ក៏បានដាក់ចេញនូវការងារអាទិភាពទៅតាមបណ្តុំជាមូលដ្ឋានទាំង ៥ រួមមាន (១) ការរៀបចំក្របខណ្ឌគោលនយោបាយ និងស្ថាប័ន, (២) ការរៀបចំយន្តការអនុវត្តកម្មវិធី, (៣) ប្រព័ន្ធបើកផ្តល់, (៤) ប្រព័ន្ធទិន្នន័យ និងព័ត៌មាន និង (៥) ហិរញ្ញប្បទាន ក្នុងគោលបំណងកសាងភាពធន់ក្នុងសង្គម, បង្កើនភាពត្រៀមលក្ខណៈនៃប្រព័ន្ធគាំពារសង្គម, ជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម និងការត្រៀមទុកជាមុនដើម្បីឆ្លើយតបនឹងគ្រោះអាសន្ននានា។ លើសពីនេះ ក្របខណ្ឌនេះនឹងបើកផ្លូវឱ្យមានយន្តការសម្របសម្រួលអន្តរក្រសួង-ស្ថាប័នដែលមានសមត្ថកិច្ច ព្រមទាំងអនុញ្ញាតឱ្យរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ពង្រឹងកិច្ចសហការ និងការធ្វើសុខដុមនីយកម្មកិច្ចគាំពារសង្គមនៅកម្ពុជាឱ្យកាន់តែប្រសើរ។

# សទ្ទានុក្រម

**កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដោយភ្ជាប់លក្ខខណ្ឌ៖** សំដៅដល់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដោយភ្ជាប់នូវការអនុវត្តលក្ខខណ្ឌតម្រូវឱ្យអ្នកទទួលផលអនុវត្តសកម្មភាពជាក់លាក់មួយចំនួន ដូចជាការមករៀនទៀងទាត់, ការមកទទួលយកសេវាសុខភាព និងពិនិត្យលើកម្រិតអាហាររូបត្ថម្ភ និងការបំពេញការងារដើម្បីទទួលបានអត្ថប្រយោជន៍ ពីកម្មវិធីជំនួយសង្គម ឬរបបសន្តិសុខសង្គម ពោលគឺលក្ខខណ្ឌត្រូវបំពេញ មុននឹងទទួលបានអត្ថប្រយោជន៍។

**ការរៀបចំកែសម្រួលយន្តការអនុវត្តកម្មវិធី៖** សំដៅដល់ជម្រើសឧបករណ៍គោលនយោបាយ សម្រាប់កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ដែលតម្រូវឱ្យមានការកែសម្រួលយន្តការអនុវត្តកម្មវិធី និងរបបគាំពារសង្គមដែលមានស្រាប់ ផ្អែកទៅតាមប្រភេទនៃគ្រោះអាសន្នដែលជួបប្រទះ ដើម្បីធានាបាននូវប្រក្រតីភាពនៃកិច្ចដំណើរការប្រតិបត្តិការរបស់កម្មវិធីនៅក្នុងពេលមានគ្រោះអាសន្ន ព្រមទាំងធានាឱ្យបាននូវការបំពេញតម្រូវការរបស់ពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយគ្រោះអាសន្ន។

**ការពង្រីកវិសាលភាពគ្របដណ្តប់តាមខ្សែផ្តេក៖** សំដៅដល់ជម្រើសឧបករណ៍គោលនយោបាយសម្រាប់កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន តាមរយៈការដាក់បញ្ចូលក្រុមគោលដៅថ្មីដែលរងផលប៉ះពាល់ពីគ្រោះអាសន្ន ជាបណ្តោះអាសន្ន។

**ការពង្រីកវិសាលភាពគ្របដណ្តប់តាមខ្សែបញ្ឈរ៖** សំដៅដល់ជម្រើសឧបករណ៍គោលនយោបាយសម្រាប់កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន តាមរយៈការបង្កើនកម្រិតអត្ថប្រយោជន៍ ឬពន្លាតរយៈពេលនៃការផ្តល់អត្ថប្រយោជន៍ ជាបណ្តោះអាសន្នសម្រាប់អ្នកទទួលផលដែលមាននៅក្នុងកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមដែលមានស្រាប់។

**ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន(MIS)៖** សំដៅដល់ប្រព័ន្ធ ឬកម្មវិធី (Software) គ្រប់គ្រងព័ត៌មានបម្រើដល់ការបំពេញមុខងារ សម្រាប់ដំណើរការចុះបញ្ជី និងពិនិត្យលក្ខណៈវិនិច្ឆ័យ ដើម្បីបញ្ចូលក្នុងប្រព័ន្ធ ឬប្រតិបត្តិការនៃកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមជាក់លាក់ណាមួយដើម្បីផ្តល់អត្ថប្រយោជន៍ ដូចជាប្រតិបត្តិការបើកផ្តល់ និងត្រួតពិនិត្យការអនុវត្តលក្ខខណ្ឌជាដើម។

**ប្រព័ន្ធជំនួយសង្គម៖** សំដៅដល់អន្តរាគមន៍សម្រាប់ជាប្រយោជន៍ដល់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះ ដែលហិរញ្ញប្បទានដោយថវិកាជាតិ និង/ឬជំនួយអភិវឌ្ឍន៍ផ្លូវការ។ កិច្ចអន្តរាគមន៍ទាំងនោះរួមមាន (១) ការឆ្លើយតបនឹងគ្រោះអាសន្ន (២) ការអភិវឌ្ឍមូលធនមនុស្ស (៣) ការបណ្តុះបណ្តាលវិជ្ជាជីវៈ (៤) សុខុមាលភាពសម្រាប់ជនងាយរងគ្រោះ។

**ប្រព័ន្ធសន្តិសុខសង្គម៖** សំដៅដល់កម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម ដែលផ្តល់ការគាំពារដល់ពលរដ្ឋពីការធ្លាក់ចុះភ្លាមៗនៃប្រាក់ចំណូលដែលបណ្តាលមកពីជំងឺ, លំហែមាតុភាព, គ្រោះថ្នាក់ការងារ, និកម្មភាព, ទុព្វលភាព, ជរាភាព និងមរណភាពរបស់អ្នកដែលរកប្រាក់ចំណូលចិញ្ចឹមគ្រួសារ ដូចជា៖ (១) ប្រាក់សោធន, (២) ការថែទាំសុខភាព, (៣) ហានិភ័យការងារ, និង (៤) និកម្មភាពជាដើម។ របបសន្តិសុខសង្គម តម្រូវឱ្យសមាជិក និងភាគីពាក់ព័ន្ធ បង់ភាគទានជាកាតព្វកិច្ចទៅតាម

អត្រាជាក់លាក់។ រាជរដ្ឋាភិបាលប្រកាន់ខ្ជាប់នូវលើគោលការណ៍ផ្តល់ឧបត្ថម្ភធនសម្រាប់ពលរដ្ឋដែលមិនមានលទ្ធភាពបង់ភាគទាន ពោលគឺពលរដ្ឋក្រីក្រ និងងាយរងគ្រោះ។

**ប្រព័ន្ធគាំពារសង្គម៖** សំដៅដល់គោលនយោបាយ, កម្មវិធី, សកម្មភាព, ក្របខណ្ឌច្បាប់ និងក្របខណ្ឌស្ថាប័ន ដែលត្រូវបានរៀបចំដើម្បីផ្តល់ការគាំពារ និងពង្រឹងសមត្ថភាពរបស់ពលរដ្ឋ ក្នុងការដោះស្រាយប្រកបដោយប្រសិទ្ធភាពទៅនឹងការប្រឈមនូវហានិភ័យផ្នែកសង្គម-សេដ្ឋកិច្ច និងភាពងាយរងគ្រោះផ្សេងៗ ដែលបណ្តាល មកពីការប្រែប្រួលលក្ខខណ្ឌរស់នៅ និងការងារ ដូចជាការធ្លាក់ចូលទៅក្នុងភាពក្រីក្រដែលបណ្តាលមកពីការទទួលរងឥទ្ធិពលពីគ្រោះធម្មជាតិ, តម្រូវការលើការថែទាំសុខភាព, ការធ្លាក់ខ្លួនពិការភាព ឬការឈានចូលវ័យចាស់ជរា ជាដើម។

**កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន៖** សំដៅដល់ការប្រើប្រាស់សក្តានុពលនៃប្រព័ន្ធគាំពារសង្គមដើម្បីកាត់បន្ថយភាពរងឥទ្ធិពលពីគ្រោះអាសន្ននានា ដូចជាគ្រោះអាសន្នដែលបង្កផលប៉ះពាល់លើសហគមន៍, ថ្នាក់តំបន់, ឬថ្នាក់ជាតិ ក្នុងគោលបំណងផ្តល់ការគាំទ្រដល់គ្រួសារដែលទទួលរងផលប៉ះពាល់ដោយគ្រោះអាសន្ន។

**មូលដ្ឋានចុះបញ្ជីសង្គម៖** សំដៅដល់ឃ្លាំងផ្ទុកទិន្នន័យចុះបញ្ជី, លក្ខណៈវិនិច្ឆ័យ ឬអត្តសញ្ញាណពលរដ្ឋដែលជាក្រុមគោលដៅ ដែលអាចនឹងត្រូវទទួលបានអត្ថប្រយោជន៍ពីកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមនានា ក្នុងប្រព័ន្ធគាំពារសង្គម។



គាំពារ គាំពារ គាំពារ
សិទ្ធិ សិទ្ធិ សិទ្ធិ
កម្ពុជា កម្ពុជា កម្ពុជា